**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីនៃការជម្រះក្ដីលើកទី១

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **ស្រ៊ុន ម៉ូរ៉ានី**
**រី ស៊ីណា**

សាស្ត្រាចារ្យណែនាំ
**លោក ញឹក ឌុធ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស្រ៊ុន មុំរ៉ានី** និង **រី ស៊ីណា** ជានិស្សិតបរិញ្ញាបត្រឆ្នាំទី៤ ជំនាន់ទី១៧ ផ្នែកនីតិសាស្ត្រនៃសាលាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។

សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតចំពោះ ៖

លោកឪពុក **លាង ស្រ៊ុន** និងអ្នកម្តាយ **គង់ មុទុម** រួមទាំងលោកឪពុក **រុន រី** និងអ្នកម្តាយ **ណូយ មុំយ** ដែលលោកមានគុណយ៉ាងធំធេង ដែលលោកមិនត្រឹមតែផ្តល់កំណើតដល់រូបខ្ញុំតែប៉ុណ្ណោះនោះទេ គឺលោកបានខិតខំចិញ្ចឹម បីបាច់ថែរក្សា ផ្តល់ដំបូន្មានល្អៗ ព្រមទាំងខិតខំអស់ពីកម្លាំងកាយចិត្តរកប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃផង និងសម្រាប់ការសិក្សាសម្រាប់កូនៗផង ដើម្បីឱ្យកូនៗទទួលបានចំណេះដឹង និងក្លាយខ្លួនជាពលរដ្ឋល្អមួយរូបក្នុងសង្គម។ ទោះលោកទាំងពីរត្រូវហត់នឿយយ៉ាងណាក៏លោកមិនមែនត្អូញត្អែរ ហើយថែមទាំងផ្តល់កម្លាំងចិត្តឱ្យកូនខិតខំរៀនសូត្រ ធ្វើឱ្យកូនៗមានភាពកក់ក្តៅក្នុងចិត្តក្រៃលែង ដោយសារតែមានការជម្រុញលើកទឹកចិត្តអំពីលោកទាំងពីរនេះហើយ ទើបធ្វើឱ្យយើងខ្ញុំទាំងពីរនាក់បានបន្តការសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ទើបមានឱកាសសរសេរសារណាមួយនេះឡើង។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការដឹកនាំគ្រប់គ្រង និងបានបង្ហាត់បង្រៀនរូបយើងខ្ញុំឱ្យទទួលបានចំណេះដឹងលទ្ធផលនៃការសិក្សាទទួលបានបានពិន្ទុល្អ និងមានលទ្ធភាពក្នុងការសរសេរសារណាមួយនេះ។

លោកសាស្ត្រាចារ្យ **ញឹក ឧុធី** ដែលយល់ព្រមធ្វើជាគ្រូដឹកនាំការសរសេរសារណានេះ ហើយថែមទាំងបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការដឹកនាំ បង្ហាត់បង្ហាញ ពន្យល់ណែនាំ កែតម្រូវត្រង់ចំណុចខ្វះខាតរបស់យើងខ្ញុំទាំងពីរ និងផ្តល់អនុសាសន៍ល្អៗដល់ការសរសេរសារណានេះឡើង។

លោកស្រី **ជ័យ មាលា** ជាចៅក្រមសាលាដំបូងខេត្តតាកែវ និងជាអនុប្រធានសាលាដំបូងខេត្តតាកែវ លោក **តិន ផល្លែង** និងលោក **ហុង សុងហ៊ាង** ជាចៅក្រមសាលាដំបូងខេត្តតាកែវ ដែលបានចំណាយពេលវេលា ចែករំលែកចំណេះដឹង បង្ហាត់បង្រៀន ផ្តល់ជាបទពិសោធន៍ ទីតាំង និងឱកាសឲ្យយើងខ្ញុំបានចុះស្រាវជ្រាវ និងផ្តល់ឯកសារមួយចំនួនមកធ្វើជាឯកសារគំរូនៅក្នុងឧបសម្ព័ន្ធនៃសារណារបស់យើងខ្ញុំ។

ជាចុងបញ្ចប់ យើងខ្ញុំសូមលំឱនកាយបួងសួងដល់វត្ថុស័ក្តិសិទ្ធិជួយបីបាច់ថែរក្សា លោកឪពុក និងអ្នកម្តាយ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកនៃសាកលវិទ្យាល័យ លោកគ្រូសាស្ត្រាចារ្យដឹកនាំសារណា លោក និងលោកស្រី ចៅក្រម** ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សារៀនសូត្រនៅថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រកន្លងមកអស់រយៈពេលបួនឆ្នាំនៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** រួចមក យើងខ្ញុំទទួលបានចំណេះដឹងយ៉ាងច្រើន រួមទាំងចំណេះដឹងទាក់ទងនឹងផ្នែកនីតិសាស្ត្រនៅក្នុងពេលអតីតកាល និងស្ថានភាពជាក់ស្តែងនៅក្នុងសង្គមបច្ចុប្បន្នផងដែរ ដោយសារតែលោក លោកស្រីសាស្ត្រាចារ្យបានលើកយកមេរៀនសំខាន់ៗមកធ្វើការបង្ហាញដល់និស្សិត ទាំងច្បាប់ជាតិ អន្តរជាតិ និងវប្បធម៌ទូទៅជាដើម។ មិនតែប៉ុណ្ណោះតាមរយៈការសិក្សាជាមួយលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ពួកគាត់បានអប់រំទូន្មានឱ្យធ្វើជាពលរដ្ឋល្អនៅក្នុងសង្គមផងដែរ។

ស្នាដៃមួយនេះ បានចងក្រងឡើង ដើម្បីជាសក្ខីភាពក្នុងការបញ្ជាក់នូវចំណេះដឹង ដែលយើងខ្ញុំទទួលបានតាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះអស់រយៈពេលបួនឆ្នាំកន្លងមក។ ក្នុងស្នាដៃតូចមួយនេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយគឺ "**នីតិវិធីនៃការជម្រះក្តីលើកទី១**" យកមកធ្វើការបង្ហាញ ហើយប្រធានបទនេះជាផ្នែកមួយនៃនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏ជានីតិវិធីដែលសំខាន់ណាស់នៅក្នុងរឿងក្តីរដ្ឋប្បវេណី។

យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ ពីព្រោះយើងខ្ញុំយល់ឃើញថា នៅក្នុងការរស់នៅរបស់មនុស្សនៅក្នុងសង្គមមួយតែងតែមានវិវាទកើតមានឡើង ដោយសារមានការរំលោភបំពានសិទ្ធិគ្នា។ ក្នុងករណីមានការបំពានសិទ្ធិគ្នាបែបនេះ គឺមានការប្តឹងមកតុលាការ ដើម្បីឱ្យតុលាការឱ្យដោះស្រាយ ហើយដើម្បីតុលាការអាចដោះស្រាយនោះវិវាទបានដោយផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ជាគោលការណ៍ នៅក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណីមាននីតិវិធីជាច្រើនដូចជា ការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងជាចុងក្រោយគឺការប្រកាសសាលក្រម។

យើងខ្ញុំសង្ឃឹមថាការចងក្រងប្រធានបទនេះឡើងអាចមានអត្ថប្រយោជន៍ដល់អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ។ ទោះបីជាមានការខិតខំប្រឹងប្រែង និងប្រុងប្រយ័ត្នខ្ពស់យ៉ាងណាក្តី សារណាមួយនេះ មិនអាចថាគ្មានចំណុចខ្វះខាតដោយជៀសមិនផុតឡើយ ដូច្នេះយើងខ្ញុំសូមអធ្យាស្រ័យ និងអភ័យទោសទុកជាមុនចំពោះកំហុសឆ្គងទាំងឡាយដែលបានកើតឡើងដោយអចេតនា។ ទន្ទឹមនឹងនេះ នាងខ្ញុំក៏សុំរង់ចាំដោយក្តីរីករាយក្នុងការទទួលយកនូវមតិរិះគន់ កែលម្អក្នុងន័យស្ថាបនាទាំងឡាយដើម្បីធ្វើឲ្យអត្ថបទសារណានេះកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា

**ទំព័រ**

**តារាងសម្គាល់អក្សរកាត់** ... v

**បញ្ជីរាយនាមឧបសម្ព័ន្ធ** ... vi

**សេចក្តីផ្តើម** ... 1

**ជំពូកទី១**

**ការដាក់ពាក្យបណ្តឹង**

**ផ្នែកទី១. របៀបដាក់ពាក្យបណ្តឹង** ... 3

កថាភាគទី១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹង ... 3

១. អត្តសញ្ញាណរបស់ភាគី ... 3

២. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ... 4

៣. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ... 5

កថាភាគទី២. ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង ... 5

១. អង្គហេតុដែលជាមូលហេតុនៃការទាមទារ ... 5

២. អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង ... 6

**ផ្នែកទី២. ការទទួលពាក្យបណ្តឹង** ... 6

កថាភាគទី១. នីតិវិធីនៃការទទួលពាក្យបណ្តឹង ... 6

កថាភាគទី២. ឯកសារភ្ជាប់ជាមួយពាក្យបណ្តឹង ... 7

កថាភាគទី៣. ពន្ធដាក់ពាក្យបណ្តឹង និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ... 8

១. ពន្ធដាក់ពាក្យបណ្តឹង ... 8

២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ... 8

**ផ្នែកទី៣. ការពិនិត្យពាក្យបណ្តឹង** ... 9

កថាភាគទី១. របៀបពិនិត្យពាក្យបណ្តឹង ... 9

កថាភាគទី២. ដីកាបង្គាប់ឲ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល ... 10

**ផ្នែកទី៤. ការបែងចែករឿងក្តី** ... 10

កថាភាគទី១. ការបែងចែករឿងក្តីតាមលំដាប់ដែលបានកំណត់ ... 10

កថាភាគទី២. ការបែងចែករឿងក្ដីទៅឲ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម................ 10

**ជំពូកទី២**

**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ផ្នែកទី១. សញ្ញាណនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.................................... 12
កថាភាគទី១. អត្ថន័យ និងគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល .................. 12
១. អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................................................ 12
២. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល............................................ 12
កថាភាគទី២. កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល .................................. 13
១. ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................ 13
២. ការបញ្ជូនពាក្យបណ្ដឹង និងការកោះហៅគូភាគី ................................................... 14
៣. នីតិវិធីនៃការបញ្ជូន ........................................................................................ 14
កថាភាគទី៣. ការបំបែក និងបញ្ចូលសំណុំរឿងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.......... 16
**ផ្នែកទី២. ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**................................ 17
កថាភាគទី១. ការសាកល្បងផ្សះផ្សា......................................................................... 17
កថាភាគទី២. ការរៀបចំការអះអាង ភស្តុតាង និងការកំណត់ចំណុចវិវាទ ............................. 19
១. ការរៀបចំការអះអាង ........................................................................................ 19
២. ការកំណត់ចំណុចវិវាទនៃរឿងក្ដី........................................................................ 20
៣. ការរៀបចំភស្តុតាង .......................................................................................... 21
កថាភាគទី៣. កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.................................. 21
១. ភាពចាំបាច់នៃកំណត់ហេតុ ................................................................................ 21
២. ចំណុចដែលត្រូវសរសេរចូលក្នុងកំណត់ហេតុ.......................................................... 21
**ផ្នែកទី៣. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**...................................... 22
កថាភាគទី១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់.............................................. 22
កថាភាគទី២. ការកំណត់កាលបរិច្ឆេទលើកទីមួយនៃការទាញហេតុផលដោយផ្ទាល់មាត់............ 23

**ជំពូកទី៣**

**នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

**ផ្នែកទី១. សញ្ញាណទូទៅនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**............................ 24

កថាភាគទី១. ការកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........................ 24
កថាភាគទី២. ភាពចាំបាច់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........................................ 25
**ផ្នែកទី២. ដំណើរការនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** .................................... 25
កថាភាគទី១. ការសាកល្បងធ្វើការផ្សះផ្សា ........................................................................ 25
កថាភាគទី២. សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............ 25
កថាភាគទី៣. ការដាក់មធ្យោបាយតទល់ និងមធ្យោបាយការពារថ្មី ........................................ 26
កថាភាគទី៤. ការពិនិត្យភស្តុតាងដោយសមូហវិធី ................................................................ 26
១. ការសាកសួរសាមីភាគី ......................................................................................... 26
២. ការសាកសួរសាក្សី ............................................................................................... 27
៣. កោសលវិច័យ ...................................................................................................... 30
៤. ភស្តុតាងជាឯកសារ ............................................................................................... 32
៥. ការត្រួតពិនិត្យ ..................................................................................................... 33
**ផ្នែកទី៣. ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់** .................................................. 34
កថាភាគទី១. កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ .................................... 35
១. ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ .......................... 35
២. ចំណុចជាសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........................ 35
កថាភាគទី២. ការកត់ត្រាដោយថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ .................................. 36
កថាភាគទី៣. ការយកឯកសារ ជាអាទិ៍ ជាអាគតដ្ឋាន និង ការភ្ជាប់ជាឧបសម្ព័ន្ធ ......................... 36

## ជំពូកទី៤

## ការប្រកាសសាលក្រម

**ផ្នែកទី១. សញ្ញាណទូទៅនៃសាលក្រម** ......................................................................... 37
កថាភាគទី១. អត្ថន័យនៃសាលក្រម ................................................................................... 37
កថាភាគទី២. សាលក្រមចុងក្រោយ .................................................................................... 37
១. សាលក្រមលើកបណ្តឹងចោល ...................................................................................... 37
២. សាលក្រមទទួលស្គាល់ការទាមទារ ............................................................................. 38
៣. សាលក្រមមិនទទួលស្គាល់ការទាមទារ ........................................................................ 38
កថាភាគទី៣. សាលក្រមរបៀប ........................................................................................... 38

១. អត្ថន័យនៃសាលក្រមរបៀប ........ 38

២. ចំណុចដែលអាចចេញសាលក្រមរបៀប ........ 38

**ផ្នែកទី២. ដំណើរការនៃការប្រកាសសាលក្រម** ........ 39

កថាភាគទី១. កាលបរិច្ឆេទនៃការប្រកាសសាលក្រម ........ 39

កថាភាគទី២. របៀបនៃការប្រកាសសាលក្រម ........ 39

កថាភាគទី៣. លិខិតសាលក្រម ........ 40

**ផ្នែកទី៣. អានុភាពនៃសាលក្រម** ........ 40

កថាភាគទី១. អត្តពន្ធភាពនៃសាលក្រម ........ 41

កថាភាគទី២. អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ ........ 41

កថាភាគទី៣. អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ........ 41

កថាភាគទី៤. អានុភាពអនុវត្ត ........ 42

កថាភាគទី៥. អានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ........ 42

**សេចក្តីសន្និដ្ឋាន** ........ 43

**អនុសាសន៍** ........ 45

**គន្ថនិទ្ទេស** ........ 46

**ឧបសម្ព័ន្ធ** ........ 47

# តារាងសម្គាល់អក្សរកាត់

| ល.រ | ពាក្យកាត់ | ពាក្យពេញ |
|---|---|---|
| ០១ | ក្រមនីតិវិធីរដ្ឋប្បវេណី | ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។ |
| ០២ | សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី | សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី បោះពុម្ពឆ្នាំ២០០៧។ |
| ០៣ | សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋ-ប្បវេណីភាគ១: នីតិវិធីបណ្តឹង | សៀវភៅ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី បោះពុម្ពឆ្នាំ២០០៨។ |

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឧបសម្ព័ន្ធ |
|---|---|
| ០១ | ពាក្យបណ្តឹង |
| ០២ | បង្កាន់ដៃបង់ប្រាក់ |
| ០៣ | កំណត់បង្ហាញរឿង |
| ០៤ | លិខិតតំណាងដោយអាណត្តិ |
| ០៥ | ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ |
| ០៦ | ដីកាបង្គាប់ឲ្យកែតម្រូវ |
| ០៧ | ដីកាសម្រេចលើកពាក្យបណ្តឹងចោល |
| ០៨ | សាលក្រមលើកបណ្តឹងចោល |
| ០៩ | ដីកាកោះ |
| ១០ | លិខិតអញ្ជើញមេធាវី |
| ១១ | របាយការណ៍ស្តីពីការបញ្ជូនដីកាកោះ |
| ១២ | កំណត់ហេតុសះជា |
| ១៣ | កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង<br>សេចក្តីថ្លែងការណ៍សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល |
| ១៤ | ពាក្យសុំបញ្ចូលភស្តុតាងជាឯកសារ |
| ១៥ | លិខិតសុំបញ្ចូលសាក្សី |
| ១៦ | ពាក្យសុំបញ្ចូលភស្តុតាង |
| ១៧ | ដីកាកោះហៅភាគីឱ្យចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ |
| ១៨ | របាយការណ៍ស្តីពីការបញ្ជូន |
| ១៩ | ដីកាបញ្ជូន |
| ២០ | លិខិតអញ្ជើញមេធាវី |
| ២១ | កំណត់ហេតុស្តីពីការសះជា |
| ២២ | សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល |

| | |
|---|---|
| ២៣ | កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ |
| ២៤ | សាលក្រម |
| ២៥ | កំណត់ហេតុប្រកាសសាលក្រម |
| ២៦ | លិខិតបញ្ជាក់ស្តីពីការចូលជាស្ថាពរនៃសាលក្រម |

# សេចក្តីផ្តើម

នៅក្នុងការរស់នៅរបស់មនុស្សគ្រប់រូប តែងតែប្រាថ្នាចង់បានសេចក្តីសុខកាយ សប្បាយចិត្ត និងទទួលបានយុត្តិធម៌ស្មើៗគ្នា ព្រមទាំងនៅក្នុងការប្រកបមុខរបររកស៊ី តែនេះគ្រាន់តែជាសេចក្តីប្រាថ្នាចង់បានរបស់មនុស្សគ្រប់គ្នាតែប៉ុណ្ណោះ។ តែយ៉ាងណាមិញ សេចក្តីសុខកាយ សប្បាយចិត្តនឹងមិនកើតមានឡើងឡើយ ប្រសិនបើការរស់នៅត្រូវទទួលរងនូវការបំពានសិទ្ធិ ឬ ការបំពានលើទ្រព្យសម្បត្តិរបស់ខ្លួន ត្រូវបានបុគ្គលដទៃធ្វើឱ្យប៉ះពាល់ ឬ ខូចខាតនោះ។ ដោយសារតែមានការរំលោភបំពានបែបនេះហើយ ទើបប្រទេសបង្កើតច្បាប់ដើម្បីរារាំង និងទប់ស្កាត់អំពើបំពានទាំងនោះ។ ការបង្កើតឱ្យមានច្បាប់ដើម្បីគ្រប់គ្រងមិនគ្រប់គ្រាន់នោះឡើយ។ ទោះបីជាមានច្បាប់គ្រប់គ្រងយ៉ាងណាក៏ដោយ ក៏ជម្លោះនៅតែកើតមានឡើងជៀសមិនផុត ដែលជាហេតុនាំឱ្យមានការកើតទុកមិនសុខចិត្តបែបនេះហើយ ទើបស្ថាប័នតុលាការមានតួនាទីសំខាន់ណាស់លើការដោះស្រាយវិវាទរបស់បុគ្គលឯកជន គឺតុលាការរដ្ឋប្បវេណី ដែលមានសមត្ថកិច្ចដោះស្រាយវិវាទរដ្ឋប្បវេណី ឬ វិវាទពាណិជ្ជកម្ម ជាដើម។

ជាការពិតណាស់ការដោះស្រាយវិវាទរដ្ឋប្បវេណី គឺផ្តើមឡើងដោយមានការដាក់ពាក្យបណ្តឹងមកតុលាការរដ្ឋប្បវេណីដែលមានសមត្ថកិច្ច។ ហើយតុលាការ ដើម្បីអាចសម្រេចសេចក្តីត្រូវឆ្លងកាត់នីតិវិធីច្រើន ហើយនីតិវិធីមួយដែលចាំបាច់មិនអាចខ្វះបានមុននឹងសម្រេចសេចក្តីនោះ គឺនីតិវិធីជម្រះក្តីលើកទី១។ គួសបញ្ជាក់ផងដែរថានៅក្នុងរឿងក្តីរដ្ឋប្បវេណីមាននីតិវិធីច្រើនដូចជានីតិវិធីបណ្តឹង នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច នីតិវិធីដាស់តឿន នីតិវិធីអនុវត្តដោយបង្ខំ និងនីតិវិធីរក្សាការពារជាដើម ដោយពេលនេះយើងនឹងធ្វើការបកស្រាយដោយផ្តោតសំខាន់លើនីតិវិធីបណ្តឹង ឬនីតិវិធីនៃការជម្រះក្តីលើកទី១តែប៉ុណ្ណោះ។

ដើម្បីឱ្យយល់ច្បាស់ពីប្រធានបទមួយនេះ យើងខ្ញុំបានស្វែងរកចំណោទបញ្ហាមួយចំនួនដូចខាងក្រោម ៖

-តើការដាក់ពាក្យបណ្តឹង និងទទួលពាក្យបណ្តឹងត្រូវប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

-តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

-តើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

-តើការប្រកាសសាលក្រមប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

ដោយមើលឃើញនូវចំណោទបញ្ហាទាំងនេះ ទើបយើងខ្ញុំមានចំណាប់អារម្មណ៍ចំពោះនីតិវិធីនៃការជម្រះក្តីលើកទី១នេះ។ អាស្រ័យហេតុនេះ ចំពោះដែនកំណត់នៃការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនឹងសម្រេចយកត្រឹមតែនីវិធីជម្រះក្តីលើកទី១ប៉ុណ្ណោះ ពោលគឺចាប់ពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹងរហូតដល់ពេលប្រកាសសាលក្រម។

ដើម្បីងាយស្រួលក្នុងការបកស្រាយពាក់ព័ន្ធនឹងប្រធានបទសារណានេះ យើងខ្ញុំបានបែងចែកជាបី (០៤) ជំពូកគឺ ៖

- ជំពូកទី១ ៖ **ការដាក់ពាក្យបណ្តឹង** ដែលបែងចែកជាបួន (០៤) ផ្នែកគឺ ៖
  - -ផ្នែកទី១ ៖ របៀបដាក់ពាក្យបណ្តឹង
  - -ផ្នែកទី២ ៖ ការទទួលពាក្យបណ្តឹង
  - -ផ្នែកទី៣ ៖ ការពិនិត្យពាក្យបណ្តឹង
  - -ផ្នែកទី៤ ៖ ការបែងចែករឿងក្តី
- ជំពូកទី២ ៖ **នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ដែលបែងចែកជាបី (០៣) ផ្នែកគឺ ៖
  - -ផ្នែកទី១ ៖ សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
  - -ផ្នែកទី២ ៖ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
  - -ផ្នែកទី៣ ៖ កាបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- ជំពូកទី៣ ៖ **នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** ដែលបែងចែកជាបី (០៣) ផ្នែកគឺ ៖
  - -ផ្នែកទី១ ៖ សញ្ញាណទូទៅនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
  - -ផ្នែកទី២ ៖ ដំណើរការនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
  - -ផ្នែកទី៣ ៖ ការបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
- ជំពូកទី៤ ៖ **ការប្រកាសសាលក្រម** ដែលបែងចែកជាបី (០៣) ផ្នែកគឺ ៖
  - -ផ្នែកទី១ ៖ សញ្ញាណទូទៅនៃសាលក្រម
  - -ផ្នែកទី២ ៖ ដំណើរការនៃការប្រកាសសាលក្រម
  - -ផ្នែកទី៣ ៖ អានុភាពនៃសាលក្រម។

# ជំពូកទី១
# ការដាក់ពាក្យបណ្តឹង

នៅក្នុងជំពូកទី១នេះ យើងខ្ញុំសុំធ្វើការសិក្សាទៅលើរបៀបនៃការដាក់ពាក្យបណ្តឹង ការទទួលពាក្យបណ្តឹង ការពិនិត្យពាក្យបណ្តឹង និងការបែងចែករឿងក្តី។

## ផ្នែកទី១. របៀបដាក់ពាក្យបណ្តឹង

នីតិវិធីរដ្ឋប្បវេណីនៅតុលាការត្រូវចាប់ផ្តើមនៅពេលដែលមានការដាក់ពាក្យបណ្តឹង។ ពាក្យបណ្តឹងដែលបានចាត់ទុកថាបានដាក់នៅពេលដែលដើមចោទនោះបានដាក់ពាក្យបណ្តឹងនោះនៅតុលាការ ហើយត្រូវបានបុគ្គលិកផ្នែករដ្ឋបាលទទួលពាក្យបណ្តឹងរដ្ឋប្បវេណី បោះត្រា និងចុះលេខចូលថាបានទទួល។

"បណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតុលាការ[1]" លើកលែងតែមានបញ្ញត្តិផ្សេង ដែលច្បាប់អនុញ្ញាតឲ្យធ្វើដោយផ្ទាល់មាត់ ជាក់ស្តែងក្នុងមាត្រា២២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ អនុញ្ញាតឲ្យធ្វើបណ្តឹងដោយផ្ទាល់មាត់ក្នុងករណីដែលបណ្តឹងនៃរឿងក្តីដែលមានចំនួនទឹកប្រាក់[2]។

បានន័យថា ជាគោលការណ៍ ការដាក់ពាក្យបណ្តឹងត្រូវធ្វើឡើងដោយដើមចោទទៅតុលាការដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ស្របតាមបញ្ញត្តិនៃមាត្រា ៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែរឿងក្តីដែលមានចំនួនទឹកប្រាក់តិច គឺអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់បាន។ ការប្តឹង គឺជាសកម្មភាពមួយដែលទាមទារឱ្យបំពេញនូវលក្ខខណ្ឌជាក់លាក់មួយជាកំណត់ ដោយការប្រគល់ពាក្យបណ្តឹង ដែលភ្ជាប់លក្ខខណ្ឌទម្រង់ ដើម្បីឱ្យមានភាពច្បាស់លាស់នូវអង្គហេតុនៃការធ្វើបណ្តឹងទៅតាមនីតិវិធី។

### កថាភាគទី១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹង

#### ១. អត្តសញ្ញាណរបស់ភាគី

ពាក្យបណ្តឹងត្រូវសរសេរឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីឲ្យបានច្បាស់លាស់។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីឲ្យបានច្បាស់លាស់ គឺជាការចាំបាច់សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់ភាគី ព្រមទាំងសម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹង និងឯកសារផ្សេងៗទៅភាគីចុងចម្លើយ[3]។

ចំពោះដើមចោទជាអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកតំណាងឲ្យដូចជា នីតិបុគ្គល អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅជាដើម) ពាក្យបណ្តឹងត្រូវសរសេរបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់នោះ។

---

[1] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថាខណ្ឌទី១ និងមាត្រា៧៩

[2] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២២៤ កថាខណ្ឌទី១

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក

ចំពោះអ្នកតំណាងដោយអាណត្តិឲ្យដើមចោទ[4] (ដូចជាមេធាវីជាដើម) ពាក្យបណ្ដឹងត្រូវសរសេរបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះ។

## ២. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ[5] យោងតាមចំណុចនេះ អាចបញ្ជាក់នូវការទាមទារតាមផ្លូវបណ្ដឹងបាន។

ការទាមទារតាមផ្លូវបណ្ដឹង គឺជាកម្មវត្ថុដែលតុលាការត្រូវធ្វើការជំនុំជម្រះ និងវិនិច្ឆ័យ។ ចំពោះតុលាការចេញជាសាលក្រមនូវអ្វីដែលជាការទាមទាររបស់ភាគីដែលបានស្នើសុំ ដោយឡែកតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានស្នើសុំឡើយ ប៉ុន្តែតុលាការត្រូវចេញសេចក្ដីសម្រេចអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ទោះបីជាគ្មានការស្នើសុំរបស់ភាគីក៏ដោយ[6]។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺការសម្រេចសេចក្ដីអំពីអត្ថន័យនៃសាល-ក្រមដែលដើមចោទចង់ឲ្យតុលាការចេញដូចក្នុងពាក្យបណ្ដឹងរបស់ខ្លួន។ ការសរសេរពីខ្លឹមសារសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ នៅក្នុងពាក្យបណ្ដឹងមានការខុសប្លែកគ្នាទៅតាមប្រភេទនៃបណ្ដឹង ដែលរួមមានបីប្រភេទដូចជា[7]៖

( * * ) **បណ្ដឹងទារទារឲ្យផ្ដល់តាវកាលិក**

បណ្ដឹងទារទារឲ្យផ្ដល់តាវកាលិក គឺបណ្ដឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារតាវកាលិកកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្ដឹង ហើយទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្ដល់តាវការលិកមួយ ដោយផ្អែកលើសិទ្ធិនោះ។

( * * ) **បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**

បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្ដឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាការទាមទារតាមផ្លូវបណ្ដឹង ហើយទាមទារឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មី ប្ដូរ ឬរំលត់នូវទំនាក់ទំនងគតិយុត្តដោយផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ។

[4] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៣

[5] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថាខណ្ឌទី២ ចំណុចខ

[6] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៣

[7] មើលសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ទំព័រទី៤៤

( ** ) **បណ្ដឹងទាមទារឲ្យបញ្ជាក់**

បណ្ដឹងទាមទារឲ្យបញ្ជាក់ គឺបណ្ដឹងដែលដើមចោទអះអាងនូវអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទំនងគតិយុត្ត កំណត់មួយ ហើយទាមទារឲ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទំនងគតិយុត្ត នោះ។ បណ្ដឹងទាមទារឲ្យបញ្ជាក់នេះ ការសរសេរខ្លឹមសារនៃពាក្យបណ្ដឹងដែលដើមចោទទាមទារឱ្យតុលាការ ចេញសាលក្រមនៅក្នុងបណ្ដឹង (ក) និង (ខ) ខាងលើ ការសរសេរខ្លឹមសារនៃបណ្ដឹងនេះ (បណ្ដឹងទាមទារ ឲ្យបញ្ជាក់) ដើមចោទគ្រាន់តែបង្ហាញនូវអង្គហេតុដែលចាំបាច់ដើម្បីបញ្ជាក់នូវការទាមទាររួចជាការស្រេច។

សរុបសេចក្ដីមក នៅក្នុងការសរសេរពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញចាំបាច់ ត្រូវបញ្ជាក់ខ្លឹមសារដែលខ្លួនទាមទារឲ្យច្បាប់លាស់ ព្រោះងាយស្រួលដល់ចៅក្រមចេញសាលក្រមតាមចំណុច ដែលខ្លួនទាមទារឲ្យតុលាការចេញសាលក្រម។

**៣. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ**

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាអង្គហេតុដែលដើមចោទត្រូវសរសេរឲ្យបានច្បាស់លាស់ ចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្ដឹង។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារសំដៅទៅលើ អង្គហេតុ ដែលអាចធ្វើការសម្គាល់កុំឲ្យមានការភាន់ច្រឡំ និងទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទ និងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដទៃទៀត។ មូលហេតុចាំបាច់ត្រូវសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការ ទាមទារក្នុងពាក្យបណ្ដឹង គឺដើម្បីកុំឲ្យមានការភាន់ច្រឡំ ឬមានការបែងចែកមិនច្បាស់លាស់នូវការទាមទារដែល ជាកម្មវត្ថុនៃការជំនុំជម្រះ និងសម្រេចសេចក្ដី ទៅនឹងការទាមទាររបស់ដើមចោទ។

តាមរយៈការបញ្ជាក់ទាំងនេះ គឺបានច្បាស់លាស់នូវកម្មវត្ថុនៃសិទ្ធិ ប្រភេទ និងខ្លឹមសារនៃសិទ្ធិ ព្រមទាំងមូល- ហេតុនៃការកកើតសិទ្ធិ គឺអាចបញ្ជាក់ឲ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្ដឹងរបស់ដើមចោទបាន។

**កថាភាគទី២. ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្ដឹង**

**១. អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជា សិទ្ធិទាមទារតាមផ្លូវបណ្ដឹង។ ម្យ៉ាងវិញទៀតអង្គហេតុនេះ ដើមចោទត្រូវសរសេរបំភ្លឺឲ្យបានច្បាស់លាស់អំពីការ អះអាងនៃការទាមទារ។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ ធ្វើឡើងដើម្បីបង្ហាញអំពីអត្ថិភាពនៃការទាមទារតាមផ្លូវបណ្ដឹង របស់ដើមចោទ។

**២. អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង**

ដើមចោទគប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ អង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ និងភស្តុតាង។ អង្គហេតុដែលពាក់ព័ន្ធមានដូចជាអង្គហេតុប្រយោល ដែលជាអង្គហេតុទាំងឡាយណាដែលធ្វើឲ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុចម្បង។

វិធីដើម្បីធ្វើការបញ្ជាក់ភស្តុតាងនៃអង្គហេតុមានពីរវិធី ៖

វិធីទី១ : ការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុនោះ ដោយភស្តុតាងផ្ទាល់។

វិធីទី២ : ការទទួលស្គាល់អង្គហេតុប្រយោល តាមរយៈភស្តុតាងប្រយោល ហើយទទួលស្គាល់នូវអង្គហេតុនោះដោយអង្គហេតុប្រយោលដែលបានបញ្ជាក់នេះ ដូច្នេះការបញ្ជាក់ភស្តុតាងនៃអង្គហេតុ គឺជាការសន្និដ្ឋាននូវអង្គហេតុនោះតាមរយៈអង្គហេតុប្រយោល។ ប៉ុន្តែ ភស្តុតាងប្រយោលនេះតុលាការភាគតិចណាស់ទទួលស្គាល់ភស្តុតាងនេះ បើភាគីមិនមានភស្តុតាងផ្ទាល់ខ្លះៗភ្ជាប់ជាមួយ។

ប្រសិនបើមានកង្វះខាតនូវភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់នូវអង្គហេតុចម្បង ដើមចោទគប្បីសរសេរក្នុងពាក្យបណ្តឹងនូវអង្គហេតុប្រយោលឲ្យបានច្រើន។ ផ្ទុយមកវិញ ប្រសិនបើមានភស្តុតាងផ្ទាល់ច្បាស់លាស់ហើយមិនចាំបាច់សរសេរអង្គហេតុប្រយោលក៏បានដែរ[៩]។

## ផ្នែកទី២. ការទទួលពាក្យបណ្តឹង

### កថាភាគទី១. នីតិវិធីនៃការទទួលពាក្យបណ្តឹង

នៅពេលដែលមានការដាក់ពាក្យបណ្តឹងនៅតុលាការ ដាក់ស្តែងដែលអនុវត្តប្រចាំថ្ងៃនៅតាមសាលាជម្រះក្តីអ្នកមានភារៈទទួលពាក្យបណ្តឹងអនុវត្តតាមជំហានដូចខាងក្រោម ៖

-មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្តឹងរដ្ឋប្បវេណី ជាអ្នកវាយត្រាលើពាក្យបណ្តឹងដែលបានទទួលហើយចុះកាលបរិច្ឆេទនៃការទទួល និងចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្តឹង រួមទាំងចេញបង្កាន់ដៃបង់ប្រាក់ផង។

**សំគាល់** : មុនពេលទទួលពាក្យបណ្តឹងមកធ្វើចំណាត់ការដូចខាងលើ មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យ-បណ្តឹងគួរពិនិត្យមើលលើពាក្យបណ្តឹងមួយត្រួសសិន ហើយបើមិនមានការខ្វះខាតមន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្តឹង គប្បីពន្យល់ឲ្យអ្នកដាក់ពាក្យបណ្តឹងធ្វើការកែតម្រូវពីចំណុចខ្វះខាតនោះសិន។ ចំណុចដែលមន្ត្រី

[៩] មើលសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ឆ្នាំ២០០៨ ទំព័រទី៤០ និង៦៦

រដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្ដឹង គប្បីពន្យល់ដល់អ្នកដាក់ពាក្យអំពីការសរសេរបណ្ដឹងត្រឹមត្រូវតាមមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- មន្ត្រីរដ្ឋបាលនោះ ត្រូវបញ្ជូនពាក្យបណ្ដឹងទៅឲ្យប្រធានតុលាការ។

- ប្រធានតុលាការចារឈ្មោះចៅក្រម ទទួលបន្ទុកតាមលំដាប់បន្ទាប់ដែលបានកំណត់ លើសាមីនៃពាក្យបណ្ដឹងនោះ ហើយមន្ត្រីរដ្ឋបាលនោះ ត្រូវយកសាមីនៃពាក្យបណ្ដឹងនោះ ទៅឲ្យក្រឡាបញ្ជីនៃចៅក្រមទទួលបន្ទុកនោះ។

- ក្រឡាបញ្ជីនៃចៅក្រមដែលទទួលបន្ទុក ត្រូវទទួលសាមីនៃពាក្យបណ្ដឹងនោះ ហើយយកទៅឲ្យចៅក្រមទទួលបន្ទុកនោះ និងចៅក្រមនោះត្រូវចារឈ្មោះក្រឡាបញ្ជីណាជាអ្នកកាន់ពាក្យបណ្ដឹងនោះ។

- ក្រឡាបញ្ជីដែលទទួលបន្ទុករឿងក្ដីដែលចៅក្រមចាត់ឲ្យ ត្រូវយកសាមីពាក្យបណ្ដឹងចុះក្នុងសៀវភៅទទួលពាក្យបណ្ដឹងរបស់ខ្លួន។

**កថាភាគទី២. ឯកសារភ្ជាប់ជាមួយពាក្យបណ្ដឹង**

ការដាក់ពាក្យបណ្ដឹង ត្រូវមានឯកសារភ្ជាប់មកជាមួយពាក្យបណ្ដឹង ដោយឯកសារដែលភ្ជាប់មកជាមួយ គឺបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងបណ្ដឹង។

ដោយយោងតាមមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺទាក់ទងទៅនឹងអ្នកដាក់ពាក្យ ហើយអ្នកដាក់ពាក្យបណ្ដឹងមានច្រើនប្រភេទដូចជា ភាគី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងនៃនីតិបុគ្គល និងអ្នកតំណាងដោយអាណត្តិ។ ដូច្នេះប្រសិនបើអ្នកតំណាងទាំងនោះ ត្រូវបានម្ចាស់បណ្ដឹងប្រគល់សិទ្ធិឲ្យ ដូចនេះត្រូវតែមានលិខិតបញ្ជាក់សិទ្ធិតំណាងនោះ ហើយសិទ្ធិតំណាងនោះមានខាងក្រោម ៖

- បើជាអ្នកតំណាងដែលច្បាប់បានកំណត់ដូចជា ឪពុកម្ដាយ តំណាងឲ្យកូនជាអនីតិជន ឬអ្នកអាណាព្យាបាល គឺលិខិតបញ្ជាក់សិទ្ធិនោះ ត្រូវបានបញ្ជាក់ដោយជាលាយលក្ខណ៍អក្សរ[9]។ បើជាឪពុកម្ដាយ លិខិតបញ្ជាក់នោះអាចជាសំបុត្រកំណើតរបស់កូន សៀវភៅគ្រួសារ សៀវភៅស្នាក់នៅជាដើម។ បើជាអាណាព្យាបាល លិខិតបញ្ជាក់សិទ្ធិតំណាង គឺជាសេចក្ដីសម្រេចរបស់តុលាការ។

- បើជាអ្នកតំណាងនៃនីតិបុគ្គល ត្រូវអនុវត្តដូចអ្នកតំណាងដែលច្បាប់បានកំណត់[10] គឺលិខិតបញ្ជាក់សិទ្ធិនោះ ត្រូវធ្វើដោយជាលាយលក្ខណ៍អក្សរ[11]។

[9] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣៥ កថាខណ្ឌទី៣

[10] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣៨

[11] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣៥ កថាខណ្ឌទី៣

- អ្នកតំណាងដោយអាណត្តិ ត្រូវមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ និងលិខិតតំណាងដោយអាណត្តិ[12]។

ម្យ៉ាងវិញទៀត ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើ ក៏មានឯកសារភ្ជាប់ជាមួយពាក្យបណ្តឹងផងដែរ ដូចជា ឯកសារភស្តុតាង (ឯកសារថតចម្លងពីច្បាប់ដើម) សម្រាប់ធ្វើការទាមទារ និងឯកសារពាក់ព័ន្ធផ្សេងទៀត (ឯកសារថតចម្លង)។

**កថាភាគទី៣. ពន្ធដាក់ពាក្យបណ្តឹង និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ**

**១. ពន្ធដាក់ពាក្យបណ្តឹង**

នៅពេលដាក់ពាក្យបណ្តឹងទៅតុលាការ ដើមចោទត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងដោយគណនាទៅតាមតម្លៃនៃកម្មវត្ថុបណ្តឹង។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដល់ ១០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០ រៀល ត្រូវបង់ ១.០០០ រៀល។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០.០០០.០០០ រៀល ដល់ ១០០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០ រៀល ត្រូវបង់ ៧០០ រៀល។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០០.០០០.០០០ រៀល ដល់ ១.០០០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០ រៀលត្រូវបង់ ៣.០០ រៀល។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងលើស ១.០០០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០ រៀល ត្រូវបង់ ១០០ រៀល។ ចំពោះការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបង់ ១,៥ ដង រីឯចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខវិញ ត្រូវបង់ ២ដង នៃថ្លៃពន្ធដែលបានគណនាក្នុងកថាខណ្ឌទី១ និងទី២ នេះទៅតុលាការ។ ចំពោះការដាក់បណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវបង់ ១០.០០០ រៀលទៅតុលាការ។ ចំពោះការដាក់ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធ១ភាគ២ នៃប្រាក់ដោយគណនារួច ទៅតាមតម្លៃកម្មនៃការទាមទារ។ ការដែលបង់ពន្ធលើស សងពន្ធដែលបានបង់លើសទៅវិញ ក្នុងករណីដែលមានការផ្សះផ្សារបានលទ្ធផលមុនពេលការទាញហេតុផលដោយផ្ទាល់មាត់។ ករណីដកបណ្តឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ករណីដែលសេចក្តីសម្រេចលើកចោលពាក្យបណ្តឹងដោយមិនបានឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ចូលជាស្ថាពរ គឺសងពាក់កណ្តាលនៃពន្ធដែលបានបង់ហើយទៅឲ្យដើមចោទវិញ[13]។

**២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ**

បន្ទាប់ពីពន្ធដាក់ពាក្យបណ្តឹង ដើមចោទក៏ត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ។ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធមានដូចជា ប្រាក់ចាំបាច់ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង និងឯកសារ ឬសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី និងសោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ ដែលចាំបាច់សម្រាប់ចៅក្រម និង

[12] មើលច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មាត្រា២២ និងមាត្រា៣ និងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤៥ និង៥២

[13] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៦១

ក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅតុលាការ។ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ តុលាការត្រូវបង្គាប់ឲ្យភាគី ឬបុគ្គលដែលទាក់ទងរឿងក្តីបង់ចំនួនប្រាក់ជាមុនសិន[14]។ ប៉ុន្តែនៅពេលដាក់ពាក្យបណ្តឹង ដើមចោទត្រូវតម្រូវឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធមួយចំនួនជាមុនសម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹង ឯកសារផ្សេងៗ ដីកាកោះ និងសោហ៊ុយផ្សេងទៀតដែលចាំបាច់ ហើយដែលអាចប៉ាន់ប្រមាណបានចំនួនទឹកប្រាក់នឹងត្រូវបានកំណត់តាមសភាពជាក់ស្តែង។ ប្រសិនបើ ដើមចោទពុំបានបង់នូវប្រាក់សម្រាប់បញ្ជូនពាក្យបណ្តឹងទុកជាមុនទេ តុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច[15]។ ម្យ៉ាងវិញទៀត ប្រសិនបើដើមចោទ មិនព្រមបង់ប្រាក់ចាំបាច់សម្រាប់ការកោះហៅភាគីឲ្យចូលឆ្លើយមកតាមកាលបរិច្ឆេទតាមការបង្គាប់របស់តុលាការទេ តុលាការអាចលើកបណ្តឹងចោល ដោយដីកាសម្រេច ប្រសិនបើចុងចម្លើយគ្មានការតវ៉ា[16]។

## ផ្នែកទី៣. ការពិនិត្យពាក្យបណ្តឹង

### កថាភាគទី១. របៀបពិនិត្យពាក្យបណ្តឹង

ក្រោយពីរឿងក្តីត្រូវបញ្ជូនមកចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមរួចហើយ ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមត្រូវធ្វើការពិនិត្យពាក្យបណ្តឹង។ ក្នុងការពិនិត្យពាក្យបណ្តឹងស្តែងឡើងតាមលក្ខណៈពីរប្រភេទដូចតទៅ ៖

-ទី១៖ ការពិនិត្យពាក្យបណ្តឹងចៅក្រមម្នាក់ ឬចៅក្រមជំនុំជម្រះនៃចៅក្រមអាចចេញដីកាបង្គាប់ឲ្យកែតម្រូវ និងចេញដីកាសម្រេចលើកពាក្យបណ្តឹងចោល បើចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមពិនិត្យឃើញថា ការសរសេរក្នុងពាក្យបណ្តឹងមិនទាន់គ្រប់គ្រាន់នៅឡើយ ដោយផ្អែកតាមមាត្រា៧៥ កថាខណ្ឌទី២ នៃក្រម-នីតិវិធីរដ្ឋប្បវេណី និងដើមចោទបានបង់ពន្ធដាក់ពាក្យបណ្តឹងហើយ ឬនៅ។

-ទី២៖ ការពិនិត្យពាក្យបណ្តឹង គឺដើម្បីធ្វើឲ្យនីតិវិធីរឿងក្តីឲ្យបានឆាប់រហ័ស ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ត្រូវពិនិត្យមើលទៅលើអង្គហេតុនៃការទាមទារ និងអង្គហេតុសំខាន់ដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងសំខាន់ៗ ជាអាទិ៍ មានសរសេរ និងភ្ជាប់ជាមួយពាក្យបណ្តឹង។ ការពិនិត្យត្រង់ចំណុចនេះ មានគោលបំណងចាត់ការរឿងក្តីឲ្យមានប្រសិទ្ធភាពដែលធ្វើឲ្យមានលក្ខណៈងាយស្រួលដល់ការរៀបចំចំណុចវិវាទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ។ ការពិនិត្យពាក្យបណ្តឹងក្នុងចំណុចនេះ ទោះជាដើមចោទមិនព្រមកែតម្រូវក៏ដោយនូវចំណុចដែលគប្បីសរសេរ (មាត្រា ៧៥ កថា-

[14] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៦២

[15] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ កថាខណ្ឌទី២

[16] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨២ កថាខណ្ឌទី១

ខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក៏ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមមិនអាចលើកពាក្យបណ្តឹងចោលបានទេ។ ផ្ទុយមកវិញចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ត្រូវតែកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយត្រូវទាមទារឲ្យដើមចោទពន្យល់បន្ថែមក្នុងកាលបរិច្ឆេទនោះប៉ុណ្ណោះ។

**កថាភាគទី២. ដីកាបង្គាប់ឲ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល**

តាមបញ្ញត្តិមាត្រា ៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឲ្យកែ-តម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះ។

តាមបញ្ញត្តិមាត្រា៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះតាមដីកាសម្រេចបង្គាប់ឲ្យកែតម្រូវទេ តុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។ ចំពោះដីកាសម្រេចនេះ ដើមចោទអាចប្តឹងជំទាស់បាន[17]។

## ផ្នែកទី៤. ការបែងចែករឿងក្តី

**កថាភាគទី១. ការបែងចែករឿងក្តីតាមលំដាប់ដែលបានកំណត់**

នៅតាមតុលាការ ការបែងចែករឿងក្តី និងលំដាប់សម្រាប់ជំនួស ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈត្រូវកំណត់ជាមុននៅរៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ[18]។ ដោយសារមានដីកាសម្រេចនេះ ចៅក្រមម្នាក់ ឬចៅក្រមប្រឹក្សាជំនុំជម្រះទទួលបន្ទុកស្វ័យប្រវត្តិ ដើម្បីដោះស្រាយរឿងក្តីណាមួយតាមលំដាប់សម្រាប់ចៅក្រមម្នាក់ និងលំដាប់សម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ។

**កថាភាគទី២. ការបែងចែករឿងក្តីទៅឲ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

ចៅក្រមម្នាក់ ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ជំនុំជម្រះរឿងក្តីមួយ អាស្រ័យទៅតាមប្រភេទនៃរឿងក្តី ដែលច្បាប់កំណត់ ឬភាពស្មុគស្មាញនៃរឿងក្តី ដែលទទួលស្គាល់ដោយតុលាការ។ ការបែងចែករឿងក្តីទៅឲ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមមានដូចក្រោម៖

-ប្រសិនបើជារឿងក្តីដែលច្បាប់បានកំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម រឿងក្តីនោះត្រូវបែងចែកទៅឲ្យក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសមាសភាពចៅក្រមចំនួនបីរូប ដោយធ្វើតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ[19]។ រឿងក្តីដែលមានកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនតិចជាងប្រាំលានរៀល ហើយដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យ និងជម្រះដោយក្រុមប្រឹក្សា

[17] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ កថាខណ្ឌទី៣

[18] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៦

[19] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៣ កថាខណ្ឌទី៣

ជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និងបញ្ហាផ្សេងទៀត[20]។ ក្នុងករណីនេះ ការសម្រេចថាតើរឿងក្តីនោះត្រូវវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមម្នាក់ ត្រូវតាមដីកាសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ[21]។

-គ្រប់រឿងក្តីទាំងអស់លើកលែងតែចំណុច (ក) ខាងលើ ត្រូវធ្វើការបែងចែកទៅឲ្យចៅក្រមម្នាក់ដោយត្រូវធ្វើទៅតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ចៅក្រមម្នាក់[22]។

[20] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៣ កថាខណ្ឌទី២

[21] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៣ កថាខណ្ឌទី៤

[22] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៣ កថាខណ្ឌទី១

# ជំពូកទី២
# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងជំពូកទី២នេះ គឺបង្ហាញអំពីទ្រឹស្ដីគតិយុត្តនានាស្ដីអំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ដើម្បីយល់ច្បាស់អំពីប្រធានបទនេះ ត្រូវសិក្សាលើចំណុចជាច្រើនបន្តបន្ទាប់ដូចជា សញ្ញាណនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលសិក្សាអំពីអត្ថន័យ និងគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ-ផល ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការកោះហៅភាគី ការបញ្ជូនដីកាកោះហៅ និងការបំបែក ឬបញ្ចូលរឿងក្ដីជាអាទិ៍។ ចំពោះចំណុចបន្ទាប់គឺសិក្សាលើដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមាននីតិវិធីផ្សះផ្សា ការរៀបចំការអះអាង ភស្តុតាង និងការកំណត់ចំណុចវិវាទ ជាពិសេសក៏មានការបកស្រាយអំពីទម្រង់ និងខ្លឹមសារនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ។ ចំណុចចុងក្រោយនៃជំពូកទី២នេះ គឺនឹងធ្វើការបកស្រាយពាក់ព័ន្ធទៅនឹងការបញ្ចប់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

## ផ្នែកទី១. សញ្ញាណនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### កថាភាគទី១. អត្ថន័យ និងគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

#### ១. អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីសំខាន់មួយ ក្នុងគោលដៅត្រៀមរៀបចំធ្វើយ៉ាងណាឲ្យការទាញហេតុផលដោយផ្ទាល់មាត់ធ្វើឡើងឲ្យមានភាពឆាប់រហ័ស កាត់បន្ថយភាពស្មុគស្មាញ និងមានភាពងាយស្រួលក្នុងការស្វែងរកការពិត។ ពោលគឺនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកំពស់ និងសម្រួលដល់ការជម្រះក្ដីនៅក្នុងការទាញហេតុផលផ្ទាល់មាត់។

#### ២. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានគោលបំណងចំនួន ០៣(បី) សំខាន់គឺ ដើម្បីធ្វើការបំភ្លឺអំពីចំណុចវិវាទរវាងភាគី រៀបចំនូវសេចក្ដីអះអាងរបស់គូភាគី និងរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវធ្វើការពិនិត្យ[23] នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំគិតថាអង្គហេតុទាំងនោះ មាន ឬគ្មានសារៈសំខាន់ចំពោះរឿងក្ដី

[23] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៣

នោះទេ។ នៅក្នុងពេលជាមួយគ្នា ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណា ដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ក៏ប៉ុន្តែ ការធ្វើបែបនេះនឹងនាំឲ្យការជម្រះក្ដីមានភាពស្មុគស្មាញ និងអូសបន្លាយដោយឥតប្រយោជន៍ និងធ្វើឲ្យមានការលំបាកក្នុងការស្វែងរកការពិត។ ហេតុដូច្នេះហើយ មុននឹងចាប់ផ្ដើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំសេចក្ដីអះអាងរបស់ភាគី និងត្រូវបំភ្លឺនូវចំណុចវិវាទ តាមវិធីសាស្ត្រដូចតទៅ[24]៖

-ទី១៖ស្នើឲ្យភាគីដកការអះអាងអំពីអង្គហេតុ ដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្ដឹង និងផាត់ចោលនូវអង្គហេតុទាំងឡាយណាដែលភាគីធ្វើការអះអាងដូចគ្នាចំពោះចំណុចជាសារវ័ន្តនៃការពិនិត្យភស្តុតាង ដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ។

-ទី២៖ចំពោះភស្តុតាងដែលត្រូវពិនិត្យទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានាឲ្យបាននូវការពិនិត្យដោយសមូហវិធី ដោយត្រូវយកចិត្តទុកដាក់តែទៅលើភស្តុតាងដែលសំខាន់ និងមានតម្លៃតែប៉ុណ្ណោះ។

ហេតដូច្នេះហើយបានជាមុនពេលធ្វើនីតិវិធីជំនុំជម្រះក្ដីដោយការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន។

### កថាភាគទី២. កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

#### ១. ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលត្រូវធ្វើឡើង នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន[25]។ ការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងមានវត្តមាននេះ គឺជាគោលការណ៍ចំពោះមុខដែលស្របទៅនឹងគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ បានន័យថា ភាគីណាក៏មិនអាចត្រូវបានតុលាការដំណើរការនីតិវិធីដោយមិនបានធ្វើការកោះហៅ ឬធ្វើការសាកសួរនោះឡើយ។ ដូច្នេះតុលាការមិនអាចធ្វើការកោះហៅភាគីណាតែម្ខាង ហើយស្ដាប់ការអះអាងរបស់ភាគីម្ខាងនោះ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀតបានឡើយ ព្រោះអាចធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្តរបស់ភាគីម្ខាងទៀត ចំពោះប្រព័ន្ធតុលាការ ហើយនេះគឺជាការផ្ទុយនឹងគោលការណ៍ចំពោះមុខ។ មានន័យថា តុលាការត្រូវធ្វើការកោះហៅគូភាគីទាំងសងខាងឲ្យចូលរួមមកធ្វើការអះអាងតទល់ចំពោះគ្នាទៅវិញទៅមក នៅចំពោះមុខតុលាការ។

[24] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្ដឹង, ទំព័រទី៧៤

[25] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៥ កថាខណ្ឌទី១

តុលាការ ត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់[26]។ ដោយគោរពតាមគោលការណ៍ចំពោះមុខ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលគូភាគីទាំងសងខាង មានវត្តមានបាន ពោលគឺធ្វើនៅចំពោះមុខភាគីទាំងសងខាង[27] ។

### ២. ការបញ្ជូនពាក្យបណ្ដឹង និងការកោះហៅគូភាគី

នៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគី[28]។ បានន័យថាបន្ទាប់ពីពាក្យបណ្ដឹងត្រូវបានដាក់ ហើយ តុលាការបានពិនិត្យពីភាពត្រឹមត្រូវនៃបណ្ដឹងហើយ តុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ពេលកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួច តុលាការត្រូវធ្វើការកោះហៅគូភាគីទាំងសងខាងព្រមទាំងត្រូវបញ្ជូនពាក្យបណ្ដឹង និងឯកសារពាក់ព័ន្ធនឹងសំណុំរឿងទៅចុងចម្លើយ។ ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា ចំពោះពាក្យបណ្ដឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់[29]។

### ៣. នីតិវិធីនៃការបញ្ជូន

ពាក់ព័ន្ធនឹងការបញ្ជូន នេះគឺមានមន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន។ ចំពោះមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន គឺក្រឡាបញ្ជី ហើយមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន គឺមានដូចជា បុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី[30]។

ការបញ្ជូនលិខិតឯកសារផ្សេងៗ ក៏ដូចជាការបញ្ជូនដីកាកោះហៅគូភាគីឲ្យចូលក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចធ្វើបានទៅតាមវិធីដូចជា ៖

-ការបញ្ជូនដោយប្រគល់

-ការបញ្ជូនដោយជួបប្រទះ

-ការបញ្ជូនដោយបង្គ្រប់កិច្ច

-ការបញ្ជូនដោយទុកចោល

[26] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨០ កថាខណ្ឌទី២

[27] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៥ កថាខណ្ឌទី១

[28] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៨០ កថាខណ្ឌទី១

[29] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៩ កថាខណ្ឌទី១

[30] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤៦ កថាខណ្ឌទី២ និងទី៣

-ការបញ្ជូននៅបរទេស

-ការបញ្ជូនតាមការផ្សាយជាសាធារណៈ។

*ការបញ្ជូនដោយប្រគល់៖ ការបញ្ជូនដោយប្រគល់ សំដៅលើការប្រគល់ឯកសារទៅឲ្យជនដែលត្រូវទទួលការបញ្ជូន។ ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ[31]។ ការបញ្ជូនដោយប្រគល់គឺត្រូវធ្វើនៅកន្លែងដែលជាលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន។

*ការបញ្ជូនដោយជួបប្រទះ[32]៖ ការបញ្ជូនដោយប្រគល់ សំដៅលើការប្រគល់ឯកសារទៅឲ្យជនដែលត្រូវទទួលការបញ្ជូន នៅកន្លែងដែលជួបប្រទះអ្នកដែលត្រូវទទួលការបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូននោះ ពុំច្បាស់លាស់ថា មានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ។ ប៉ុន្តែក្នុងករណីដែលភាគីបានជូនដំណឹងអំពីកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឬកន្លែងដែលត្រូវធ្វើការបញ្ជូនចំពោះអ្នកដែលត្រូវទទួលការបញ្ជូននោះ និងករណីដែលមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនអាចធ្វើការបញ្ជូនតាមការជួបប្រទះបានឡើយ ប៉ុន្តែអាចធ្វើការបញ្ជូនតាមវិធីបញ្ជូនដោយការជួបប្រទះបាន ក្នុងករណីអ្នកដែលបានជូនដំណឹងមិនប្រកែកទទួលការបញ្ជូន។

*ការបញ្ជូនដោយបង្គ្រប់កិច្ច៖ ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូន នៅទីកន្លែងដែលត្រូវបញ្ជូនទេ មន្ត្រីទទួលបន្ទុកការបញ្ជូន អាចប្រគល់ឯកសារទៅឲ្យអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬអ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន[33]។

*ការបញ្ជូនដោយទុកចោល៖ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមការបញ្ជូនដោយបង្គ្រប់កិច្ចខាងលើ មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ឯកសារនោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន[34]។

*ការបញ្ជូនដែលត្រូវធ្វើនៅបរទេស៖ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬឯកអគ្គរាជទូត ឬភារធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះឲ្យធ្វើបាន[35]។

[31] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៧ ចំណុចទី២

[32] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥១

[33] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥២ ចំណុចទី១

[34] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥២ ចំណុចទី២

[35] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៥៣ ចំណុចទី១

*__ការបញ្ជូនតាមការផ្សាយជាសាធារណៈ៖__ ដោយមានពាក្យសុំ ឬទទួលការអនុញ្ញាតពីតុលាការ ក្រឡាបញ្ជី អាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈក្នុងករណីដូចជា[36] ៖

-ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬកន្លែងផ្សេងទៀតដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញ។

-មិនអាចបញ្ជូន តាមការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល

-មិនអាចធ្វើការបញ្ជូនតាមការធ្វើនៅបរទេស

-បានធ្វើការបញ្ជូនទៅបរទេស ដោយបានធ្វើការបញ្ជូនដោយប្រគល់ឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសឲ្យធ្វើការបញ្ជូនរួចហើយ តែមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះ ក្នុងអំឡុងពេល០៦ (ប្រាំមួយ) ខែ ចាប់តាំងពីពេលបញ្ជូននោះ។

**__របៀបនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ៖__[37]

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ។ ក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលត្រូវបញ្ជូន និងអាចប្រគល់ឯកសារនោះទៅជនដែលត្រូវទទួលការបញ្ជូន នៅពេលណាក៏បាន។ ប៉ុន្តែចំពោះការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈវិញ ត្រូវបិទដីកាកោះនោះ នៅកន្លែងសម្រាប់បិទប្រកាស។ នៅក្នុងករណីដែលធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ការបិទប្រកាសនេះអាចធ្វើនៅកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ ក្រៅពីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការបាន។ តុលាការអាចចុះនៅក្នុងរាជកិច្ច ឬក្នុងសារពត៌មាន ផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីតុលាការអាចជូនដំណឹងថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ ជំនួសការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬក្នុងសារព័ត៌មាន។

ទោះជាយ៉ាងណាក្តីតុលាការអាចធ្វើនីតិវិធីបាន ទោះបីជាភាគីម្ខាងគ្មានវត្តមានក៏ដោយ ក្នុងករណីដែលតុលាការបានបញ្ជូនដីកាកោះ និងបានផ្តល់ឱកាសឲ្យភាគីនោះចូលបង្ហាញខ្លួនយ៉ាងត្រឹមត្រូវហើយ[38]។

**កថាភាគទី៣. ការបំបែក និងបញ្ចូលសំណុំរឿងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបំបែករឿងក្តីមួយទៅជារឿងក្តីផ្សេងៗ ហើយធ្វើការជម្រះក្តីលើរឿងក្តីទាំងនោះ ដោយដាច់ពីគ្នាបាន។

[36] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៥៥

[37] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៦

[38] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្តឹង, ទំព័រទី៧៥

តុលាការអាចបង្គាប់ឲ្យបំបែក ឬបញ្ចូលរឿងក្ដី ដោយដីកាសម្រេច ឬអាចលុបចោលដីកាសម្រេចនោះបាន[39]។ ឧទាហរណ៍ ប្រសិនបើនៅក្នុងបណ្ដឹងតែមួយ ដើមចោទបានទាមទារឲ្យចុងចម្លើយសងប្រាក់កំចីផង និងបង់ប្រាក់ថ្លៃលក់ទិញផង តុលាការអាចបំបែកការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញ ចេញពីបណ្ដឹងនោះ ហើយធ្វើការជម្រះក្ដីដាច់ដោយឡែកបាន។ បញ្ច្រាសទៅវិញ តុលាការក៏អាចរួមបញ្ចូលរឿងក្ដីផ្សេងៗ ដែលកំពុងត្រូវបានចាត់ការនៅក្នុងតុលាការតែមួយ ហើយធ្វើការជម្រះក្ដីសរុប ដោយនីតិវិធីតែមួយបានដែរ។ ទោះបីជាក្នុងករណីដែលការទាមទារពីរយ៉ាង ត្រូវបានដាក់នៅក្នុងបណ្ដឹងតែមួយក៏ដោយ ប្រសិនបើការទាមទារនីមួយៗ មានខ្លឹមសារពាក់ព័ន្ធគ្នាតែបន្តិចបន្តួច ហើយការជំនុំជម្រះលើការទាមទារមួយអាចនឹងធ្វើបានឆាប់ជាងការទាមទារមួយទៀត នោះវាជាការសមស្របដែលត្រូវបំបែករឿងក្ដី។ ម្យ៉ាងវិញទៀត ក្នុងករណីដែលរឿងក្ដីជាច្រើនដែលមានខ្លឹមសារទាក់ទងគ្នា កំពុងត្រូវបានចាត់ការដាច់ដោយឡែកពីគ្នាជាញឹកញាប់វាជារឿងសមហេតុផលក្នុងការជំនុំជម្រះរឿងក្ដីទាំងអស់នេះរួមគ្នា តាមរយៈការរួមបញ្ចូលរឿងក្ដី[40]។

ក្នុងករណីដែលតុលាការបានបង្គាប់ឲ្យបញ្ចូលរឿងក្ដីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមានឱកាសសាកសួរសាក្សី ដោយសារសាក្សីនោះត្រូវបានសាកសួររួចហើយមុនពេលបញ្ចូលរឿងក្ដី បានដាក់ពាក្យសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះ។ ការចែងបែបនេះគឺសំដៅទៅលើសិទ្ធិរបស់ភាគីដែលតុលាការអនុញ្ញាតឲ្យសាកសួរទៅលើសាក្សីដែលតុលាការបានសួររួចហើយមុនពេលបញ្ចូលរឿងក្ដីជាថ្មីម្ដងទៀត ក្នុងករណីដែលមានពាក្យសុំសាកសួរសាក្សីនោះ[41]។

## ផ្នែកទី២. ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### កថាភាគទី១. ការសាកល្បងផ្សះផ្សា

ការផ្សះផ្សា គឺជាកិច្ចមួយដែលត្រូវបានលើកទឹកចិត្តជានិច្ច នៅក្នុងប្រព័ន្ធដោះស្រាយបណ្ដឹងរដ្ឋប្បវេណី ពីព្រោះវាអាចជួយឲ្យភាគីចំណេញបានច្រើនយ៉ាង ទាំងពេលវេលា ហិរញ្ញវត្ថុ និងទំនាក់ទំនងទៅថ្ងៃក្រោយ។ ដូច្នេះ ប្រសិនបើភាគីមានឆន្ទៈបញ្ចប់វិវាទដោយការសះជានឹងគ្នា នោះនឹងក្លាយជាលទ្ធផលដែលគួរឲ្យចង់បានជាង។ ហេតុនេះហើយក្រមនីតិវិធីរដ្ឋប្បវេណីកំណត់ថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើការសាកល្បងផ្សះផ្សាជាដំបូងសិន មុននឹងចាប់ផ្ដើមនីតិវិធី លើកលែងតែក្នុងករណីដែលយល់ឃើញថាមិនសមរម្យ[42]។ ចំពោះករណីដែលយល់ថាមិនសមរម្យនេះ សំដៅទៅលើករណីដែលសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត

[39] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៩ កថាខណ្ឌទី១

[40] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្ដឹង, ទំព័រទី៨៥

[41] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៩ កថាខណ្ឌទី២

[42] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៤

ដែលដើមចោទបានទាមទារក្នុងបណ្តឹង មិនអាចឲ្យគូភាគីដោះស្រាយតាមការព្រមព្រៀងរបស់គូភាគីតែប៉ុណ្ណោះបាន ឬករណីដែលច្បាស់ថាអាកប្បកិរិយារបស់គូភាគីគ្មានបំណងនឹងស្រុះស្រួលគ្នាសោះជាដើម[43]។ សម្រាប់ករណីក្រៅពីករណីដែលយល់ថាមិនសមរម្យនេះ តុលាការគួរតែរកឱកាសធ្វើការផ្សះផ្សាទៅតាមកាលៈទេសៈជាក់ស្តែង និងគ្រប់ពេលវេលា ក្នុងអំឡុងពេលនៃនីតិវិធីត្រៀម។ ម្យ៉ាងទៀត នៅពេលកំពុងធ្វើនីតិវិធីត្រៀម បើចៅក្រមយល់ឃើញថា មានលទ្ធភាពច្រើនក្នុងការផ្សះផ្សា ចៅក្រមគួរគិតពិចារណាប្តូរគោលបំណងនៃកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល ទៅជាកាលបរិច្ឆេទនៃនីតិវិធីផ្សះផ្សាវិញ[44]។ ពាក់ព័ន្ធនឹងការផ្សះផ្សានេះ អាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើតុលាការយល់ឃើញថាសមរម្យ[45]។ ការបញ្ញត្តិដូចនេះដើម្បីមានភាពងាយស្រួល ច្បាស់លាស់ និងជួយសម្រួលដល់ភាគីដូចជាសោហ៊ុយ ពេលវេលា និងមធ្យោបាយជាដើម។ ដូចក្នុងករណីដែលចំណុចវិវាទជាការកំណត់ព្រំដី ឬវិការៈក្នុងការសង់សំណង់ ការពិភាក្សាគ្នាដើម្បីធ្វើការផ្សះផ្សា ដោយត្រួតពិនិត្យស្ថានភាពជាក់ស្តែងនៅទីកន្លែងមានភាពប្រសើរជាង។ ក្នុងករណីដែលភាគីមិនអាចមកតុលាការបានដោយសារមានជម្ងឺធ្ងន់ ការពិភាក្សាគ្នាសម្រាប់ការផ្សះផ្សាចំពោះមុខសាមីខ្លួនអាចមានលទ្ធផលល្អជាងធ្វើការផ្សះផ្សានៅតុលាការ។ ហើយបើតាមបញ្ញត្តិនៃមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន កំណត់ថាក្នុងករណីដែលបានយល់ឃើញថា ភាគីមានភាពលំបាកក្នុងការបង្ហាញខ្លួនដោយសារភាគីនោះមានលំនៅឋានឆ្ងាយ (ឆ្ងាយពីតុលាការ) ឬ ដោយសារមានមូលហេតុផ្សេងទៀត ប្រសិនបើភាគីនោះបានដាក់លិខិតដែលទទួលយល់ព្រមនូវសេចក្តីព្រាងអំពីចំណុចនៃការផ្សះផ្សាដែលត្រូវបានបង្ហាញជាមុន ដោយតុលាការ ឬដោយចៅក្រមដែលទទួលបញ្ជា ឬដោយចៅក្រមដែលទទួលការប្រគល់សិទ្ធិ ហើយភាគីម្ខាងទៀតបានបង្ហាញខ្លួននៅកាលបរិច្ឆេទសវនាការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ និងទទួលយល់ព្រមនូវសេចក្តីព្រាងអំពីចំណុចនៃការផ្សះផ្សានេះ ត្រូវចាត់ទុកថាការផ្សះផ្សាត្រូវបានសម្រេចរវាងគូភាគីទាំងសងខាង[46]។

ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ[47]។ បានន័យថា ក្នុងករណីដែលភាគីសម្រុះសម្រួលគ្នាចំពោះទំនាក់ទំនងនៃសិទ្ធិដែលជាចំណុចវិវាទ នោះភាគីអាចបញ្ចប់នីតិវិធីបណ្តឹងនៅពេលណាក៏បាន ក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយចំពោះការផ្សះផ្សាដែលទទួលបានជោគជ័យ ពោលគឺលែងមានចំណុចវិវាទ ឬករណីភាគីមានការសះជា ការលះបង់នូវការទាមទារ ឬការទទួល

---

[43] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១: នីតិវិធីបណ្តឹង, ទំព័រ៧៧

[44] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី លើមាត្រា១០៤, ទំព័រ ១០២ និង១០៣

[45] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២០ កថាខណ្ឌទី២

[46] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា ២២០, ទំព័រ ២០៤ និង២០៥

[47] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២

ស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ ហើយយើងអាចហៅកំណត់ហេតុនោះជាកំណត់ហេតុសះជា ដែលកំណត់ហេតុសះជានេះនឹងនាំឲ្យមានការបញ្ចប់នីតិវិធីបណ្ដឹង ពោលគឺមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។

ផ្ទុយទៅវិញ បើភាគីមិនព្រមផ្សះផ្សា ឬការផ្សះផ្សាមិនទទួលបានជោគជ័យទេ តុលាការនឹងបញ្ឈប់ការផ្សះផ្សា ហើយចាប់ផ្ដើមបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាធម្មតា ដោយចុះនិទ្ទេសបញ្ជាក់ពីចំណុចពុំសះជារវាងគូភាគីនេះ នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ។

## កថាភាគទី២. ការរៀបចំការអះអាង តស៊ូតាង និងការកំណត់ចំណុចវិវាទ

### ១. ការរៀបចំការអះអាង

#### ១.១. ការដាក់ឯកសារត្រៀម

ឯកសារត្រៀម គឺជាឯកសារដែលភាគីនីមួយៗ ជូនដំណឹងជាមុនទៅភាគីម្ខាងទៀត និងតុលាការអំពីចំណុចដែលខ្លួននឹងធ្វើសេចក្ដីថ្លែងការណ៍នៅកាលបរិច្ឆេទបន្ទាប់[48]។ ក្រមនីតិវិធីរដ្ឋប្បវេណី បង្កើតនូវប្រព័ន្ធឯកសារត្រៀម ដើម្បីធ្វើឲ្យមានប្រសិទ្ធិភាព និងភាពរលូនល្អ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ដូច្នេះគប្បីដាក់ឯកសារត្រៀមនាពេលកំណត់មួយ ឲ្យបានមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀម។ តុលាការអាចធ្វើការកំណត់កាលបរិច្ឆេទ ដែលត្រូវដាក់ឯកសារត្រៀមបាន[49]។ ម្យ៉ាងទៀត ឯកសារត្រៀម គឺជាឯកសារដែលតុលាការអាចបង្គាប់ឲ្យដាក់[50] ពោលគឺវាមិនមែនដាច់ខាតត្រូវតែដាក់នោះទេ គឺអាស្រ័យទៅលើសមត្ថភាព និងលទ្ធភាពរបស់ភាគី ថាអាចដាក់ឯកសារត្រៀមបានឬទេ ប្រសិនបើភាគីអាចដាក់បាននោះគឺជាការប្រសើរ ប៉ុន្តែបើស្ថានភាពរបស់ភាគីមិនអំណោយផលទេ តុលាការក៏ពុំអាចបង្ខំបានដែរ។

នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្ដីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត។ ចំពោះឯកសារត្រៀមរបស់ដើមចោទ មានដូចជាការដាក់ឯកសារផ្សេងៗ ដែលគាំទ្រដល់ការទាមទារតាមផ្លូវបណ្ដឹងរបស់ខ្លួន រួមទាំងពាក្យបណ្ដឹងរបស់ដើមចោទផ្ទាល់ ដែលមានសរសេរអំពីចំណុចចាំបាច់នានា អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុពាក់ព័ន្ធផ្សេងៗទៀត។ ឯកសារត្រៀមរបស់ដើមចោទមានអត្ថន័យជា *ការដាក់មធ្យោបាយតទល់* [51]។ ដោយឡែកឯកសារត្រៀម របស់ចុងចម្លើយដែលដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ដែលមានសរសេរក្នុងពាក្យបណ្ដឹង សរសេរអំពីការទទួល

[48] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្ដឹង, ទំព័រទី៧២

[49] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០១ កថាខណ្ឌទី៣

[50] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០១ កថាខណ្ឌទី១

[51] មធ្យោបាយតទល់ គឺជាឯកសារ ឬសេចក្ដីថ្លែងការណ៍របស់ដើមចោទ ដែលដាក់ជូនមកតុលាការដើម្បីបញ្ជាក់ពីមូលហេតុទាមទាររបស់ខ្លួនថាត្រឹមត្រូវ។

ស្គាល់ ឬមិនទទួលស្គាល់អង្គហេតុក្នុងពាក្យបណ្ដឹង និងអង្គហេតុតវ៉ាជាអាទិ៍[52]។ ឯកសារត្រៀមបែបនេះអាចហៅថា ឯកសារចម្លើយ។ ឯកសារត្រៀមរបស់ចុងចម្លើយ មានអត្ថន័យជា ការដាក់មធ្យោបាយការពារខ្លួន។

**១.២. ការធ្វើសេចក្ដីថ្លែងការណ៍របស់ភាគី**

ការដាក់ឯកសារត្រៀមទៅតុលាការ គឺមិនទាន់បានគ្រប់គ្រាន់ទេ គឺគូភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីខ្លឹមសារនេះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថែមទៀត ព្រោះថាត្រឹមតែឯកសារដែលដាក់ជូនមកតុលាការ នៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីសេចក្ដីថ្លែងការណ៍របស់ភាគី ដើម្បីឲ្យតុលាការស្វែងរកការពិតនៅឡើយទេ។ ជាពិសេសនៅក្នុងការរៀបចំការអះអាង និងកំណត់ចំណុចវិវាទ តុលាការនឹងយកចំណុចដែលមាននៅក្នុងឯកសារត្រៀមទៅពិចារណា លុះត្រាតែចំណុចទាំងនោះ ត្រូវបានភាគីថ្លែងការណ៍ដោយផ្ទាល់មាត់នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមនោះ[53]។

## ២. ការកំណត់ចំណុចវិវាទនៃរឿងក្ដី

**២.១. សារៈសំខាន់នៃការកំណត់ចំណុចវិវាទនៃរឿងក្ដី**

ចំណុចវិវាទ គឺជាអង្គហេតុ ឬចំណុចទាំងឡាយណា ដែលភាគីប្រកែកគ្នា ឬអះអាងពុំត្រូវគ្នា[54]។ ចំណុចវិវាទ ជាចំណុចសំខាន់ណាស់ដោយសារតែវាជាបញ្ហាគតិយុត្តដើម្បីឲ្យតុលាការធ្វើការដោះស្រាយលើរឿងក្ដីនោះ។ ក្នុងរឿងក្ដីនីមួយៗអាចលេចចេញនូវចំណុចវិវាទច្រើន ប៉ុន្តែចំណុចវិវាទនេះគឺសំដៅលើចំណុចវិវាទនៃរឿងក្ដីទាំងមូលដែលអាចនាំទៅរកការដោះស្រាយនៃរឿងក្ដីនោះបាន។

**២.២. ការបញ្ជាក់អំពីចំណុចវិវាទនៃរឿងក្ដី**

នៅពេលដែលភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួនរួចហើយ តុលាការត្រូវអនុវត្តសិទ្ធិឲ្យបំភ្លឺ ដើម្បីកំណត់ឲ្យបានជាក់លាក់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្ដី និងរៀបចំភស្តុតាងចាំបាច់ ដែលត្រូវធ្វើការពិនិត្យនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ជាទូទៅចំណុចវិវាទរវាងភាគី គឺជាអង្គហេតុ ដូចនេះតុលាការត្រូវពិនិត្យថាអង្គហេតុណាដែលមានវិវាទ។ នៅពេលដែលភាគីម្ខាងបានអះអាង អំពីអង្គហេតុណាមួយនោះ ប្រសិនបើពិនិត្យលើឥរិយាបថរបស់ភាគីម្ខាងទៀត យើងឃើញថាមានឥរិយាបថបួនប្រភេទគឺ[55] ការបដិសេធ ការទទួលស្គាល់ ការមិនបានដឹង និងការមិនឆ្លើយតប។

-ការបដិសេធ គឺជាសេចក្ដីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុ ឬការធ្វើសេចក្ដីថ្លែងការណ៍ដោយមិនទទួលស្គាល់នូវអង្គហេតុដោយភាគីម្ខាងទៀត។

-ការទទួលស្គាល់ គឺជាសេចក្ដីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុ ។

-ការមិនបានដឹង គឺជាសេចក្ដីថ្លែងការណ៍ថាមិនបានដឹងអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ ។

[52] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០១

[53] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្ដឹង, ទំព័រ៧៣

[54] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្ដឹង, ទំព័រទី៨២

[55] ហ៊ី សោភា, នីតិវិធីរដ្ឋប្បវេណី, ទំព័រ ៦៥

-ការមិនឆ្លើយតប គឺត្រូវបានសន្មត់ថាជាការសារភាពអំពីអង្គហេតុ។

ចំពោះអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងនោះទេ[56]។

**៣. ការរៀបចំភស្តុតាង**

នៅពេលដែលតុលាការកំណត់បានច្បាស់អំពីចំណុចវិវាទរួចហើយនោះ ត្រូវសម្រេចធ្វើការបញ្ជាក់ដោយភស្តុតាងស្តីពីចំណុចវិវាទទាំងនោះ។ ភស្តុតាងណាមួយដែលត្រូវបានពិនិត្យ អាស្រ័យដោយការស្នើសុំឲ្យពិនិត្យរបស់ភាគី លើកលែងករណីពិសេស ដែលតុលាការពុំអាចសម្រេចថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុដោយភស្តុតាងដែលភាគីស្នើសុំឲ្យពិនិត្យ នោះតុលាការអាចធ្វើការពិនិត្យដោយឆន្ទានុសិទ្ធិបាន[57]។

**កថាភាគទី៣. កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**១. ភាពចាំបាច់នៃកំណត់ហេតុ**

សកម្មភាពសំខាន់មួយទៀត ដែលចៅក្រមទទួលបន្ទុកដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវតែធ្វើនោះ គឺការធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ គ្រប់កាលបរិច្ឆេទទាំងអស់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចាំបាច់ត្រូវតែមានកំណត់ហេតុ ដោយតុលាការត្រូវបង្គាប់ឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ហេតុផលសំខាន់ដែលច្បាប់តម្រូវឲ្យតុលាការត្រូវតែធ្វើកំណត់ហេតុនេះ ដោយសារតែកំណត់ហេតុនេះជាភស្តុតាងសំខាន់សម្រាប់បញ្ជាក់ថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពិតជាត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ពិតប្រាកដមែនឬទេ ហើយត្រូវបានធ្វើឡើងត្រឹមត្រូវតាមរបៀបដែលច្បាប់កំណត់ដែរឬទេ ដូចជាការពិនិត្យអំពីវត្តមានរបស់ភាគី កាលបរិច្ឆេទនៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយមានការសម្រេចអ្វីខ្លះក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជារួមគឺដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចកំណត់បានតាមរយៈកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះ។

**២. ចំណុចដែលត្រូវសរសេរចូលក្នុងកំណត់ហេតុ**

សម្រាប់ចំណុច ដែលត្រូវសរសេរចូលក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រួមមានចំណុចជារូបមន្ត (ចំណុចជាលក្ខណៈទម្រង់) និងចំណុចជាសារធាតុ (ចំណុចសំខាន់)។ ចំពោះចំណុចជារូប-មន្ត និងចំណុចជាសារធាតុនេះ គឺមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ។

ទម្រង់នៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានរៀបចំជាចំណុចជារូបមន្តដែលរួមមាន[58] ៖

-សញ្ញាណនៃរឿងក្តី។

---

[56] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២៣ កថាខណ្ឌទី២

[57] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៤

[58] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១០

-ឈ្មោះចៅក្រម និងក្រឡាបញ្ជី។

-ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន។

-ពេលវេលា និងទីកន្លែង។

កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវមានចុះហត្ថលេខាដោយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី។

ពាក់ព័ន្ធនឹងចំណុចជាសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺសំដៅលើចំណុចសំខាន់ដែលត្រូវមានក្នុងកំណត់ហេតុ បានន័យថានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឲ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ[59]៖

-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ។

-ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឲ្យពិនិត្យភស្តុតាង។

-ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។

-ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ។

-ចំណុចដែលតុលាការបានបង្គាប់ឲ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឲ្យកត់ត្រាតាមការទាមទាររបស់ភាគី។

-ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះដោយមិនធ្វើជាលាយលក្ខណ៍អក្សរ។

## ផ្នែកទី៣. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### កថាភាគទី១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនោះ[60]។ បានន័យថា តុលាការ និងភាគីសងខាង ត្រូវធ្វើការបញ្ជាក់ថា តើអង្គហេតុណាខ្លះដែលជាចំណុចវិវាទ ហើយដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង និងត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅពេលទាញហេតុផលដោយផ្ទាល់មាត់បាន[61]។

[59] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១១

[60] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៧

[61] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៧

បន្ទាប់ពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីទៀត នៅដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវធ្វើឡើងនៅពេលបន្ទាប់មកបានទេ[62]។

ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវ មិនត្រូវនឹងពេលសមរម្យដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនបាន តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឲ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីបណ្តឹង[63]។

ប្រសិនបើមានការអនុញ្ញាតឲ្យភាគីអាចដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួននៅក្រោយការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាននោះ ការដែលត្រូវកំណត់ពីចំណុចវិវាទឲ្យរួចរាល់តាមរយៈការរៀបចំនូវការអះអាងរបស់ភាគី និងការបង្រួមភស្តុតាងដែលត្រូវពិនិត្យ នឹងពុំមានន័យខ្លឹមសារអ្វីឡើយ។ បើគិតតាមគោលការណ៍នៃការដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅពេលសមរម្យ ដោយភាគីត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ប៉ុន្តែភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅពេលក្រោយបាន ក្នុងករណីដែលបញ្ហាដែលពាក់ព័ន្ធគឺជាចំណុចដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឧទាហរណ៍ អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចរបស់តុលាការ អត្ថិភាព ឬនត្ថិភាព នៃមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះជាអាទិ៍[64]។

**កថាភាគទី២. ការកំណត់កាលបរិច្ឆេទលើកទីមួយនៃការទាញហេតុផលដោយផ្ទាល់មាត់**

នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ហើយត្រូវកោះហៅភាគីទាំងសងខាង ឲ្យមកចូលរួមនៅកាលបរិច្ឆេទដែលបានកំណត់នោះ[65]។

[62] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៨

[63] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៩

[64] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១:នីតិវិធីបណ្តឹង, ទំព័រ៨៦

[65] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៣

# ជំពូកទី៣
# នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

នៅក្នុងជំពូកទី៣នេះ គឺបង្ហាញអំពីទ្រឹស្តីគតិយុត្តនានាស្តីអំពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ដើម្បីយល់ច្បាស់អំពីប្រធានបទនេះ ត្រូវសិក្សាលើចំណុចជាច្រើនបន្តបន្ទាប់ដូចជា សញ្ញាណទូទៅនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលសិក្សាអំពីអត្ថន័យ គោលបំណងនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះចំណុចបន្ទាប់គឺសិក្សាលើដំណើរការនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលមានការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការពិនិត្យភស្តុតាងដោយសមូហវិធីផងដែរ។ ចំណុចចុងក្រោយនៃជំពូកទី៣នេះ គឺនឹងធ្វើការបកស្រាយពាក់ព័ន្ធទៅនឹងការបញ្ចប់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលមានការបកស្រាយអំពីកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ការកត់ត្រាដោយខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ និងការយកឯកសារ ជាអាទិ៍ ជាអាគតដ្ឋាន និង ការភ្ជាប់ជាឧបសម្ពន្ធ័។

## ផ្នែកទី១. សញ្ញាណទូទៅនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តី ដែលក្នុងនោះ សកម្មភាពរបស់តុលាការ និងសកម្មភាពភាគីចំពោះការជម្រះក្តី ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការស្តាប់សេចក្តីថ្លែងការណ៍ នៅសាលសវនាការដែលបើកចំហជាសាធារណៈ[66] នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន។ ម្យ៉ាងទៀត ការទាញហេតុផលដោយផ្ទាល់មាត់ ជានីតិវិធីនៃការវិនិច្ឆ័យសេចក្តីរបស់តុលាការទៅលើបណ្តឹងរដ្ឋប្បវេណី ដើម្បីឈានទៅដល់ការសម្រេចសេចក្តីចេញសាលក្រម ដែលទាមទារឲ្យសកម្មភាពតុលាការ និងភាគីត្រូវធ្វើនៅសាលសវនាការ ហើយតុលាការដែលចេញសាលក្រម ពិតជាបានស្តាប់ការអះអាងរបស់ភាគីដោយផ្ទាល់ ដើម្បីស្វែងរកការពិត។

### កថាភាគទី១. ការកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងមានវត្តមាន។ នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម[67]។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៥ កថាខណ្ឌទី១

[67] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៣

**កថាភាគទី២. ភាពចាំបាច់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

ជាគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីចេញសាលក្រមនៅលើបណ្តឹង តុលាការចាំបាច់ត្រូវឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែ ចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ [68]។

**ផ្នែកទី២. ដំណើរការនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

ដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់ អាចធ្វើទៅបានលុះត្រាតែភាគីទាំងពីរបានចូលរួមនៅកាលបរិច្ឆេទ ដែលកំណត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ នៅក្នុងករណីដែលភាគីណាបានទទួលការកោះហៅត្រឹមត្រូវតាមច្បាប់ហើយ តែមិនព្រមចូលរួមការទាញហេតុផលដោយផ្ទាល់មាត់ដោយពុំមានមូលហេតុត្រឹមត្រូវ។

**កថាភាគទី១. ការសាកល្បងធ្វើការផ្សះផ្សា**

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាគូភាគីបានផងដែរ ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ[69]។ ហេតុដូច្នេះ ទោះបីជានៅកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាគូភាគីបានដែរ។ ការសាកល្បងធ្វើការផ្សះផ្សាអាចធ្វើទៅបាន លុះត្រាតែមានវត្តមានគូភាគីបានចូលរួមនៅក្នុងកាលបរិច្ឆេទកំណត់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធ្វើការបង្ហាញខ្លួនចំពោះមុខតុលាការ។ ក្នុងករណីដែលគូភាគីយល់ព្រមសះជានឹងគ្នា ដោយធ្វើសម្បទានឲ្យគ្នាទៅវិញទៅមកនោះ តុលាការនឹងធ្វើកំណត់ហេតុស្តីពីការសះជា។ កំណត់ហេតុស្តីពីការសះជា ត្រូវបានទទួលស្គាល់ថាមានអានុភាពដូចសាលក្រមស្ថាពរដែរ [70]។ ក៏ប៉ុន្តែប្រសិនបើគូភាគីមិនយល់ព្រម សះជានឹងគ្នានោះទេ ទោះបីតុលាការព្យាយាមប្រឹងប្រែងយ៉ាងក៏ដោយនោះ តុលាការនឹងបញ្ចប់នីតិវិធីផ្សះផ្សា រួចចាប់ផ្តើមនីតិវិធីទាញហេតុ-ផលដោយផ្ទាល់មាត់។

**កថាភាគទី២. សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ការទាញហេតុផលដោយផ្ទាល់មាត់ ជាដំបូងភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយក្នុងសេចក្តីថ្លែងការណ៍នេះ ភាគីត្រូវធ្វើឡើងដោយចង្អុលបង្ហាញឲ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងនៅពេលក្រោយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់[71]។ នៅក្នុងសកម្មភាពរបស់តុលាការ និងភាគីបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយក៏ដោយ ក៏សកម្មភាពទាំងនោះមិនអាចនឹងត្រូវយកទៅធ្វើជាភស្តុតាង ឬ មូលហេតុក្នុងការចេញសាលក្រមបានឡើយដោយហេតុថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនបានធ្វើជាសាធារណៈ លុះត្រាតែបានស្នើសុំ និងមានការព្រមព្រៀងរបស់គូភាគី។

---

[68] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៤ កថាខណ្ឌទី១

[69] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៧

[70] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២២២

[71] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៦ កថាខណ្ឌទី១

នៅពេលធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីអង្គហេតុដែលត្រូវបញ្ជាក់តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអង្គហេតុដែលជាចំណុចវិវាទ។

**កថាភាគទី៣. ការដាក់មធ្យោបាយតទល់ និងមធ្យោបាយការពារថ្មី**

បន្ទាប់ពីធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបន្តនីតិវិធីជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់។ ជាគោលការណ៍ភាគីអាចដាក់មធ្យោបាយតទល់ និងមធ្យោបាយការពារថ្មីបានតែនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ។ ប៉ុន្តែភាគីនៅតែអាចដាក់ភស្តុតាងបាន ក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំពោះមធ្យោបាយតទល់ និងមធ្យោបាយការពារខ្លួនថ្មីនោះ មិនធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ហើយភស្តុតាងអាចដាក់បានមុនពេលចាប់ផ្តើមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងអំឡុងពេលកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ក៏ភាគីអាចដាក់មធ្យោបាយតទល់ និងមធ្យោបាយការពារថ្មីក្នុងករណី ៖

-មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី ពាក់ព័ន្ធនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ។

-មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី ដែលមិនធ្វើឲ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធី ទោះបីជា មធ្យោបាយថ្មីនោះត្រូវបានលើកយកទៅពិនិត្យក៏ដោយ។

-មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី ដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់ មធ្យោបាយនោះមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ។

ហេតុដូច្នេះ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីនៅក្នុងអំឡុងពេលសមរម្យ។ នៅក្នុងករណីដែលមធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីនោះ ត្រូវដាក់នៅក្រោយពេលសមរម្យ ហើយធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង តុលាការអាចលើកចោលមធ្យោបាយថ្មីនោះ។[72]

**កថាភាគទី៤. ការពិនិត្យភស្តុតាងដោយសមូហវិធី**

**១. ការសាកសួរសាមីភាគី**

**១.១. ករណីយកិច្ចរបស់សាមីភាគី**

តុលាការអាចធ្វើការសាកសួរសាមីភាគីបាន។ នៅក្នុងករណីនេះ តុលាការអាចឲ្យភាគីនោះស្បថបាន។ ក្នុងករណីដែលធ្វើការសាកសួរសាមីភាគី បើភាគីនោះពុំចូលខ្លួន ឬ បដិសេធនូវការធ្វើសម្បថ ឬ ផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ ប្រសិនបើភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល បានដោយដីកាសម្រេច។ ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន[73]។

[72] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៣ និងមាត្រា៩៤

[73] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤០

**១.២. សម្បថ**

សម្បថរបស់សាមីភាគីត្រូវធ្វើនៅមុនពេលសាកសួរ។ ប៉ុន្តែបើមានមូលហេតុពិសេសអាចធ្វើនៅក្រោយពេលសាកសួរបាន។ លើកលែងតែសាមីភាគីជាជនដែលមានអាយុក្រោម១៦ឆ្នាំ ឬ ជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឲ្យសាមីភាគីនោះធ្វើសម្បថបានឡើយ។ នៅពេលសាកសួរសាមីភាគីដែលមានសិទ្ធិជិសេធនូវការផ្ដល់ចម្លើយ ហើយសាមីភាគីនោះមិនប្រើសិទ្ធិបដិសេធនូវការផ្ដល់ចម្លើយ តុលាការអាចមិនឲ្យធ្វើសម្បថបាន។ ទម្រង់នៃសម្បថត្រូវធ្វើតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី នីតិវិធីក្នុងការធ្វើសម្បថ។ មុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពីគោលបំណងនៃសម្បថ ហើយប្រាប់ឲ្យដឹងជាមុនអំពីការផ្ដន្ទាទោសចំពោះការផ្ដល់សក្ខីភាពក្លែងក្លាយ។

**១.៣. វិធីសាកសួរសាមីភាគី**

នីតិវិធី និងទម្រង់បែបបទនៃវិធីសាកសួរសាមីភាគី ត្រូវអនុវត្តដូចគ្នានឹងនីតិវិធី និងទម្រង់បែបបទនៃនីតិវិធីសាកសួររបស់សាក្សីដែរ។ លើកលែងតែក្នុងករណីដែលតុលាការយល់ឃើញថា អាចអនុញ្ញាតឲ្យសាមីភាគីដែលត្រូវបានសាកសួរហើយ ឬ សាមីភាគីដែលបម្រុងនឹងត្រូវសាកសួរឲ្យនៅក្នុងសាលសវនាការបាន និងក្នុងករណីយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យធ្វើការសាកសួរសាមីភាគីនឹងសាមីភាគីម្ខាងទៀត ឬ ជាមួយនឹងសាក្សី នៅពេលជាមួយគ្នាបាន។[74]

**១.៤. ការកម្រិតទៅលើសំណួរ**

នីតិវិធី និងទម្រង់បែបបទនៃការកម្រិតទៅលើសំណួរចំពោះសាមីភាគី ត្រូវអនុវត្តដូចគ្នានឹងនីតិវិធី និងទម្រង់បែបបទនៃការកម្រិតទៅលើសំណួរលើសាក្សីផងដែរ។

**១.៥. ការសាកសួរសាមីភាគីនៅក្រៅតុលាការ**

នីតិវិធី និងទម្រង់បែបបទនៃការសាកសួរសាមីភាគីនៅក្រៅតុលាការត្រូវអនុវត្តដូចគ្នានឹងនីតិវិធី និងទម្រង់បែបបទនៃសាកសួរសាក្សីនៅក្រៅតុលាការផងដែរ។

**១.៦. ការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់**

នៅករណីដែលមានអ្នកតំណាងដែលច្បាប់បានកំណត់ តុលាការអាចធ្វើការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់បាន។ មុននឹងធ្វើការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់ តុលាការអាចឱ្យធ្វើសម្បថ និងទម្រង់នីតិវិធីនៃការសាកសួរសាក្សី ត្រូវយកមកអនុវត្តដូចគ្នាចំពោះការសាកសួរសាមីភាគីផងដែរ[75]។

## ២. ការសាកសួរសាក្សី

**២.១. ករណីយកិច្ចរបស់សាក្សី**

ការសាកសួរសាក្សី គឺជាតតិយជនដែលត្រូវតុលាការបង្គាប់ឲ្យធ្វើសេចក្ដីរាយការណ៍ជូនតុលាការ ស្ដីពីអង្គហេតុនៃអតីតកាលដែលខ្លួនបានជួបប្រទះដោយខ្លួនឯងនៅក្រៅបណ្ដឹង។ សេចក្ដីរាយការណ៍របស់សាក្សី គេហៅថា ចម្លើយជាកសិណសាក្សី ហើយការពិនិត្យភស្តុតាងដើម្បីយកចម្លើយជាកសិណសាក្សីនោះ ធ្វើជាធនធានភស្តុតាង គឺជាការសាកសួរសាក្សី។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤១ កថាខណ្ឌទី២

[75] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤២

តុលាការអាចបង្គាប់ឲ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន។ ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បានអោយដីកាសម្រេច ។ ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន[76]។

ការសាកសួរសាក្សីជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ អំពីកិច្ចការសម្ងាត់ក្នុងមុខនាទីនោះ តុលាការត្រូវទទួលការយល់ព្រមពីសំណាក់ស្ថាប័នដែលគ្រប់គ្រងលើសាក្សីនោះ។ ការយល់ព្រមនេះ មិនអាចបដិសេធបានឡើយ លើកលែងតែក្នុងករណីដែលអាចធ្វើឲ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឲ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ[77]។

ប្រសិនបើការផ្តល់ចម្លើយជាកសិណសាក្សី ទាក់ទងនឹងហេតុដែលធ្វើឲ្យសាក្សី ឬ សហព័ទ្ធរបស់សាក្សី ឬ ញាតិឯទៀតរបស់សាក្សី អាចទទួលរងនូវការចោទប្រកាន់ពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោសនោះ សាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន។ បន្ថែមពីនេះ ចំពោះការផ្តល់ចម្លើយជាកសិណសាក្សីទាក់ទងនឹងហេតុដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយសបុគ្គលខាងលើនេះ ឬ បណ្តាលឲ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ សាក្សីអាចបដិសេធនូវការផ្តល់ចម្លើយបាន[78]។

សាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន ៖[79]

-សាក្សីជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ។

-សាក្សីជាវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកធ្លាប់មានមុខងារទាំងនេះ ត្រូវទទួលការសាកសួរអំពីអង្គហេតុដែលបានដឹងក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់។

-ក្នុងករណីដែលសាកសួរអំពីហេតុដែលទាក់ទងនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ។

នៅក្នុងករណីដែលសាក្សីទទួលការលើកលែងពីកិច្ចការលាក់ការសម្ងាត់ នោះសាក្សីមិនអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបានឡើយ។

ចំណែកការសាកសួរសាក្សីនៅក្រៅតុលាការនៅក្នុងករណីដែល ៖

-សាក្សីគ្មានករណីយកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្តឹង ឬ មានមូលហេតុត្រឹមត្រូវដែលអាចចូលតុលាការបាន។

-ការចូលខ្លួនរបស់សាក្សីទៅតុលាការដែលទទួលបណ្តឹង បណ្តាលឲ្យមានការចំណាយទៅលើពេលវេលា ឬ សោហ៊ុយមិនសមរម្យ។

---

[76] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣២

[77] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៣

[78] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៤ កថាខណ្ឌទី១

[79] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៤ កថាខណ្ឌទី២

-ភាគីពុំមានការតវ៉ា[80]។

**២.២. សម្បថ**

សម្បថរបស់សាក្សី ត្រូវធ្វើនៅមុខពេលសាកសួរ។ ប៉ុន្តែបើមានមូលហេតុពិសេសអាចធ្វើទៅក្រោយពេលសាកសួរបាន។ លើកលែងតែសាក្សីជាជនដែលមានអាយុក្រោម១៦ឆ្នាំ ឬ ជនដែលមិនយល់ អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឲ្យសាក្សីនោះធ្វើសម្បថបានឡើយ និងក្នុងករណីមានបញ្ញត្តិពិសេស តុលាការមិនអាចឲ្យសាក្សីនោះធ្វើសម្បថបាន។ នៅពេលសាកសួរសាក្សីដែលមានសិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី ហើយសាក្សីនោះមិនប្រើសិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី តុលាការអាចមិនឲ្យធ្វើសម្បថបាន។ ទម្រង់នៃសម្បថ ត្រូវធ្វើតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី នីតិវិធីក្នុងការធ្វើសម្បថ។ មុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពី គោលបំណងនៃសម្បថ ហើយប្រាប់ឲ្យដឹងជាមុនអំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីភាពក្លែងក្លាយ[81]។

**២.៣. វិធីសាកសួរសាក្សី**

ការស្នើសុំសាកសួរសាក្សី ត្រូវធ្វើឡើងដោយកំណត់ឲ្យបានច្បាស់លាស់ទៅលើសាក្សីណាមួយ។ អ្នកដែលស្នើសុំសាកសួរសាក្សី ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរ។ សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច ២ (ពីរ ) សប្តាហ៍ មុនថ្ងៃសាកសួរ។ ដីកាកោះហៅសាក្សី ត្រូវសរសេរនូវកំណត់សំគាល់ដូចខាងក្រោម ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចសាកសួរ ៖

-ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់សាក្សី។

-ពេលវេលា និង ទីកន្លែងដែលត្រូវចូលខ្លួន។

-ទណ្ឌកម្មដែលកំណត់ដោយច្បាប់នឹងកើតមាន បើមិនចូលខ្លួន។

ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ភាគីដែលស្នើសុំឲ្យសាកសួរនោះ និងភាគីម្ខាងទៀត។ ចៅក្រមប្រឹក្សាអាចសាកសួរទៅសាក្សីបាន នៅក្រោយពេលបានជម្រាបទៅប្រធានក្រុមប្រឹក្សាជំនុំជម្រះឲ្យបានដឹងហើយ។ ប្រសិនបើយល់ឃើញថាត្រឹមត្រូវ តុលាការអាចកែសម្រួលលំដាប់ដែលត្រូវសាកសួរសាក្សីនោះបាន។ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចអនុញ្ញាតឲ្យ សាក្សីដែលត្រូវបានសាកសួរហើយ ឬ សាក្សីដែលបម្រុងនឹងត្រូវសាកសួរឲ្យនៅក្នុងសាលសវនាការបាន។ សាក្សីមិនអាចឆ្លើយដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបានឡើយ ប្រសិនតុលាការអនុញ្ញាតសាក្សីអាចយកឯកសារមកអានបាន។ នៅពេលដែលតុលាការទទួលស្គាល់ថា សាក្សីពុំអាចឆ្លើយឲ្យគ្រប់គ្រាន់បាននៅចំពោះមុខអ្នកសង្កេតការណ៍ណាមួយ ដោយសារតែអ្នកនោះជាហេតុនាំឲ្យមានការភ័យព្រួយ តុលាការអាចបង្គាប់ឲ្យអ្នកសង្កេតការណ៍នោះចេញក្រៅសាលសវនាការ នៅពេលដែលសាក្សីនោះឆ្លើយ។ នៅពេលដែលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យធ្វើការសាកសួរសាក្សី និងសាក្សីផ្សេងទៀត នៅពេលជាមួយគ្នាបាន[82]។

---

[80] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៦ កថាខណ្ឌទី១

[81] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៧

[82] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៨

### ២.៤. ការកម្រិតទៅលើសំណួរ

ចំពោះសំណួរ បើអាចធ្វើបាន ត្រូវធ្វើដាច់ដោយឡែក និងច្បាស់លាស់។ លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរដូចខាងក្រោមនេះ៖

-សំណួរដែលប្រមាថមើលងាយ ឬ ធ្វើឲ្យច្របូកច្របល់ដល់សាក្សី។

-សំណួរនាំមុខ។

-សំណួរច្រំដែល។

-សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ។

-សំណួរដែលទាមទារឲ្យថ្លែងនូវយោបល់របស់សាក្សីផ្ទាល់ខ្លួន។

-សំណួរដែលទាមទារឲ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់។

ម្យ៉ាងវិញទៀត តុលាការអាចកម្រិតនូវសំណួរតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន នៅពេលដែលយល់ឃើញថា សំណួរនោះផ្ទុយនឹងចំណុចខាងលើ នៅក្នុងករណីមិនសុខចិត្តភាគីអាចតវ៉ាចំពោះការកម្រិតសំណួរនេះបាន[83]។

## ៣. កោសលវិច័យ

### ៣.១. ការស្នើសុំឲ្យធ្វើកោសលវិច័យ និងចំណុចធ្វើកោសលវិច័យ

តុលាការអាចបង្គាប់ឲ្យធ្វើកោសលវិច័យតាមពាក្យសុំរបស់ភាគីបាន។ ពេលស្នើសុំធ្វើកោសលវិច័យ ភាគីដែលស្នើសុំត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលសុំឲ្យធ្វើកោសលវិច័យ។ ប៉ុន្តែ ប្រសិនបើមានមូលហេតុដែលពុំអាចជៀសវាងបាន ឯកសារនោះអាចដាក់នៅក្នុងអំឡុងពេលដែលតុលាការបានកំណត់។ តុលាការអាចសួរយោបល់ភាគីម្ខាងទៀត នៅពេលមានការស្នើសុំធ្វើកោសលវិច័យ។

តុលាការត្រូវកំណត់នូវចំណុចដែលត្រូវធ្វើកោសលវិច័យ ដោយផ្អែកលើឯកសារដែលភាគីស្នើសុំ បានភ្ជាប់មកជាមួយ ហើយពិចារណាអំពីយោបល់របស់ភាគីម្ខាងទៀតអំពីការស្នើសុំធ្វើកោសលវិច័យនេះ [84]។

### ៣.២. ការចាត់តាំងអ្នកជំនាញខាងកោសលវិច័យ ករណីយកិច្ចធ្វើកោសលវិច័យ

អ្នកជំនាញខាងកោសលវិច័យត្រូវបានចាត់តាំងដោយតុលាការ។ ជនដែលមានចំណេះវិជ្ជា និងបទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យមានករណីយកិច្ចធ្វើកោសលវិច័យ។

ជនទាំងឡាយ ពុំអាចធ្វើជាអ្នកជំនាញខាងកោសលវិច័យបាន ក្នុងករណីដូចខាងក្រោមនេះ ៖

-ការធ្វើកោសលវិច័យនោះ បណ្តាលឲ្យអ្នកជំនាញផ្ទាល់ខ្លួន ឬ សហព័ទ្ធ ឬ ញាតិឯទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ព្រមទាំងចំពោះករណីដែលអ្នកជំនាញធ្វើកោសលវិច័យ ការធ្វើកោសលវិច័យនោះ អាចធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះ បណ្តាលឲ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ។

-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់ខ្លួនជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ។ ប៉ុន្តែនៅក្នុងករណីដែលអ្នកជំនាញធ្វើកោសលវិច័យទទួលការយល់ព្រមពី

[83] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៩

[84] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤៣

សំណាក់ក្រសួង ឬ ស្ថាប័នគ្រប់គ្រងនោះ អ្នកជំនាញអាចធ្វើកោសលវិច័យបាន។ ក្រសួង ឬ ស្ថាប័នគ្រប់គ្រងមិនអាចបដិសេធមិនផ្តល់ការយល់ព្រមបានឡើយ លើកលែង តែក្នុងករណីដែលអាចធ្វើឲ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឲ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ។ ស្ថាប័នគ្រប់គ្រងខាងលើ គឺព្រឹទ្ធសភាចំពោះសមាជិកព្រឹទ្ធសភា ឬ អតីតសមាជិកព្រឹទ្ធសភា រដ្ឋសភា ចំពោះសមាជិករដ្ឋសភា ឬ អតីតសមាជិករដ្ឋសភា រីឯចំពោះសមាជិករាជរដ្ឋាភិបាល ឬ អតីតសមាជិករាជរដ្ឋាភិបាលវិញ គឺគណៈរដ្ឋមន្ត្រី។ ប៉ុន្តែចំពោះករណីដែលអ្នកជំនាញខាងកោសលវិច័យខាងលើនេះ ទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់នោះ អាចធ្វើកោសលវិច័យបាន។

-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុង សាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ ក្នុងការបំពេញតួនាទីរបស់ខ្លួនហើយ ដែលត្រូវលាក់ការសម្ងាត់។ ប៉ុន្តែចំពោះករណីដែលអ្នកជំនាញខាងកោសលវិច័យខាងលើនេះ ទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់នោះ អាចធ្វើកោសលវិច័យបាន។

-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ។

ប៉ុន្តែ ចំពោះករណីដែលអ្នកជំនាញខាងកោសលវិច័យនោះខាងលើនេះ ទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់នោះ អាចធ្វើកោសលវិច័យបាន[85]។

**៣.៣. បណ្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យ**

ក្នុងករណីមានហេតុដែលរារាំងសច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យនោះបាន នៅមុនពេលដែលអ្នកជំនាញនោះធ្វើសេចក្តីសន្និដ្ឋានអំពីចំណុចដែលត្រូវធ្វើកោសលវិច័យ។ ទោះបីជាក្នុងករណីដែលអ្នកជំនាញខាងកោសលវិច័យបានធ្វើសេចក្តីសន្និដ្ឋានរួចហើយក៏ដោយ ក៏ភាគីអាចប្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យនោះបានដែរ ចំពោះករណីដែលមូលហេតុនៃការផាត់ចោលអ្នកជំនាញនោះបានកើតឡើងនៅពេលក្រោយ ឬ ភាគីបានដឹងអំពីមូលហេតុនោះ ក្រោយពេលដែលអ្នកជំនាញនោះបានធ្វើសេចក្តីសន្និដ្ឋានរួច។

ពាក្យសុំផាត់ចោលត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលពាក្យសុំនោះត្រូវបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

ភាគីដែលដាក់ពាក្យសុំផាត់ចោល ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃបណ្តឹងផាត់ចោលនោះ។

ចំពោះដីកាសម្រេចដែលសម្រេចថា បណ្តឹងផាត់ចោលមានមូលហេតុត្រឹមត្រូវ មិនអាចធ្វើបណ្តឹងឧបាស្រ័យបានទេ ប៉ុន្តែបណ្តឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ អាចប្តឹងជំទាស់បាន[86]។

[85] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤៤

[86] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤៥

**៣.៤. ទម្រង់នៃសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញខាងកោសលវិច័យ និងសំណួររបស់អ្នកជំនាញ ជាអាទិ៍**

តុលាការអាចឲ្យអ្នកជំនាញខាងកោសលវិច័យ បញ្ចេញយោបល់ជាលាយល័ក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន។ ក្នុងករណីដែលមានការចាំបាច់សម្រាប់កិច្ចការធ្វើកោសលវិច័យ អ្នកជំនាញខាងកោសលវិច័យអាចចូលរួមក្នុងសវនាការ ហើយអាចស្នើសុំឲ្យតុលាការធ្វើការសាកសួរសាក្សី ឬ សាមីភាគី ឬ ដោយទទួលការអនុញ្ញាតពីតុលាការ អាចសាកសួរដោយផ្ទាល់មាត់ទៅលើជនទាំងនោះបាន[87]។

ចំពោះការសាកសួរអ្នកជំនាញកោសលវិច័យ និងទម្រង់នៃសម្បថ ការសាកសួរសាក្សី និងសម្បថរបស់សាក្សី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស។

**៤. ភស្តុតាងជាឯកសារ**

**៤.១. ការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍**

ការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់នូវឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំទៅតុលាការឲ្យបង្គាប់ឲ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក។ នៅក្នុងករណីយល់ឃើញថាចាំបាច់ តុលារការអាចឃាត់ទុកនូវឯកសារដែលបានផ្តល់មក ឬ ដែលបានផ្ញើមកបាន។ ក្នុងករណីដែលការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារដែលសរសេរជាភាសាបរទេស ភាគីដែលស្នើសុំត្រូវភ្ជាប់មកជាមួយនូវសេចក្តីបកប្រែត្រង់ចំណុចដែលខ្លួនសុំឲ្យពិនិត្យនោះ[88]។

ក្នុងករណីដែលភាគីម្ខាងទៀត មានយោបល់អំពីភាពត្រឹមត្រូវនៃសេចក្តីបកប្រែនោះ ភាគីអាចដាក់ជូនតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ[89]។

ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ ត្រូវធ្វើឡើងដោយលាយល័ក្ខណ៍ជាអក្សរ និងបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោមនេះ៖

-ចំណងជើង និងខ្លឹមសារនៃឯកសារ

-ម្ចាស់ឯកសារ

-អង្គហេតុដែលត្រូវបញ្ជាក់បំភ្លឺ។[90]

**៤.២. ករណីយកិច្ចផ្តល់ឯកសារ**

បុគ្គលដែលជាម្ចាស់ឯកសារ ពុំអាចបដិសេធនូវការផ្តល់ឯកសារបានឡើយ។ ប៉ុន្តែ បុគ្គលដែលជាម្ចាស់នៃឯកសារ អាចបដិសេធនូវការផ្តល់ឯកសារបាននៅក្នុងករណីដែលឯកសារនោះត្រូវនឹងចំណុចណាមួយដូចខាងក្រោមនេះ៖

-ឯកសារមានសរសេរអំពីហេតុដែលបណ្តាលឲ្យម្ចាស់ឯកសារ ឬ សហព័ទ្ធ ឬ ញាតិដទៃទៀតរបស់ខ្លួនអាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ឬ ហេតុដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់នេះ ឬអាចបណ្តាលឲ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ។

[87] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤៦

[88] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤៨

[89] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៤៩

[90] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៥១

-ឯកសារមានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់មន្ត្រីរាជការ ហើយការផ្តល់ឯកសារនោះអាចបណ្តាលឲ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ។

-ឯកសារមានសរសេរអំពីអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងាររៀបរាប់នេះខាងលើ នៅក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ឬ ហេតុដែលពាក់ព័ន្ធទៅនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់។

**៤.៣. ដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ ជាអាទិ៍**

ក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារមានមូលហេតុត្រឹមត្រូវ តុលាការត្រូវបង្គាប់ដោយដីកាសម្រេច ឲ្យម្ចាស់ឯកសារផ្តល់ឯកសារនោះ។ ក្នុងករណីនេះ បើមានផ្នែកខ្លះនៃឯកសារដែលតុលាការយល់ឃើញថា មិនចាំបាច់ពិនិត្យ ឬ មានផ្នែកខ្លះដែលពុំអាចទទួលស្គាល់ថា មានករណីយកិច្ចក្នុងការផ្តល់ជូននោះ តុលាការអាចបង្គាប់ឲ្យផ្តល់ដោយលើកលែងចោលនូវផ្នែកនោះបាន។ ម្យ៉ាងទៀតក្នុងករណីដែលតុលាការមានបំណងនឹងបង្គាប់ឲ្យតតិយជនផ្តល់ឯកសារ តុលាការត្រូវសួរតតិយជននោះ។ ដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ អាចប្តឹងជំទាស់បាន[91]។

ក្នុងករណីដែលតតិយជនដែលជាម្ចាស់នៃឯកសារមិនគោរពតាមដីកាបង្គាប់ឲ្យផ្តល់ឯកសារ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល ដោយដីកាសម្រេច។ ចំពោះដីកាសម្រេចនេះអាចប្តឹងជំទាស់បាន[92]។

**៥. ការត្រួតពិនិត្យ**

ការស្នើសុំឲ្យត្រួតពិនិត្យត្រូវធ្វើឡើង ដោយចង្អុលបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ។ ការត្រួតពិនិត្យ គឺជាការពិនិត្យភស្តុតាងដើម្បីទទួលបាននូវធនធានភស្តុតាង ដោយការត្រួតពិនិត្យភិនភាគ ឬ បាតុភូតនៃវត្ថុដោយផ្ទាល់ ដោយចៅក្រម ដោយប្រើវិញ្ញាណទាំងប្រាំរបស់ខ្លួន (ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, កាយវិញ្ញាណ, ឃានវិញ្ញាណ, ជីវិញ្ញាណ) ហើយវត្ថុ ឬ មនុស្ស ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនោះ ហៅថា វត្ថុដែលត្រូវត្រួត-ពិនិត្យ។

ការត្រួតពិនិត្យត្រូវធ្វើឡើង ដោយចង្អុលបង្ហាញឲ្យច្បាស់លាស់អំពីកម្មវត្ថុនៃការត្រួតពិនិត្យ។ សាមីភាគីត្រូវដាក់ពាក្យស្នើសុំឲ្យតុលាការធ្វើការត្រួតពិនិត្យកម្មវត្ថុដែលខ្លួនបានដាក់ជូន ឬ ដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យតុលាការបង្គាប់ឲ្យផ្តល់វត្ថុអ្នកដទៃកាន់កាប់ ព្រមទាំងអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីស្នើសុំឲ្យម្ចាស់នៃវត្ថុផ្ញើវត្ថុនោះមក។ ក្នុងករណីយល់ឃើញថាចាំបាច់ តុលាការអាចឃាត់ទុកនូវវត្ថុដែលបានផ្តល់មក ឬ ដែលបានផ្ញើមកនេះបាន។

[91] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៥៣

[92] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៥៤

ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់វត្ថុ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ។ បើភាគីម្ខាងទៀតមានយោបល់ស្តីពីពាក្យសុំដែលបានកំណត់ចំពោះពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់វត្ថុ ភាគីនោះត្រូវដាក់ជូនទៅតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ។

ក្នុងករណីពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់វត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ មានមូលហេតុត្រឹមត្រូវ តុលាការចេញដីកាសម្រេចឲ្យម្ចាស់វត្ថុផ្តល់វត្ថុនោះ។

ក្នុងករណីដែលតុលាការមានបំណងនឹងបង្គាប់ឲ្យតតិយជនផ្តល់វត្ថុនៃការត្រួតពិនិត្យ តុលាការត្រូវសួរតតិយជននោះ។ ចំពោះដីកាសម្រេចអំពីពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់វត្ថុនោះ អាចប្តឹងជំទាស់បាន។ តតិយជនមិនព្រមធ្វើតាមដីកាសម្រេចនេះ ដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល ដោយដីកាសម្រេច ហើយដីកាសម្រេចនេះ អាចប្តឹងជំទាស់បាន។

## ផ្នែកទី៣. ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យភស្តុតាង ហើយតុលាការដែលអាចនឹងមានជំនឿទុកចិត្តទៅលើទំនាក់ទំនងអង្គហេតុនៃរឿងក្តីតាមរយៈការពិនិត្យភស្តុតាងនេះ ឬ ដោយផ្អែកតាមគោលការណ៍នៃការទទួលខុសត្រូវក្នុងការបញ្ជាក់ត្រូវមានតួនាទីចេញសាលក្រមលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវចំពោះ ការទាមទាររបស់ដើមចោទ។ នៅពេលនោះ តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងចេញសាលក្រមចុងក្រោយ[93]។ នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវប្រកាសអំពីការបញ្ចប់នោះ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗ ធ្វើការទាញហេតុផលចុងក្រោយបាននៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ដោយសារថា ការទាញហេតុផលចុងក្រោយ គឺជាឱកាសឲ្យភាគីនីមួយៗ អាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួន ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ដើមចោទ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យភស្តុតាង។ ដូច្នេះតុលាការគួរតែផ្តល់ឱកាសឲ្យភាគីនីមួយៗ លើកឡើងនូវការទាញហេតុ-ផលចុងក្រោយរបស់ខ្លួនឲ្យតែអាចធ្វើទៅបាន។

ទោះបីជាការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានបញ្ចប់ទៅហើយក្តី បើយល់ថាចាំបាច់ តុលាការអាចបើកឲ្យមានការទាញហេតុផលសាជាថ្មី នៅមុនពេលចេញសាលក្រមចុងក្រោយបាន។[94] លើសពីនេះទៅទៀត នៅក្រោយការពិនិត្យភស្តុតាង ប្រសិនបើតុលាការយល់ថាអង្គហេតុសំខាន់មួយបានកើតឡើង ហើយអង្គ-ហេតុនោះ មិនត្រូវបានបញ្ចេញនៅក្នុងការទាញហេតុផលរបស់ភាគីទេ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅពេលនេះ វាផ្ទុយទៅនឹងក្របខ័ណ្ឌយុត្តិធម៌នោះ ហេតុដូច្នេះ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀតបាន ក្នុងករណីដែលតុលាការយល់ឃើញថា ចាំបាច់ដើម្បីធ្វើនីតិវិធីម្តងទៀត ចាប់ពីការរៀបចំចំណុចវិវាទ[95]។

[93] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨០ កថាខណ្ឌទី១

[94] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨០ កថាខណ្ឌទី៣

[95] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៦៦ កថាខណ្ឌទី៣

**កថាភាគទី១. កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

តុលាការត្រូវឲ្យក្រឡាបញ្ជីកត់ត្រាកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ។ នៅក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រា នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះ ត្រូវកត់សេចក្តីប្តឹងតវ៉ានោះ នៅក្នុងកំណត់ហេតុនោះ[96]។

**១. ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ ៖

ក. សញ្ញាណរឿងក្តី។

ខ. ឈ្មោះចៅក្រម និង ក្រឡាបញ្ជី។

គ. ឈ្មោះតំណាងអយ្យការដែលបានចូលរួម ប្រសិនបើមាន។

ឃ. ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន។

ង. ពេលវេលា និង ទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់។

ច. ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ ហេតុការណ៍ និងមូលហេតុដែលមិនបានធ្វើជាសាធារណៈក្នុងករណីមិនធ្វើជាសាធារណៈ។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខានៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នេះ [97]។

**២. ចំណុចជាសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឲ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ ៖

ក. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និងការសារភាព។

ខ. សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសលវិច័យ។

គ. ការធ្វើសម្បថ ឬ មិនធ្វើសម្បថរបស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសលវិច័យធ្វើសម្បថ។

ឃ. លទ្ធផលការត្រួតពិនត្យ ។

ង. ចំណុចដែលតុលាការបានបង្គាប់ឲ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឲ្យកត់ត្រាតាមការទាមទាររបស់ភាគី ។

ច. ការសម្រេចសេចក្តីដែលបានធ្វើឡើង ដោយមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ។

ឆ. ការប្រកាសសេចក្តីសម្រេច។

នៅក្នុងករណីដែលបណ្តឹងត្រូវបានបញ្ចប់ដោយមិនតាមការសម្រេចសេចក្តី សេចក្តីថ្លែងការណ៍របស់សាក្សីរបស់ភាគីផ្ទាល់ និងរបស់អ្នកកោសលវិច័យ និងលទ្ធផលនៃការត្រួតពិនិត្យ អាចមិនសរសេរក្នុងកំណត់ហេតុ

[96] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៧

[97] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៨

បានដោយទទួលការអនុញ្ញាតពីតុលាការ។ ប៉ុន្តែចំពោះករណីដែលភាគីទាមទារឲ្យកត់ត្រាក្នុងកំណត់ហេតុក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលខ្លួនបានដឹងថាបណ្តឹងនោះត្រូវបានចប់[98]។

**កថាភាគទី២. ការកត់ត្រាដោយថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ**

ក្នុងករណីមានការអនុញ្ញាតពីតុលាការ ក្រឡាបញ្ជីអាចថតខ្សែអាត់ ឬ ខ្សែវីដេអូនូវសេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យ ដើម្បីជំនួសកំណត់ហេតុជាលាយល័ក្ខណ៍អក្សរបាន។ ប៉ុន្តែនៅពេលដែលតុលាការអនុញ្ញាត ភាគីអាចបញ្ចេញមតិយោបល់របស់ខ្លួនបាន។

ក្នុងករណីមានការស្នើសុំរបស់ភាគី រហូតដល់បណ្តឹងនេះបានបញ្ចប់ ក្រឡាបញ្ជីត្រូវធ្វើឯកសារ ដែលកត់សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យជាលាយល័ក្ខណ៍អក្សរ[99]។

**កថាភាគទី៣. ការយកឯកសារ ជាអាទិ៍ ជាអាគតដ្ឋាន និង ការភ្ជាប់ជាឧបសម្ព័ន្ធ**

ឯកសារ រូបថត ខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុផ្សេងទៀតដែលតុលាការយល់ឃើញថាសមរម្យអាចយកធ្វើជាផ្នែកមួយនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ដោយយកធ្វើអាគតដ្ឋានក្នុងកំណត់ហេតុនោះ ហើយភ្ជាប់ជាមួយនឹងសំណុំរឿងជាឧបសម្ព័ន្ធបាន[100]។

[98] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៩

[99] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២០

[100] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២១

# ជំពូកទី៤
# ការប្រកាសសាលក្រម

ដោយបណ្តឹងត្រូវបានចាប់ផ្តើម ដោយការទាមទាររបស់ដើមចោទ តាមរយៈពាក្យបណ្តឹងសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់ណាមួយ ជាគោលការណ៍បណ្តឹងត្រូវបញ្ចប់ដោយសាលក្រមរបស់តុលាការដែលឆ្លើយតបចំពោះការទាមទាររបស់ដើមចោទនោះ [101] ដូច្នេះនៅពេលបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងចេញសាលក្រមដោយតុលាការនឹងបន្តនីតិវិធីនៃការប្រកាសសាលក្រមដែលនឹងត្រូវបកស្រាយនៅក្នុងជំពូកទី៤នេះ។ ពាក់ព័ន្ធនឹងនីតិវិធីនៃការប្រកាសសាលក្រម គឺយើងខ្ញុំនឹងធ្វើការបកស្រាយដោយធ្វើការបែងចែកជា០៣ផ្នែក គឺផ្នែកទី១ ស្តីអំពីសញ្ញាណទូទៅនៃសាលក្រម ផ្នែកទី២ ស្តីអំពីដំណើរការនៃការប្រកាសសាលក្រម និងផ្នែកទី៣ ស្តីអំពីអានុភាពនៃសាលក្រម។

## ផ្នែកទី១. សញ្ញាណទូទៅនៃសាលក្រម

### កថាភាគទី១. អត្ថន័យនៃសាលក្រម

សាលក្រម គឺជាសេចក្តីសម្រេចដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ ហើយកើតអានុភាពដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ[102]។

### កថាភាគទី២. សាលក្រមចុងក្រោយ

បើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ [103] ។ បញ្ញត្តិនេះគឺចែងអំពីសាលក្រមសម្រេចអង្គសេចក្តី ដែលត្រូវបញ្ចប់នីតិវិធីនៃបណ្តឹងដែលតុលាការជាន់ណាមួយកំពុងចាត់ការ។ ទស្សនទានផ្ទុយពីសាលក្រមចុងក្រោយ គឺសាលក្រមរបៀប។ ចំពោះសាលក្រមចុងក្រោយ គេទុកផ្លូវសម្រាប់ឲ្យធ្វើបណ្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់បាន តែចំពោះសាលក្រមរបៀបវិញ គេមិនទទួលស្គាល់ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដោយឯកឯងឡើយ។ ប្រភេទនៃសាលក្រមចុងក្រោយមានដូចជា សាលក្រមលើកចោលពាក្យបណ្តឹង សាលក្រមច្រានចោលការទាមទារ និងសាលក្រមទទួលស្គាល់ការទាមទារ[104]។

#### ១. សាលក្រមលើកបណ្តឹងចោល

សាលក្រមលើកបណ្តឹងចោល គឺជាសាលក្រមប្រភេទទី១នៃសាលក្រមចុងក្រោយ ដែលតុលាការនឹងធ្វើការចេញសាលក្រមលើកបណ្តឹងចោលនេះ ដោយមិនធ្វើការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការ

[101] មើលសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង, ទំព័រទី១២៨

[102] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៧៩ ចំណុចទី១

[103] ក្រមនីវិធីរដ្ឋប្បវេណី មាត្រា ១៨០ ចំណុចទី១

[104] មើលសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨០ ចំណុចទី១

ទាមទារ ដោយមកពីមូលហេតុខ្វះល័ក្ខខ័ណ្ឌបណ្តឹង។ នៅក្នុងករណីនេះ ដោយបណ្តឹងចប់ភ្លាមបន្ទាប់ពីការវិនិច្ឆ័យទៅលើអត្ថិភាព ឬនត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្តឹង សាលក្រមបែបនេះ គេហៅថា "សាលក្រមនីតិវិធី"។

**២. សាលក្រមទទួលស្គាល់ការទាមទារ**

សាលក្រមទទួលស្គាល់ការទាមទារ គឺជាសាលក្រមទទួលស្គាល់ការទាមទាររបស់របស់ដើមចោទ ចំពោះបណ្តឹងដែលគ្មានភាពខ្វះខាតនៃល័ក្ខខ័ណ្ឌបណ្តឹង។ សាលក្រមប្រភេទនេះគេហៅថា "សាលក្រមទទួលស្គាល់ការទាមទារ"។

**៣. សាលក្រមមិនទទួលស្គាល់ការទាមទារ**

សាលក្រមមិនទទួលស្គាល់ការទាមទារ គឺជាសាលក្រមមិនទទួលស្គាល់ការទាមទាររបស់ដើមចោទចំពោះបណ្តឹងដែលគ្មានភាពខ្វះខាតនៃល័ក្ខខ័ណ្ឌបណ្តឹង។ សាលក្រមប្រភេទនេះគេហៅថា "សាលក្រមច្រានចោលការទាមទារ"។

សាលក្រមទទួលស្គាល់ការទាមទារ និងសាលក្រមច្រានចោលការទាមទារ គឺជាសាលក្រមអង្គសេចក្តីដែលជាសាលក្រមបង្ហាញអំពីការសម្រេចសេចក្តីរបស់តុលាការស្តីពីភាពត្រឹមត្រូវនៃការទាមទារ ដែលជាកម្មវត្ថុដើមនៃបណ្តឹង ហើយដោយបែបនេះ សាលក្រមទាំងនោះខុសគ្នាពីសាលក្រមលើបណ្តឹង ដែលមានតែការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាព នៃល័ក្ខខ័ណ្ឌនៃបណ្តឹងប៉ុណ្ណោះ។ ហេតុដូច្នេះគេហៅថា សាលក្រមលើអង្គសេចក្តី ក្នុងន័យថាជាសាលក្រមដែលសម្រេចអំពីអង្គសេចក្តីនៃរឿងក្តី[105]។

**កថាភាគទី៣. សាលក្រមរបៀប**

**១. អត្ថន័យនៃសាលក្រមរបៀប**

សាលក្រមរបៀបដែលគ្មានអានុភាពបញ្ចប់បណ្តឹងទេ ហើយដែលសម្រេចសេចក្តីចំពោះចំណុចដែលជាបុរេល័ក្ខខ័ណ្ឌសម្រាប់ការចេញសាលក្រមចុងក្រោយ គេឲ្យឈ្មោះថា "សាលក្រមរបៀប"។ ដោយមូលហេតុសាលក្រមរបៀប មានគោលបំណងរៀបចំ និងសម្រួលធ្វើឲ្យការវិនិច្ឆ័យបណ្តឹងមានសណ្តាប់ធ្នាប់ តុលាការអាចចេញសាលក្រមរបៀបបានតែចំពោះចំណុចដែលត្រូវនឹងគោលបំណងនោះប៉ុណ្ណោះ[106]។

**២. ចំណុចដែលអាចចេញសាលក្រមរបៀប**

បើមានវិវាទអំពីហេតុណាមួយដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ តុលាការអាចបញ្ចប់ការវិនិច្ឆ័យ ចំពោះតែហេតុនោះសិន ហើយចេញសាលក្រមរបៀបបាន[107]៖

-អត្ថិភាពនៃការទាមទារក្នុងករណីដែលមានវិវាទលើអត្ថិភាព និងចំនួនទឹកប្រាក់នៃការទាមទារ។

-មធ្យោបាយតទល់ ឬការពារខ្លួនដែលអាចវិនិច្ឆ័យដោយឯករាជ្យបាន។

-អត្ថិភាព ឬនត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្តឹង។

-ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្តឹង។

---

105 មើលសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង, ទំព័រទី១២៨

106 មើលសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង, ទំព័រទី១២៩

107 មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨១

## ផ្នែកទី២. ដំណើរការនៃការប្រកាសសាលក្រម

### កថាភាគទី១. កាលបរិច្ឆេទនៃការប្រកាសសាលក្រម

ការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត[108]។

### កថាភាគទី២. របៀបនៃការប្រកាសសាលក្រម

ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម។ ប៉ុន្តែក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ចៅក្រមប្រឹក្សាអាចអានជំនួសបាន។ ការប្រកាសសាលក្រមអាចធ្វើទៅបានទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ។ ប្រសិនបើយល់ឃើញថាសមរម្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬ អាចពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន[109]។

ក្នុងករណីដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវប្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ។ បើដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន។ បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវប្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ[110]។

បើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភ្លាមៗ ហើយកំណត់កាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់។ បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុ-ផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ហើយបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ តែបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវប្រានចោលការទាមទារនោះ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីមុនមក[111]។

---

[108] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៧

[109] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៨

[110] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២០០

[111] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០១

តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយករណី[112] ៖

- ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់។
- ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន។
- បណ្ដឹងមិនស្របច្បាប់។
- ខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយ មុនកាលបរិច្ឆេទនោះ។

### កថាភាគទី៣. លិខិតសាលក្រម

នៅក្នុងលិខិតសាលក្រម[113] ត្រូវសរសេរចំណុចដូចជា តុលាការ ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ អង្គហេតុ និងចំណុចវិវាទ សំអាងហេតុ និងសេចក្ដីសម្រេចបញ្ចប់។ ចំពោះអង្គហេតុ និងចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗ ដោយផ្អែកលើសេចក្ដីថ្លែងការណ៍របស់ភាគី។ ចៅក្រមដែលចេញសាលក្រមត្រូវចុះហត្ថលេខាលើលិខិតសាលក្រមនោះ។ ក្នុងករណីដែលចៅក្រមណាម្នាក់ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ មានធុរៈក្នុងការចុះហត្ថលេខាលើលិខិតសាលក្រម ចៅក្រមផ្សេងទៀតត្រូវចុះហត្ថលេខាដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះមិនអាចចុះហត្ថលេខាបាន។

លិខិតសាលក្រមត្រូវបញ្ជូនទៅឲ្យគូភាគី ក្នុងអំឡុងពេល ០២ (ពីរ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ។ ការបញ្ជូននេះត្រូវធ្វើឡើងដោយអនុសារសាលក្រម[114]។

### ផ្នែកទី៣. អានុភាពនៃសាលក្រម

ពេលដែលសាលក្រមចុងក្រោយត្រូវបានបង្កើតហើយ អានុភាពផ្សេងៗនឹងកើតមានឡើង។ ជាក់ស្ដែងដូចជា អត្តពន្ធភាព អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ អានុភាពអនុវត្ត អានុភាពនៃការបង្កើត (ឬផ្លាស់ប្ដូរ ឬរំលត់) សិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាដើម។ ក្នុងចំណោមនោះ អានុភាព០៣ (បី) ដំបូង គឺជាអានុភាពរួម ចំពោះរាល់សាលក្រមទាំងអស់ ដោយឡែកអានុភាពនៃការអនុវត្តត្រូវកើតឡើងចំពោះសាលក្រមបង្គាប់ឲ្យផ្ដល់តាវកាលិក ហើយអានុភាពនៃការបង្កើត (ឬផ្លាស់ប្ដូរ ឬរំលត់) សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ត្រូវកើតឡើងចំពោះសាលក្រមបង្កើត (ឬផ្លាស់ប្ដូរ ឬរំលត់) សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត[115]។

---

[112] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២០២

[113] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៩

[114] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩០

[115] មើលសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្ដឹង, ទំព័រទី១៣៣

**កថាភាគទី១. អត្តពន្ធភាពនៃសាលក្រម**

សាលក្រមនឹងត្រូវបានផ្តើតឡើងដោយការប្រកាស ហើយបន្ទាប់មក សាលក្រមនោះនឹងចងតុលាការដែលចេញសាលក្រមនោះ ហើយមិនអនុញ្ញាតឲ្យលុបចោល ឬប្តូរបានឡើយ។ នេះគឺដោយសារតែ សាលក្រមគឺជាការសម្តែងចេញមកខាងក្រៅ នៃការវិនិច្ឆ័យដោយសិទ្ធិអំណាចសាធារណៈ ម្យ៉ាងទៀត ប្រសិនបើតុលាការអាចលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដោយងាយស្រួលនឹងធ្វើឲ្យបាត់បង់នូវស្ថិរភាពគតិយុត្ត ហើយធ្វើឲ្យខូចកិត្យានុភាពរបស់តុលាការទៀតផង។ អានុភាពចងបែបនេះ គេហៅថាអត្តពន្ធភាពនៃសាលក្រម។

តុលាការមិនអាចលុប ឬធ្វើការកែប្រែសាលក្រមបានឡើយ ប៉ុន្តែតុលាការអាចលុប ឬកែប្រែសាលក្រមនោះបានតាមរយៈដីកាសម្រេចកែតម្រូវ។ ក្នុងករណីដែលសាលក្រមមានការគណនាលេខខុស ឬកត់ខុស ឬកំហុសជាក់ស្តែងផ្សេងទៀតដែលមានប្រភេទប្រហាក់ប្រហែលគ្នា តុលាការអាចចេញដីកាសម្រេចកែតម្រូវសាលក្រម តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។ ដីកាសម្រេចកែតម្រូវអាចប្តឹងជំទាស់បាន លើកលែងតែករណីមានបណ្តឹងឧទ្ធរណ៍ស្របច្បាប់ចំពោះសាលក្រមប៉ុណ្ណោះ។ ដីកាសម្រេចកែតម្រូវត្រូវសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និងអនុសារសាលក្រម។ ប៉ុន្តែប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើដីកាសម្រេចនេះជាលិខិត ជំនួសការសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និងអនុសារសាលក្រម ហើយបញ្ជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនេះ ទៅឲ្យគូភាគីបាន[116]។

**កថាភាគទី២. អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់**

សាលក្រមចូលជាស្ថាពរ នៅពេលដែលគេមិនអាចទាមទារឲ្យលុបសាលក្រមនោះចោល ដោយបណ្តឹងឧបាស្រ័យធម្មតា ដូចជាការប្តឹងឧទ្ធរណ៍ ឬការប្តឹងសាទុក្ខបាន។ ដោយសារតែគេអាចចាត់ទុកបានថា នេះជាលទ្ធផលនៃសេចក្តីវិនិច្ឆ័យដែលមានអានុភាពចង ដែលរារាំងសូម្បីតែតុលាការដែលមានថ្នាក់ខ្ពស់ជាងក៏មិនអាចលុបចោលនូវសេចក្តីសម្រេចនោះបាននោះ គេអាចនិយាយបានថា អានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់កើតមានឡើង។ អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់នៃសាលក្រមនេះ គឺជាល័ក្ខខ័ណ្ឌមូលដ្ឋាននៃការកើតមានឡើងនូវអាជ្ញាអស់ជំនុំជាលក្ខណៈសារជាតុ អានុភាពអនុវត្ត និងអានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬរំលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត។

សាលក្រមចូលជាស្ថាពរ នៅពេលផុតអំឡុងពេលដែលបានកំណត់សម្រាប់ការប្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬការប្តឹងទាស់ដែលស្របច្បាប់។ ការចូលជាស្ថាពរនៃសាលក្រម ត្រូវបានបង្អាក់ដោយការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬពាក្យបណ្តឹងទាស់[117]។

**កថាភាគទី៣. អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ**

ប្រសិនបើបញ្ហាដែលបានវិនិច្ឆ័យដោយសាលក្រមចុងក្រោយដែលបានចូលជាស្ថាពរ បានក្លាយជាបញ្ហាក្នុងបណ្តឹងមួយផ្សេងទៀត ភាគីមិនត្រូវអនុញ្ញាតឲ្យធ្វើការការអះអាងដែលមានភាពផ្ទុយគ្នានឹងការវិនិច្ឆ័យដែល

[116] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩១ និងមាត្រា១៩២

[117] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩៣

បានធ្វើហើយក្នុងសាលក្រមស្ថាពរទេ ហើយតុលាការក៏មិនត្រូវអនុញ្ញាតឱ្យធ្វើការវិនិច្ឆ័យដែលមានភាពផ្ទុយគ្នានឹងការវិនិច្ឆ័យដែលបានធ្វើហើយក្នុងសាលក្រមស្ថាពរនោះឡើយ។ អានុភាពនៃការវិនិច្ឆ័យនៅក្នុងសាលក្រមស្ថាពរដែលចងនូវខ្លឹមសារនៃការវិនិច្ឆ័យក្រោយពេលនោះ ត្រូវហៅថា អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ[118]។

**កថាភាគទី៤. អានុភាពអនុវត្ត**

តាមធម្មតា អានុភាពដែលអាចសម្រេចនូវសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក ដែលមានសរសេរនៅក្នុងឯកសារណាមួយ ហៅថា "អានុភាពអនុវត្ត" ហើយឯកសារដែលត្រូវបានទទួលស្គាល់នូវអានុភាពអនុវត្ត ហើយនឹងក្លាយទៅជាមូលដ្ឋានគតិយុត្តនៃការអនុវត្តដោយបង្ខំនោះ គេហៅថា "លិខិតអនុវត្ត"។ សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក មានអានុភាពអនុវត្ត ហើយអាចសម្រេចបាននូវសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកដែលជាខ្លឹមសារនៃសាលក្រមនោះ ដោយការអនុវត្តដោយបង្ខំ។ ក្នុងចំណោមសាលក្រមទាំងអស់ មានតែសាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិកប៉ុណ្ណោះទេ ដែលមានអានុភាពអនុវត្ត។ ជាគោលការណ៍ អានុភាពអនុវត្តនៃសាលក្រមត្រូវកើតឡើងនៅពេលដែលអានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុកើតមានឡើង មានន័យថា គឺនៅពេលដែលសាលក្រមចុងក្រោយបានចូលជាស្ថាពរ លើកលែងតែសាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក ដែលមានភ្ជាប់នូវការប្រកាសការអនុវត្តបណ្តោះអាសន្ន[119]។

**កថាភាគទី៥. អានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**

អានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាអានុភាពបង្កើត ផ្លាស់ប្តូរ ឬរំលត់នូវស្ថានភាពគតិយុត្ត តាមផ្លូវច្បាប់សារធាតុដោយផ្ទាល់ដោយសាលក្រម។ ក្នុងចំណោមសាលក្រមទាំងអស់ សាលក្រមដែលមានអានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺមានតែសាលក្រមបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តដែលទទួលស្គាល់នូវការទាមទារនៃបណ្តឹងទាមទារឲ្យបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តទេ។ អានុភាពបង្កើត ផ្លាស់ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តបានចូលជាស្ថាពរ[120]។

[118] មើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩៤

[119] មើលសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង, ទំព័រទី១៨៤

[120] មើលសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង, ទំព័រទី១៨៥

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ អំពីនីតិវិធីនៃការជម្រះក្ដីលើកទី១មក ក្រុមយើងខ្ញុំសង្កេតឃើញថា នីតិវិធីនៃការជម្រះក្ដីលើកទី១ជានីតិវិធីដោះស្រាយរឿងក្ដីរដ្ឋប្បវេណី ដោយសារតែរឿងក្ដីរដ្ឋប្បវេណីត្រូវបានដោះ-ស្រាយតាមរយៈនីតិវិធីជំនុំជម្រះក្ដីលើកទី១ ក្នុងនោះផងដែរនៅក្នុងនីតិវិធីជំនុំជម្រះក្ដីលើកទី១ ក៏មានបែងចែកជាជំពូកចំនួន០៤ (បួន) ធំៗដូចជា ទី០១ (មួយ) ការដាក់ពាក្យបណ្ដឹង បកស្រាយអំពីការដាក់ពាក្យបណ្ដឹង ការទទួលពាក្យបណ្ដឹង ការពិនិត្យពាក្យបណ្ដឹង និងការបែងចែករឿងក្ដី ទី០២ (ពីរ) នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល បកស្រាយអំពីសញ្ញាណនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទី០៣ (បី) នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលបានធ្វើការបកស្រាយអំពីសញ្ញាណទូទៅនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដំណើរការនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និង ទី០៤ (បួន) ចុងក្រោយគឺនឹងបកស្រាយពាក់ព័ន្ធនឹងការប្រកាសសាលក្រម ដែលលម្អិតបន្ថែមពាក់ព័ន្ធនឹងសញ្ញាណនៃសាលក្រម ដំណើរការនៃការប្រកាសសាលក្រម និងអានុភាពនៃសាលក្រម។

ហេតុដែលនាំឱ្យមានការសម្រេចសេចក្ដីក្នុងរឿងក្ដីរដ្ឋប្បវេណីកើតឡើង ដោយសារតែការប្រើប្រាស់សិទ្ធិហួសព្រំដែនដែលកំណត់ដោយច្បាប់ ធ្វើឱ្យមានការបំពានលើសិទ្ធិនៃជីវិតឯកជនរបស់អ្នកដទៃ ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃដែលកើតមានក្នុងសង្គម ទើបនីតិវិធីជំនុំជម្រះក្ដីលើកទី១ ត្រូវបានបញ្ញត្តិសម្រាប់ឱ្យចៅក្រមអនុវត្តតាមសម្រាប់ដោះស្រាយលើរាល់បញ្ហា បំពានសិទ្ធិទាំងអស់នោះ ដោយផ្អែកតាមការជំនុំជម្រះក្ដីលើកទី១ ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ដើម្បីឱ្យបុគ្គលដែលបានទទួលរងនូវការរំលោភបំពានសិទ្ធិ និងខូចខាតទ្រព្យសម្បត្តិ ទទួលបានសំណងជម្ងឺចិត្ត និងសំណងការខូចខាតអំពីព្យសនកម្មនៃអំពើបំពានដែលខ្លួនបានទទួលរងនោះ។ ក្រោយពីក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ ក្រុមយើងខ្ញុំបានយល់ដឹងកាន់តែច្បាស់ ហើយក៏យល់ឃើញថា បញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលចែងអំពីនីតិវិធីជំនុំជម្រះក្ដីលើកទី១ មានលក្ខណៈល្អណាស់ ព្រោះមុននឹងមានការសម្រេចសេចក្ដីត្រូវឆ្លងកាត់នីតិវិធីជាច្រើន ហើយនីតិវិធីមួយចំនួនត្រូវបានធ្វើឡើងវិញ ធ្វើយ៉ាងណាដើម្បីឱ្យទទួលបានភាពពិតប្រាកដច្បាស់លាស់ ហេតុនេះហើយទាំងភាគីដើមចោទ ឬភាគីចុងចម្លើយនៅក្នុងរឿងក្ដីរដ្ឋប្បវេណីនឹងទទួលបានភាពយុត្តិធម៌យ៉ាងពិតប្រាកដ អំពីអំពើបំពានដែលកើតឡើងមកលើខ្លួន។ ដោយសារមានការវិនិច្ឆ័យ និងការសម្រេចសេចក្ដីយ៉ាងយកចិត្តទុកដាក់របស់ចៅក្រមលើរឿងក្ដី ព្រមទាំងក្រឡាបញ្ជីបានជួយសម្រួលកិច្ចការផ្សេងៗ ដើម្បីឱ្យភាគីរងគ្រោះទទួលបានយុត្តិធម៌យ៉ាងឆាប់រហ័សទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។ តែយ៉ាងណាក៏ដោយ ការទទួលបានការសម្រេចសេចក្ដីយ៉ាងឆាប់រហ័សគឺមិនអាចធ្វើទៅបានលើគ្រប់រឿងក្ដីទេ ដោយសារតែមានសំណុំរឿងក្ដីមានចំនួនច្រើន ហើយរឿងមួយចំនួនមានលក្ខណៈស្មុគស្មាញ ដែលត្រូវទាមទារឱ្យប្រើពេលវេលាក្នុងការដោះស្រាយមួយកម្រិតទៀត។ ក្នុងនេះផងដែរ ក្រុមយើងខ្ញុំសូមផ្ដល់ជាអនុសាសន៍ និងលើកទឹកចិត្តដល់មន្ត្រីបម្រើការក្នុងវិស័យយុត្តិធម៌ទាំងអស់ សូមមានមនសិការក្នុងការបំពេញការងារដោយការយកចិត្តទុកដាក់ខ្ពស់បំផុតបន្ថែមទៀត ដើម្បីឱ្យដំណើរការរឿងក្ដីទទួលបានភាពត្រឹមត្រូវយុត្តិធម៌។

សរុបសេចក្តីមក នីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ ដែលក្រុមយើងខ្ញុំបានធ្វើការបកស្រាយខាងលើរួចមក យល់ឃើញថាប្រធានបទនេះ គឺជានីតិវិធីសំខាន់នៅក្នុងរឿងក្តីរដ្ឋប្បវេណី ហើយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការយកចិត្តទុកដាក់បំពេញការងារតាមច្បាប់ចែងរបស់មន្ត្រីអនុវត្តច្បាប់ នឹងសម្រេចបាននូវជោគជ័យក្នុងការ ពន្លឿនការដោះស្រាយរឿងក្តីដោយយុត្តិធម៌ និងឆាប់រហ័ស ឱ្យកាន់តែល្អប្រសើរឡើងបន្ថែមទៀត។

# អនុសាសន៍

ដើម្បីឱ្យប្រធានបទសារណាស្ដីអំពីការជំនុំជំម្រះក្ដីលើកទី១នេះ ប្រព្រឹត្តទៅត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដាច់ខាតត្រូវអនុវត្តតាមច្បាប់ត្រឹមត្រូវ ទាមទារឱ្យអ្នកមានសមត្ថកិច្ចអនុវត្តច្បាប់ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ក្នុងការបំពេញកិច្ចការងារដែលខ្លួនមានតួនាទីត្រូវបំពេញឱ្យបានល្អ។ ហើយនៅរឿងក្ដីរដ្ឋប្បវេណីត្រូវឆ្លងកាត់ការជំនុំជម្រះក្ដីលើកទី១ មុនឈានដល់ការសម្រេចសេចក្ដីដោយចៅក្រមលើបណ្ដឹង ដែលដើមចោទបានដាក់មកតែក្នុងនីតិវិធីបណ្ដឹងរឿងក្ដីរដ្ឋប្បវេណីនេះក៏មាននីតិវិធីមួយក្នុងនោះផងដែរ គឺនីតិវិធីផ្សះផ្សា ដោយសារតែក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិឱ្យមានការផ្សះផ្សានៅគ្រប់ដំណាក់កាលទាំងអស់ឱ្យអស់ពីលទ្ធភាពជាមុនសិនប្រសិនបើការផ្សះផ្សាមិនទទួលបានលទ្ធផលទេ តុលាការនឹងបន្តនីតិវិធីបណ្ដឹងបន្តទៅមុខទៀត។

មួយវិញទៀតការជម្រះក្ដីលើកទី១ ជានីតិវិធីដែលអនុវត្តដោយតុលាការក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ដោយការទទួលខុសត្រូវតុលាការប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្ដឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ដោយមានការចូលរួមចំណែកទទួលខុសត្រូវពីភាគីក្នុងរឿងក្ដី ត្រូវអនុវត្តបណ្ដឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។ សើសពីនេះទៀតរាល់ការដាក់ពាក្យបណ្ដឹងរបស់ដើមចោទ ដែលប្ដឹងទៅលើភាគីម្ខាងទៀតជាចុងចម្លើយ គឺត្រូវបានតុលាការដែលមានសមត្ថកិច្ចជម្រះក្ដីនៃការជំនុំជម្រះក្ដីលើកទី១ ដំណើរការនីតិវិធីតាមច្បាប់កំណត់ ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីដោះស្រាយវិវាទប្រកបដោយយុត្តិធម៌។

ជាចុងក្រោយសម្រាប់ការបញ្ចប់នៃការសរសេរសារណានេះ យើងខ្ញុំសង្ឃឹមថាការលើកយកប្រធានបទនៃការជំនុំជម្រះក្ដីលើកទីមួយមកធ្វើការបកស្រាយ បានចូលរួមចំណែកក្នុងការផ្សព្វផ្សាយដល់អ្នកសិក្សារៀនសូត្រជំនាន់ក្រោយបានទទួលចំណេះដឹងបន្ថែមទៀតអំពីប្រធានបទមួយនេះ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់អ្នកអាន និងប្អូនៗនិស្សិតដែលសិក្សាផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ ឬសិក្សាបរិញ្ញាបត្រផ្សេងក៏ដោយ ក៏ត្រូវតែយល់ឱ្យបានច្បាប់អំពីនីតិធីជំនុំជម្រះក្ដីលើកទី១នេះ ដើម្បីជាចំណេះដឹងសម្រាប់ជាទុនក្នុងការការពារខ្លួនពីការបំពានសិទ្ធិរបស់អ្នកដទៃមកលើខ្លួន ឬអាចដឹងអំពីការដោះស្រាយបញ្ហាអំពីការបំពាននេះនៅក្នុងសង្គមរស់នៅបាន។

# គន្ថនិទ្ទេស

**១.ក្រម**

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

**២.សៀវភៅ**

-សៀវភៅ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង រៀបចំដោយគណ:កម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី បោះពុម្ពឆ្នាំ២០០៨។

-សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណ:កម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី បោះពុម្ពឆ្នាំ២០០៧។

-សៀវភៅ នីតិវិធីរដ្ឋប្បវេណី បង្រៀនដោយសាស្ត្រាចារ្យ ហ៊ី សោភា។

**៣.ឯកសារផ្សេងៗរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តតាកែវ**

**៤.វចនានុក្រមអេឡិចត្រូនិច**

វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ពាក្យបណ្ដឹង

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹង

▪*ដើមចោទ:* **ឈ្មោះ** *ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិបឹង តាពេង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត។*

▪*អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ:* *លោកមេធាវី និង ការិយាល័យស្ថិតនៅភូមិមួយ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ ទូរស័ព្ទលេខ:០១១ ៥៥៥ ០៦០/០៩២ ៥៤៥ ២៣៥។*

▪*សហចុងចម្លើយ:* **ឈ្មោះ** *ភេទ ប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និង ប្រពន្ធ ឈ្មោះ អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ។*

## សូមគោរពចូល
## ឯកឧត្តមប្រធាន សាលាដំបូងខេត្តតាកែវ

**សូមធានជ្រាប!**

**កម្មវត្ថុ:** *សូមឲ្យតុលាការសម្រេចនូវសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:*

*១-បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ទៅឲ្យដើមចោទនូវទឹកប្រាក់ចំនួន ៧៨៤៦ដុល្លា (ប្រាំពីរពាន់ប្រាំបីរយសែសិបប្រាំមួយដុល្លាអាមេរិក) និងជំងឺចិត្តនិងការខាតបង់ពេលវេលាចំនួន២០,០០០,០០០(ម្ភៃលានរៀល) ។*

*២-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានភ្លាមៗទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។*

*៣-បង្គាប់ឲ្យសហចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី ។*

**យោង:** *កិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០*

*តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន* **ឯកឧត្តមប្រធាន** *មេត្តាជ្រាបថា:នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ សហចុងចម្លើយបានធ្វើកិច្ចសន្យាសងប្រាក់ដើមចោទ ដែលជាម្ចាស់ហាង ចាប់ពីថ្ងៃទី៣០ ខែ០៣ ឆ្នាំ២០២០ ក្នុងមួយខែចំនួន ១០០$(មួយរយដុល្លាអាមេរិក) រហូតដល់ថ្ងៃទី៣១ ខែ១២ ឆ្នាំ២០២២ អោយបានគ្រប់ចំនួន ៧៨៤៦$ (ប្រាំពីរពាន់ប្រាំបីរយសែសិបប្រាំមួយដុល្លាអាមេរិក) ។លុះដល់ថ្ងៃកំណត់ដែលត្រូវ*

ចង់ប្រចាំខែ បែរជាសហចុងចម្លើយគេចវេសមិនទទួលខុសត្រូវ ពេលកូនក្តីយើងខ្ញុំទៅសួរនាំសហចុងចម្លើយឆ្លើយថា គេមិនមានប្រាក់ទេ ប្តឹងដល់ណា ក៏ប្តឹងទៅ គេមិនខ្លាចឡើយ។

**ឯកឧត្តមប្រធានជាទីគោរព!**

ទង្វើរបស់សចុងចម្លើយ គឺមានចេតនាទុច្ចរិត គេចវេស មិនទទួលខុសត្រូវ ធ្វើអោយកូនក្តីយើងខ្ញុំអស់ជំនឿលើសហចុងចម្លើយទៀតហើយ ទើបដាក់ពាក្យបណ្តឹងមកតុលាការ ដើម្បីជួយរកយុត្តិធម៌ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវពាក្យបណ្តឹងរបស់យើងខ្ញុំ និងចាត់ការតាមនិតិវិធីច្បាប់ ដើម្បីផ្តល់យុត្តិធម៌ដល់កូនក្តីយើងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ខេត្តតាកែវ ថ្ងៃទី០៨ ខែ ០៧ ឆ្នាំ២០២៤

**ហត្ថលេខា និងត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW

# ឧបសម្ព័ន្ធទី២

## បង្កាន់បង់ប្រាក់

គំរូលេខ ០១ សហវ/ធមក

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ភ្ជាប់សំណុំរឿង)

260-1- 00106551

MEF19000109193

អង្គភាព ...

ទទួលពី ................ អង្គភាព ................ ( ................ )

ចំនួនទឹកប្រាក់ជាលេខ ........ 249,700 ........

ជាអក្សរ ........

អត្ថន័យចំណូល ........ 7,846$ ........ មាតិកាថវិកា ........

........ ថ្ងៃទី 10 ខែ 09 ឆ្នាំ 2020

អ្នកប្រមូលចំណូល

# ឧបសម្ព័ន្ធទី៣

## កំណាត់បញ្ចាញរឿង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

## <u>កំណត់បង្ហាញរឿង</u>

**<u>យោង៖</u>** -ដីកាសម្រេចលេខ **១១៧៣ រប/២០** ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

-សំណុំរឿងរដ្ឋប្បវេណីលេខ.....[illegible].....ចុះថ្ងៃទី.....14.....ខែ.....09.....ឆ្នាំ២០២០ ។

-សំណុំរឿងនេះដល់វេនលោក-លោកស្រី ..ជាចៅក្រមទទួលបន្ទុកតាមលំដាប់ ។

ថ្ងៃ.....[illegible].....ខែ.....[illegible].....ឆ្នាំជូត ទោស័ក ព.ស២៥៦៤
តាកែវ ,ថ្ងៃទី.....14.....ខែ.....09.....ឆ្នាំ ២០២០

**ប្រធានសាលាដំបូង**

# ឧបសម្ព័ន្ធទី៤

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..... .... អាយុ..40...ឆ្នាំ ជនជាតិ..ខ្មែរ.. សញ្ជាតិ..ខ្មែរ
មុខរបរ...................... មានទីលំនៅផ្ទះលេខ.................. ផ្លូវ............... ភូមិ..ព្រៃតាពាង.......
ឃុំ/សង្កាត់...ព្រៃឃ្នង........... ស្រុក/ខណ្ឌ.....ត្រាំកក់........... ខេត្ត/ក្រុង.....តាកែវ.............។

## សូមប្រគល់សិទ្ធិជូន

**លោកមេធាវី** អត្តលេខ ៦១៣ និង **លោកមេធាវី** អត្តលេខ ១២០៧ ដែលបំពេញការងារនៅ **ការិយាល័យមេធាវី** ធ្វើជា **តំណាងដោយអាណត្តិ** អោយខ្ញុំបាទ /នាងខ្ញុំ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ............... ចុះថ្ងៃទី.......... ខែ............. ឆ្នាំ២០.......... នៃសាលា/តុលាការ.......តាកែវ........... ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ មូលហេតុដោយខ្ញុំបាទ/នាងខ្ញុំ មិនសូវយល់ដឹងពីនីតិវិធីច្បាប់ដើម្បីការពារផលប្រយោជន៍ខ្លួនឯងបានឡើយ។

**បញ្ជាក់:** សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗនៅក្នុងបណ្តឹងនេះ ជាបន្ទុករបស់ខ្ញុំបាទជាអាណត្តិទាយក។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំសុខចិត្តទទួលខុសត្រូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

លោកមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តកិច្ចការអាណត្តិតាមច្បាប់ ដែលអាណត្តិទាយកបានប្រគល់ជូនដូចខាងលើ ចាប់ពីថ្ងៃផ្តិមេដៃ ឬ ចុះហត្ថលេខានេះតទៅ។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមលោក/លោកស្រី/កញ្ញាមេធាវី មេត្តាទទួលសិទ្ធិធ្វើជា **អ្នកតំណាងដោយអាណត្តិ** អោយខ្ញុំបាទ/នាងខ្ញុំ តាមផ្លូវច្បាប់ដោយក្តីអនុគ្រោះ។

សូមលោក/លោកស្រី/កញ្ញាមេធាវី ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

**ធ្វើនៅ..តាកែវ..... ថ្ងៃទី..08... ខែ.....02...... ឆ្នាំ២០20...**

**ស្នាមមេដៃស្តាំអ្នកប្រគល់សិទ្ធិ**

យល់ព្រមទទួលធ្វើជា **អ្នកតំណាងដោយអាណត្តិ**
ចាប់ពីថ្ងៃចុះហត្ថលេខា និងប្រថាប់នេះតទៅ។
ធ្វើនៅ..តាកែវ..... ថ្ងៃទី...08..... ខែ...02........ ឆ្នាំ២០20....

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.

មេធាវី.

# ឧបសម្ព័ន្ធទី៥

## ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
លេខ:...៤៤៣.../២០២០

# ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

យើង ចៅក្រមសាលាដំបូងខេត្តតាកែវ ។

**បានឃើញ** មាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៧ ០៦/០២១ ចុះថ្ងៃទី០៦.០៧.២០០៦ ។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

**ដើមចោទឈ្មោះ** ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នភូមិតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត ដោយមានលោក និងលោក ជាមេធាវីតំណាងដោយអាណត្តិ ។

**សហចុងចម្លើយឈ្មោះ** ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ អាយុ៣៤ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ។

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖**

១. បង្គាប់ឲ្យសហចុងចម្លើយសង ប្រាក់ទៅឲ្យដើមចោទនូវទឹកប្រាក់ចំនួន ៧៨៤៦$ (ប្រាំពីរពាន់ប្រាំបីរយសែសិបប្រាំមួយដុល្លារអាមេរិក) និងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ២០,០០០,០០០៛ (ម្ភៃលានរៀល) ។

២. សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានភ្លាមៗទោះបីជាមានបណ្ដឹងឧទរណ៍ ដោយ ។

៣. បង្គាប់ឲ្យសហចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដី ។

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**យល់ឃើញថា** ដើមចោទត្រូវបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ដើម្បីឲ្យតុលាការធ្វើការបញ្ជូនឯកសារផ្សេងៗ ឬធ្វើសកម្មភាពផ្សេងទៀតតាមបញ្ញត្តិ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**យល់ឃើញថា** នៅក្នុងសំណុំរឿងលេខ:២៤២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ ដើមចោទមិនទាន់បានបង់នូវប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនៅឡើយទេ ដែលនាំឲ្យតុលាការមិនទាន់អាចចាត់ការលើរឿងនេះបាននៅឡើយ ។

**យល់ឃើញថា** ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធជាចំនួនទឹកប្រាក់ចាំបាច់សម្រាប់ជាសោហ៊ុយក្នុងការអនុវត្តនីតិវិធី។

**យល់ឃើញថា** ដើម្បីឲ្យតុលាការមានលទ្ធភាពចាត់ការលើរឿងក្ដីទៅតាមនីតិវិធីបាន គប្បីបង្គាប់ឲ្យដើមចោទបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធជាមុនសិន។

## ហេតុដូច្នេះសម្រេច

១/បង្គាប់ឲ្យដើមចោទឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល មកសាលាដំបូងខេត្តតាកែវ (បន្ទប់ទី៨") ។

២. ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធត្រូវបង់ក្នុងរយៈពេល ០២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃទទួលដំណឹង បើហួសកាលកំណត់នេះយើងនឹងចេញដីកាសម្រេចលើកពាក្យបណ្ដឹងចោល ។

ថ្ងៃចន្ទ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

**តាកែវ, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០**

**ចៅក្រម**

# ឧបសម្ព័ន្ធទី៦

## ដីកាសម្រេចបង្គាប់ឲ្យកែតម្រូវនូវចំណុចខ្វះខាតពាក្យបណ្តឹង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
**លេខ៖**...២៣៤.../០៣២១

## ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ
## ចំណុចខ្វះខាតពាក្យបណ្តឹង

**យើង ជាចៅក្រមសាលាដំបូងខេត្តតាកែវ**

-បានឃើញមាត្រា៧៥ និងមាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៖ ៣៤២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០។

រវាងដើមចោទឈ្មោះ ភេទប្រុស អាយុ៦៨ឆ្នាំ មុខរបររត់ម៉ូតូ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

និងសហចុងចម្លើយឈ្មោះ ហៅ ភេទស្រី អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ និងឈ្មោះ ភេទស្រី អាយុ៥៣ឆ្នាំ ទីលំនៅភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

ដែលមានកម្មវត្ថុ៖ ប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រមដែលមានដូចខាងក្រោម៖

១-បង្គាប់ឱ្យសហចុងចម្លើយប្រគល់អចលនវត្ថុដែលមានក្បាលដីលេខ៖ ៣៦០ មានព្រំប្រទល់ខាងជើងទល់ផ្លូវលំ ខាងត្បូងទល់នឹងដីរួមគ្នា ខាងកើតទល់ឈ្មោះ និងខាងលិចទល់ឈ្មោះ និងដីដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវលំ ខាងត្បូងទល់ដីរួមគ្នា ខាងកើតទល់ឈ្មោះ និងខាងលិចទល់ឈ្មោះ ដែលដីទាំងពីរខាងលើនេះ មានទីតាំងស្ថិតនៅភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ មកឱ្យខ្ញុំបាទធ្វើជាកម្មសិទ្ធិតាមកិច្ចសន្យាលក់ទិញ។

២-ទាមទារជំងឺ និងការខាតបង់ពេលវេលាជាប្រាក់ក្នុងម្នាក់ៗចំនួន៤,០០០,០០០៛(បួនលាន) រៀល។

## សំអាងហេតុ

១-កម្មវត្ថុពុំមានមូលដ្ឋានច្បាស់លាស់។

## ជម្រាបមក

១-ដើមចោទឈ្មោះ ភេទប្រុស អាយុ៦៨ឆ្នាំ មុខរបររត់ម៉ូតូ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ឱ្យធ្វើការកែតម្រូវត្រង់ចំណុចខាងលើ ក្នុងរយៈពេល ២ (ពីរ) សប្តាហ៍ ជាកំណត់ គិតចាប់ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ដែលបានទទួលដំណឹងពីដីកាសម្រេចនេះ។

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
តាកែវ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១
**ចៅក្រម**

បានទទួល
ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
តាកែវ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១
**ស្នាមម្រាមដៃ**

# ឧបសម្ព័ន្ធទី៧

## ដីកាសម្រេចលើកបណ្តឹងចោល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

លេខ៖ /០៦២០ **ដីកាសម្រេចលើកពាក្យបណ្តឹងចោល**

## យើង ចៅក្រមសាលាដំបូងខេត្តតាកែវ

-បានឃើញមាត្រា៨២ ចែងពីការលើកបណ្តឹងចោលក្នុងករណីដែលមិនបានបង់ជាមុននូវប្រាក់សម្រាប់ធ្វើការកោះហៅតាមក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៖ ១០៤ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០

**១**-ដើមចោទឈ្មោះ ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅបច្ចុប្បន្ន ភូមិពោធិ៍ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ។

**២**-ចុងចម្លើយឈ្មោះ ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិពោធិ៍ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ។

**កម្មវត្ថុ៖ ទាមទារឱ្យតុលាការចេញសាលក្រមដែលមានដូចខាងក្រោម៖**

-សុំបើកផ្លូវ៣ម៉ែត្រ គុណនឹង១៣,៥០ម៉ែត្រ តាមសម្រង់សាលក្រមរដ្ឋប្បវេណីលេខ៖ ០៨ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១។

-តុលាការយល់ឃើញថា ដើម្បីដំណើរការនីតិវិធីនៃរឿងក្តីនេះ ដើមចោទមានកាតព្វកិច្ចបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធជាមុន។

## សំអាងហេតុ

**១**-កម្មវត្ថុក្នុងពាក្យបណ្តឹងរបស់ឈ្មោះ ជូ ឡៃ ជាកម្មវត្ថុខុសច្បាប់ (អាជ្ញាអស់ជំនុំ) ដែលមិនអាចប្តឹងបាន។

**២**-ប្រាក់ប្រដាប់ក្តីអនុវត្តតាមបញ្ញត្តិមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សម្រេច

**១**-លើកចោលសំណុំរឿងរដ្ឋប្បវេណីលេខ៖ ១០៤ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ មិនចាត់ការណ៍។

**២**-រឹបអូសប្រាក់ពន្ធដាក់ពាក្យសុំចំនួនពាក់កណ្តាល ដែលដើមចោទបានបង់ទុករួច តាមបញ្ញត្តិមាត្រា**៦១** នៃក្រមនីតិវិធីរដ្ឋប្បវេណី៕

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ខេត្តតាកែវ,ថ្ងៃទី ខែ ឆ្នាំ២០២០

**ចៅក្រម**

# ឧបសម្ព័ន្ធទី០៨

## សាលក្រមលើកបណ្ដឹងចោល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សំណុំរឿងរដ្ឋប្បវេណី
លេខ ៣០ ចុះថ្ងៃទី ២៥
ខែ មករា ឆ្នាំ ២០២១
សាលក្រមរដ្ឋប្បវេណី
លេខ.........០៤..........(ញ)
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២១

## ចៅក្រម

លោក ចៅក្រមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជី

លោក ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

-ដើមចោទឈ្មោះ ភេទស្រី កើតឆ្នាំ១៩៩៤ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន ភូមិព្រៃទទឹង ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ។

-ចុងចម្លើយឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៩៤ ជាតិខ្មែរ មានអាសយដ្ឋាន បច្ចុប្បន្នភូមិព្រៃទទឹង ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១-ការទាមទាររបស់ដើមចោទ:

-ប្តឹងសុំតុលាការចេញសាលក្រមលែងលះ ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

២-ការពន្យល់ត្រួសៗអំពីរឿងក្តី

ក្នុងរឿងក្តីនេះដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមលែងលះ (ការទាមទាររបស់ដើមចោទ) ដោយហេតុថា ខ្លួនបានរៀបការជាមួយប្តីឈ្មោះ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១៧ តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ប៉ុន្តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានត្រឹមត្រូវតាមច្បាប់ទេ ។ ក្នុងការរស់នៅជាមួយគ្នាមិនមានកូនឡើយ ។ ក្រោយមកការរស់នៅជាមួយ គ្នាមិនសចុះសម្រុងតែងតែមានរឿងរកាំរកោស និងឈ្លោះគ្នាជាញឹកញាប់ ហើយប្តីរបស់ខ្លួនចេះតែលេងល្បែងមិន គិតជួយរកស៊ីចិញ្ចឹមគ្រួសារ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនា និងរស់នៅជាប្តីប្រពន្ធតទៅទៀតហើយ ។

៣-ចំណុចវិវាទ

-ក្នុងរឿងក្តីនេះពុំមានចំណុចវិវាទទេ។

៤-ការអះអាងរបស់គូភាគី

៤-១.ការអះអាងរបស់ដើមចោទ

-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ តាមទំនៀមទំលាប់ប្រពៃណីខ្មែរ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវច្បាប់នោះទេ បន្ទាប់ពីរៀបការរួចរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបានរយៈពេល១ឆ្នាំ ក៏ចាប់ផ្តើមមានរឿងរកាំរកូសក្នុងគ្រួសារដោយសារតែឈ្មោះ ជាប្តីមិនគិតគូររកស៊ី ដើម្បីអនាគតគ្រួសារទេ បែរជាបែកគំនិតគិតតែពីដើរស៊ីផឹកជាមួយមិត្តភ័ក្រ្តលេងល្បែងស៊ីសង (ជល់មាន់ លេងបៀរ លេងអាប៉ោង) បំផ្លាញលុយកាក់គ្រួសារ និងចេះតែចុះចោលពីខ្លួនទៅនៅជាមួយឪពុកម្តាយរបស់គាត់នៅភូមិបាណា ឃុំសីង្ហ ដែលជាស្រុកកំណើតបាត់ៗនៅពេលខ្លួនស្តីប្រដៅ និងហាមរឿងដើរលេង និងលេងល្បែងស៊ីសង គាត់មិនដែលស្តាប់ ខ្លួននោះទេ ខ្លួនមិនអាចទ្រាំរស់នៅជាមួយគ្នាបន្តទៀត ទើបខ្លួនសម្រេចចិត្តដាក់ពាក្យប្តឹងសុំលែងលះនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍របស់ខ្លួនរយៈពេល០៤ឆ្នាំ ប៉ុន្តែខ្លួនបានរួមរស់ជាមួយគ្នាត្រឹមរយៈពេល១ឆ្នាំ គឺពួកខ្លួនមិនមានកូននោះទេ ចំណែកឯកទ្រព្យសម្បត្តិ និងបំណុលក៏គ្មានដែរ។

-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍តបបន្ថែមថា ខ្លួនសូមបដិសេធចំពោះការលើកឡើងរបស់ចុងចម្លើយ ដោយគាត់បានឱ្យប្រាក់មកខ្លួន ត្រឹមតែ ៦,០០០.០០០ (ប្រាំមួយលាន)រៀល តែប៉ុណ្ណោះដែលគាត់ឱ្យមក គឺដើម្បីតសំយ៉ាប់ផ្ទះ។

៤-២.ការអះអាងរបស់ចុងចម្លើយ

-ចុងចម្លើយឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍តបថា ខ្លួនសូមបដិសេធចំពោះការលែងលះពីដើមចោទ ចំណែកទ្រព្យសម្បត្តិរួមដែលដើមចោទលើកឡើងថាគ្មាន គឺមិនពិតនោះទេ ដែលតាមការពិតក្រោយរៀបអាពាហ៍ពិពាហ៍ ខ្លួនបានធ្វើដំបូលផ្ទះ និងរោងតតាកចាក់សាបពីក្រោយផ្ទះ ដែលសរុបជាទឹកប្រាក់ចំនួន ៤០០០ (បួនពាន់)ដុល្លារ អាមេរិក ចំណែកឯបំណុល និងកូនគឺពុំមានពិតមែន។

## សំអាងហេតុ

-តាមលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ឃើញថា:

១-តាមការអះអាងរបស់ដើមចោទឈ្មោះ ភេទស្រី និងចុងចម្លើយឈ្មោះ ភេទប្រុស បានបញ្ជាក់ថា ពិតជាបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ពិតប្រាកដមែន តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានត្រឹមត្រូវតាមច្បាប់នោះទេ ។ ការដែលគូភាគីមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះបានន័យថាគូភាគីមិនមានចំណងអាពាហ៍ពិពាហ៍នោះទេ គឺរស់នៅជាមួយគ្នាបែបអនីតិសង្វាសប៉ុណ្ណោះ ។ ការប្តឹងសុំរបស់ដើមចោទត្រង់ចំណុចសុំឈប់រស់នៅជាអនីតិសង្វាស គឺជាបណ្តឹងខុសច្បាប់ហើយពុំអាចកែតម្រូវបានឡើយ។ ហេតុនេះ គប្បីតុលាការសម្រេចលើកចោលតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួមរស់នៅជាមួយគ្នាបានរយៈពេល ១ឆ្នាំ ភាគីទាំងសងខាងក៏ចាប់ផ្តើមឈ្លោះទាស់ទែងគ្នា ដោយចុងចម្លើយឈ្មោះ មិនគិតគូររកស៊ី ចេះតែដើរលេងផឹកស៊ីជាមួយមិត្តភ័ក្រ្ត លេងល្បែងស៊ីសងបំផ្លាញលុយកាក់គ្រួសារ និងចេះតែចុះចោលផ្ទះពីដើមចោទ ជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនា និងរួមរស់នៅជាប្តីប្រពន្ធ តទៅទៀតហើយ ។

៣-ផ្អែកតាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ បានបញ្ជាក់ថា ពួកខ្លួនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី ប៉ុន្តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះទេ។ ដោយគូភាគី មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ មានន័យថា គូភាគីពុំមានជាប់ចំណងគតិយុត្តតាមផ្លូវច្បាប់ដើម្បីឱ្យតុលាការសម្រេចបានឡើយ។

ហេតុដូច្នេះ គូភាគិមានសិទ្ធ នឹងសេរីភាពពេញលេញក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួន ដោយភាគីម្ខាងទៀតគ្មានសិទ្ធិជំទាស់ឡើយ។

៤-ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-លើកចោលបណ្តឹង ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១ របស់ដើមចោទឈ្មោះ              ជាអសារបង់តាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ គូភាគីអាចប្តឹងឧទ្ធរណ៍តាមមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

តាកែវ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២១

**ចៅក្រម**

# ឧបសម្ព័ន្ធទី០៩

## ដីកាកោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

# ដីកាកោះ

ជូនចំពោះឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត។

| | |
|---|---|
| សញ្ញាណនៃរឿងក្តី និងភាគី | សំណុំរឿងរដ្ឋប្បវេណីលេខៈ ២៤២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០<br>ដើមបណ្តឹងឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ។<br>ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ និងប្រពន្ធឈ្មោះ អាយុ៣៨ឆ្នាំ។ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | នៅថ្ងៃទី...24...... ខែ...ធ្នូ.....ឆ្នាំ២០២០ វេលាម៉ោង......8...ព្រឹក...<br>សាលាដំបូងខេត្តតាកែវ ☐សាលសវនាការ ☑បន្ទប់ចៅក្រមទី៨ |
| ប្រភេទនៃកាលបរិច្ឆេទ "សំគាល់ដោយសញ្ញា☑" | ☑ការទាញហេតុផលដោយផ្ទាល់មាត់ ☐ការផ្សះផ្សារ<br>☐ នីតិវិធីត្រៀម ☐ការសាកសួរ |
| ប្រភេទនៃឯកសារដែលភ្ជាប់មកជាមួយ "សំគាល់ដោយសញ្ញា☑" | ☑ ឯកសារស្តីពីចំណុចនៃការសាកសួរ<br>☐ ឯកសារស្តីពីចំណុចនៃការធ្វើកោសលវិច័យ |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបង្ហាញខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការកោះហៅរបស់តុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការនឹងច្រានចោលការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខ/ បញ្ឈប់នីតិវិធីត្រៀមហើយកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់លើកទី១ តាមមាត្រា ២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>-បើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការកោះហៅរបស់តុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការនឹងបញ្ឈប់នីតិវិធីត្រៀមហើយកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់លើកទី១/ ចាត់ទុកថាចុងចម្លើយបានសារភាព ហើយតុលាការនឹងទទួលស្គាល់ការទាមទាររបស់ដើមចោទតាមមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |

សូមបង្ហាញខ្លួនដូចបានកំណត់ខាងលើ។

បានទទួលថ្ងៃទី03-12-2020

ថ្ងៃ.....................ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
តាកែវ, ថ្ងៃទី...30......ខែវិច្ឆិកា ឆ្នាំ២០២០
**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

# ដីកាកោះ

**ជូនចំពោះ** សហចុងចម្លើយឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ និងប្រពន្ធឈ្មោះ អាយុ៣៤ឆ្នាំ អាសយដ្ឋានភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ។

| | |
|---|---|
| សញ្ញាណនៃរឿងក្តី និងភាគី | សំណុំរឿងរដ្ឋប្បវេណីលេខៈ២៤២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ ។<br>**ដើមចោទឈ្មោះ** ភេទប្រុស អាយុ៤០ឆ្នាំ ។<br>**សហចុងចម្លើយឈ្មោះ** ភេទប្រុស អាយុ៣៥ឆ្នាំ និងប្រពន្ធឈ្មោះ អាយុ៣៤ឆ្នាំ ។ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | នៅថ្ងៃទី២០.. ខែ.តុលា.... ឆ្នាំ២០២០ វេលាម៉ោង៧ព្រឹក......<br>សាលាដំបូងខេត្តតាកែវ ☐សាលសវនាការ ☑បន្ទប់ចៅក្រមទី៨ |
| ប្រភេទនៃកាលបរិច្ឆេទ "សំគាល់ដោយសញ្ញា☑" | ☐ការទាញហេតុផលដោយផ្ទាល់មាត់ ☐ការផ្សះផ្សារ<br>☑ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ☐ការសាកសួរ |
| ប្រភេទនៃឯកសារដែលភ្ជាប់មកជាមួយ "សំគាល់ដោយសញ្ញា☑" | ☑ ឯកសារស្តីពីចំណុចនៃការសាកសួរ<br>☐ ឯកសារស្តីពីចំណុចនៃការធ្វើកោសលវិច័យ |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបង្ហាញខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ | -បើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទ នៃការកោះហៅទេ តុលាការនឹងបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។ |

សូមបង្ហាញខ្លួនដូចបានកំណត់ខាងលើ។

ថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
តាកែវ,ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០
**ចៅក្រម**

# ឧបសម្ព័ន្ធទី១០

## របាយការណ៍បញ្ជូន

# របាយការណ៍ស្តីពីការបញ្ជូន

ប្រអប់ខាងក្រោមនេះបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី០៥ ខែ.តុលា.... ឆ្នាំ២០២០ |
| សំណុំរឿងរដ្ឋប្បវេណីលេខ:២៤២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ |
| ឈ្មោះឯកសារដែលត្រូវបញ្ជូន : **ដីកាកោះ** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ និងពាក្យបណ្តឹង |
| អ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ក្រឡាបញ្ជី |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សាលាដំបូងខេត្តតាកែវ |
| ឈ្មោះជនត្រូវទទួលការបញ្ជូន : ភេទប្រុស អាយុ៣៥ឆ្នាំ និងប្រពន្ធ អាយុ៣៤ឆ្នាំ |

ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង : .............................................

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន | |
| កាលបរិច្ឆេទនៃការបញ្ជូន | |
| ☑១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | □ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| □២ | បានប្រគល់ប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | □អ្នកបម្រើ □អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ □អ្នកនៅជាមួយ |
| | ឈ្មោះ |
| □៣ | ឯកសារត្រូវបានទុកនៅកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | □ជនដែលត្រូវទទួលការបញ្ជូន □អ្នកបម្រើ □ អ្នកនៅជាមួយ □អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ |
| | ឈ្មោះ |
| □ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | |
| □ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។ | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ ថ្ងៃទី....... ខែ................ ឆ្នាំ២០២០ | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ :............................... | |

# ឧបសម្ព័ន្ធទី១១

## លិខិតអញ្ជើញមេធាវី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

# លិខិតអញ្ជើញ

យើង ចៅក្រមនៃសាលាដំបូងខេត្តតាកែវ ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខៈ ២៤២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ។

បានឃើញលិខិតតំណាងដោយអាណត្តិចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ។

អញ្ជើញលោក និងលោក មានការិយាល័យស្ថិតនៅភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ។

ចូលមកសាលាដំបូងខេត្តតាកែវ ( បន្ទប់ចៅក្រមទី០៨ ) នៅថ្ងៃទី...24... ខែ...ធ្នូ...... ឆ្នាំ ២០២០ ម៉ោង......8...ព្រឹក......... ដើម្បីចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។

សូមលោកអញ្ជើញមកអោយទាន់ពេលវេលាកំណត់។

ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
តាកែវ, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០
**ចៅក្រម**

បានទទួល
ថ្ងៃទី.............ខែ.................ឆ្នាំ២០២០
ហត្ថលេខា

# ឧបសម្ព័ន្ធទី១២

## កំណាត់ហេតុសះជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សំណុំរឿងរដ្ឋប្បវេណីលេខ១២៥

ចុះថ្ងៃទី១៥-០៥-២០

## កំណត់ហេតុសះជា

បានឃើញក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃ ទី០៦ ខែកក្កដា ឆ្នាំ២០០៦។

វេលាម៉ោងប្រាំបួនព្រឹក ថ្ងៃទីប្រាំបួន ខែធ្នូ ឆ្នាំពីរពាន់ម្ភៃ នៅសាលាដំបូងខេត្តតាកែវ លោកស្រី ចៅក្រមសាលាដំបូងខេត្តតាកែវ អមដោយលោក **ស៊ី សារឿន** ជាក្រឡាបញ្ជី បានចេញកំណត់ហេតុសះជាលើសំណុំរឿង រដ្ឋប្បវេណីលេខ១២៥ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ រវាង:

**-ដើមចោទ** ភេទប្រុស អាយុ៧២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិដើមដូង ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ។

**-លោកមេធាវី** ជាអ្នកតំណាងដោយអាណត្តិ។

**និង**

**-ចុងចម្លើយឈ្មោះ** ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិតាំងឫស្សី ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ។

**-លោកមេធាវី** ជាអ្នកតំណាងដោយអាណត្តិ។

### សញ្ញាណរឿងក្តី

**កម្មវត្ថុបណ្តឹង :** ដើមចោទប្តឹងសុំតុលាការចេញសាលក្រម :

**១-**បង្គាប់ឱ្យចុងចម្លើយ បង់ប្រាក់បង្គ្រប់ថ្លៃដីចំនួន USD ២២.០០៥ (ពីរម៉ឺន ពីរពាន់ ប្រាំដុល្លារអាមេរិក) ។

**២-**ករណីភាគីចុងចម្លើយមិនព្រមបង់ប្រាក់ក្នុងចំនុចទីមួយខាងលើ ភាគីចុងចម្លើយត្រូវប្រគល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុដែលមានក្បាលដីលេខ៨២៩ មានទីតាំងស្ថិតនៅភូមិដើមដូង ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ឱ្យភាគីដើមចោទវិញ ហើយប្រាក់ដែលបានបង់ឱ្យភាគី ដើមចោទរួចហើយទុកជាប្រយោជន៍របស់ភាគីដើមចោទ។

**៣-**បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ថ្លៃខាតបង់ពេលវេលា សេវាកម្មផ្នែកច្បាប់ និងសោហ៊ុយជម្ងឺចិត្តចំនួន ៤០.០០០.០០០ (សែសិបលានរៀល) ឱ្យមកភាគីដើមចោទ។

៤-ប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ភាគីចុងចម្លើយ ។

៥-ការទាមទារចំនុចទី២ និងទី២ខាងលើ ប្រកាសអនុវត្តជាបណ្តោះអាសន្ន ។

**សេចក្តីថ្លែងការណ៍របស់គូភាគី**

**-លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ :** ឈ្មោះ បានជំពាក់ប្រាក់ថ្លៃទិញដីរបស់កូនក្តីខ្លួនចំនួន USD ២.២០៥(ពីរម៉ឺនពីរពាន់ ប្រាំដុល្លារអាមេរិក) ដូចនេះខ្លួនស្នើសុំឱ្យភាគីចុងចម្លើយបង់ប្រាក់បង្គ្រប់ថ្លៃទិញដីនេះមកឱ្យកូនក្តីរបស់ខ្លួនវិញ ។ ចំពោះប្រាក់សំណងជម្ងឺចិត្តកូនក្តីរបស់ខ្លួននៅតែរក្សាការទាមទារចំនួន ៤០.០០០.០០០ រៀល (សែសិបលាន) ដដែល ។

**-ចុងចម្លើយឈ្មោះ** **បានធ្វើសេចក្តីថ្លែងការណ៍ថា :** ខ្លួនទទួលស្គាល់ការទាមទាររបស់ដើមចោទ ។ មូលហេតុដែលខ្លួនមិនបានសងប្រាក់ទៅដើមចោទព្រោះខ្លួនបង្វិលលុយមិនទាន់ ។ ក្នុងរឿងនេះខ្លួនសូមបង់ប្រាក់ឱ្យដើមចោទជាពីរដំណាក់កាល គឺបង់នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ ចំនួន USD ១.២០០៥ (មួយម៉ឺនពីរពាន់ប្រាំដុល្លារអាមេរិក) និងបង់នៅសប្តាហ៍ទី០៩ ខែកុម្ភៈ ឆ្នាំ២០២០១ ចំនួន USD ១០.០០០ (មួយម៉ឺនដុល្លារអាមេរិក) ដើម្បីបញ្ចប់រឿង ។ ចំពោះការទាមទារប្រាក់សំណងជម្ងឺចិត្ត ខ្លួនសូមប្រគល់ឱ្យដើមចោទចំនួន ១០.០០០.០០០ រៀល(ដប់បីលាន) ដោយស្នើសុំអនុវត្តនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ ចំនួន ៥.០០០.០០០រៀល (ប្រាំលាន) និងនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០១ ចំនួន ៥.០០០.០០០ រៀល (ប្រាំលាន) ។

**-ដើមចោទឈ្មោះ** **បានធ្វើសេចក្តីថ្លែងការណ៍តបថា :** ខ្លួនសុខចិត្តទទួលយកការស្នើសុំរបស់ចុងចម្លើយ និងការផ្សះផ្សារបស់តុលាការប៉ុន្តែសុំឱ្យចុងចម្លើយសងប្រាក់មកខ្លួនឱ្យបានទៀងទាត់តាមការសន្យា ។

**ខ-ការពិនិត្យភស្តុតាង**

**ខ-១- ឯកសារជាភស្តុតាងរបស់ភាគីដើមចោទ :**

-លិខិតប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ។

**ខ-២- ឯកសារជាភស្តុតាងរបស់ភាគីចុងចម្លើយ :** គ្មាន ។

**តាមកំណត់ហេតុនៃនីតិវិធីនៃការត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ និងក្រោយពីបានផ្សះផ្សារ ផ្តល់យោបល់សះជារួចមក គូភាគីបានព្រមព្រៀងគ្នាដូចខាងក្រោម :**

**១**-ដើមចោទសុខចិត្តទទួលយកសំណងពីចុងចម្លើយ ដែលស្នើសុំបង់ប្រាក់ដែលនៅសល់ ជាពីរដំណាក់កាល គឺបង់នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ ចំនួន USD ១.២០០៥ (មួយម៉ឺនពីរ ពាន់ប្រាំដុល្លារអាមេរិក) និងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០១ ចំនួន USD ១០.០០០ (មួយម៉ឺនដុល្លារ អាមេរិក) ដើម្បីបញ្ចប់រឿង ។

**២**-ចំពោះប្រាក់សំណងជម្ងឺចិត្ត ដើមចោទឯកភាពទទួលយកពីចុងចម្លើយចំនួន ១០.០០០.០០០ រៀល (ដប់បីលាន) ដោយអនុវត្តនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ ចំនួន ៥.០០០.០០០រៀល (ប្រាំលាន) និងនៅថ្ងៃ

ទី០៩ ខែកុម្ភៈ ឆ្នាំ២០២០១ ចំនួន ៥.000.000 រៀល ( ប្រាំលាន) ។

៣-ភាគីដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាអនុវត្តដោយស្ម័គ្រចិត្តនូវចំនុចទី១, ទី២ ខាងលើនេះ។

**តាមបញ្ញត្តិមាត្រា២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ត្រាសះជាក្នុងកំណត់ហេតុសះជានេះ មានអនុភាពអនុវត្តដូចគ្នានឹងសាលក្រមស្ថាពរ ។**

បញ្ឈប់កំណត់ហេតុសះជានេះ នៅវេលាម៉ោងដប់មួយ នាព្រឹកថ្ងៃ ខែ ឆ្នាំដដែល ។

យើងបានអានកំណត់ហេតុនេះឱ្យគូភាគីស្តាប់ ហើយឆ្លើយថាត្រឹមត្រូវ និងសុខចិត្តផ្តិតមេដៃជាមួយយើង ។

**ដើមចោទ មេធាវីតំណាងដោយអាណត្តិ**

**ចុងចម្លើយ មេធាវីតំណាងដោយអាណត្តិ**

**ក្រឡាបញ្ជី**

**ចៅក្រម**

# ឧបសម្ព័ន្ធទី១៣

## កំណាត់ហេតុ

## ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ,លើកទី២

## និង

## សេចក្តីថ្លែងការណ៍

## សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តតាកែវ
សំណុំរឿងរដ្ឋប្បវេណីលេខ:១១៧
ចុះថ្ងៃទី៤០-០៥-២០២០

# កំណត់ហេតុ
# នៃនីតិវិធីត្រៀមសំរាប់ទាញហេតុផល

បានឃើញមាត្រា១១០ ដល់មាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

## សញ្ញាណរឿងក្តី

ដើមចោទប្តឹងសុំតុលាការចេញសាលក្រមៈ

-សម្រេចឱ្យចុងចម្លើយរុះរើសំណង់ និងឈប់រស់នៅលើដីសាលាមតេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ។

លោកស្រី ចៅក្រមសាលាដំបូងខេត្តតាកែវ

លោក ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

-ដើមចោទឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧២ មុខរបរនាយកសាលាមតេយ្យឈើទាល ទីលំនៅបច្ចុប្បន្ន ភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

-ចុងចម្លើយឈ្មោះ ភេទស្រី អាយុ...62...ឆ្នាំ ថ្ងៃខែឆ្នាំកំណើត១៩៥៨ ជនជាតិខ្មែរ មុខរបរបុគ្គលិកមេផ្ទះ ទីលំនៅបច្ចុប្បន្ននៅភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

ឆ្នាំពីរពាន់ម្ភៃ ខែវិច្ឆិកា ថ្ងៃទីម្ភៃប្រាំមួយ វេលាម៉ោងប្រាំបួន និងដប់ប្រាំនាទី ព្រឹក នៅសាលាដំបូងខេត្តតាកែវ បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់**រវាងដើមចោទ និងចុងចម្លើយដូចតទៅ:**

-ភាគីដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា:ខ្ញុំសូមធ្វើសង្ខេបជូនពីប្រវត្តិនៃដីដូចតទៅ៖ តាំងពីឆ្នាំ១៩៨០ សាលាបឋមសិក្សាប្រហ៊ូត ហៅដើមស្លែង នៅលើដីទំនាស់នេះ អស់រយៈពេល៤ទៅ៥ឆ្នាំ។ ដោយហេតុថាមានកំណើនសិស្សកើតច្រើន សាលាបានផ្លាស់ប្តូរទីតាំងទៅបង្រៀនរៀនៅវត្តឈើទាល ដោយយកទីតាំងវត្តបង្រៀនជាបណ្តោះអាសន្ន។ ក្រោយមកទៀត នៅពេលដែលគណៈកម្មការវត្ត មានលុយក៏បានសាងសង់អាគារសាលានៅក្នុងទីតាំងវត្តឈើទាលស្ថិតនៅខាងត្បូងវត្ត ចំនួនមួយខ្នង់ មាន១៥បន្ទប់ ឆ្នាំ១៩៩០។ លុះនៅឆ្នាំ២០១៧ ក្រោយពីទទួលបានការឯកភាពពីក្រសួងអប់រំឱ្យបង្កើតសាលាមតេយ្យប្រហ៊ូតឡើងវិញ ខ្ញុំបាទត្រ

ឡប់ទៅធ្វើការសាងសង់សាលាមតេយ្យសិក្សាប្រហ៊ូតពីមុន ក្រោមជំនួយរបស់ធនាគារកូរ៉េ។ ពេលនោះ មានប្រជាជនប្រាំគ្រួសាររស់នៅលើដីសាលារៀន នៅថ្ងៃទី១ សីហា ឆ្នាំ២០១៧ ខ្ញុំបានអញ្ជើញប្រជាជនទាំងប្រាំគ្រួសារមកធ្វើការសម្របសម្រួល ដើម្បីសុំដីសាលារៀនមកវិញ ប៉ុន្តែមានតែបួនគ្រួសារប៉ុណ្ណោះដែរសុខចិត្តព្រមប្រគល់ គឺលោកស្រី លោកយាយ និងលោក លោក ដោយឡែក លោកស្រី មិនឯកភាពទេ ហើយបន្តរស់នៅលើដីដល់បច្ចុប្បន្ន។ ខ្ញុំជានាយកសាលាបឋមសិក្សាឈើទាលទីបួន ខ្ញុំសូមជម្រាបថា សាលាមតេយ្យប្រហ៊ូត ហៅដើមស្លែង ជាសហព័ន្ធរបស់សាលាបឋមសិក្សាឈើទាល ដែលស្ថិតក្រោមការឧបត្ថម្ភធននាគារកូរ៉េ គឺសាលាមតេយ្យសិក្សាប្រហ៊ូតសហព័ន្ធធននាគារកូរ៉េ ខ្ញុំមិនបានដឹងពីទំហំច្បាស់លាស់បានរំលោភកាន់កាប់ទេ ប៉ុន្តែបើតាមការសាកសួរនាយកសាលាមុនៗគឺ ដីរំភទនេះមានទំហំទទឹង៣៤ ម៉ែត្រ និងបណ្តោយ២៥ ម៉ែត្រ។ តាមការពិនិត្យជាក់ស្តែងឃើញថា ចុងចម្លើយមានផ្ទះចំនួនពីរខ្នងគឺផ្ទះឈើមួយ និងផ្ទះថ្មមួយ ដែលបច្ចុប្បន្នផ្ទះថ្មមានទំហំ៥ម៉ែត្រ គុណនឹង៧១២ម៉ែត្រ និងផ្ទះឈើទំហំ៥ គុណនឹង៧ ម៉ែត្រ។ បើតាមខ្ញុំដឹងនាយកសាលាឈ្មោះ និងនាយកសាលាទី២ ឈ្មោះ បានអនុញ្ញាតឱ្យលោកស្រី រស់នៅ ប្រហែលឆ្នាំ១៩៩៧។ ពេលនោះ ដីនៅទំនេរ ក្រោយមកមានប្រជាជនស្នាក់នៅច្រើន និងអាស្រ័យផល។ ខ្ញុំសូមបញ្ជាក់ថាក្នុងអំឡុងឆ្នាំ២០១៩ ចុងចម្លើយបានសាងសង់ផ្ទះថ្មថ្មី ទំហំ៥ គុណនឹង១២ម៉ែត្រ ពេលនោះខ្ញុំនឹងគណៈកម្មការសាលារួមទាំង និងអាជ្ញាធរភូមិឃុំបានធ្វើការហាមឃាត់គាត់មិនឱ្យសាងសង់ ប៉ុន្តែក្រោយពីជាងសំណង់។ ថ្ងៃក្រោយមកគាត់បានជួលជាងផ្សេងទៀត ដើម្បីបង្ហើយសំណង់។ ខ្ញុំសូមអះអាងថា ក្នុងនាមជានាយកការស្នើសុំទាមទារដីសាលាមកវិញនេះ គឺដើម្បីប្រយោជន៍រួមរបស់ប្រជាជនក្នុងភូមិ មិនមែនក្នុងគោលបំណងយកធ្វើជាកម្មសិទ្ធិខ្លួនផ្ទាល់ខ្លួនទេ។ ការប្តឹងនេះ គឺដើម្បីប្រយោជន៍រួម ហើយសូមតុលាការសម្រេចប្រគល់ទៅតាមច្បាប់ចុះ។ ខ្ញុំមានលោកមេភូមិ និងចៅអធិការវត្ត និងអាជ្ញាធរភូមិឃុំ ដើម្បីបំភ្លឺក្នុងនាមជាកសិណសាក្សី ។

-ចុងចម្លើយឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្ញុំសូមជ្រាបតុលាការថាតាំងពីឆ្នាំ១៩៩៧ ខ្ញុំបានត្រឡប់មកពីខេត្តកោះកុង ខ្ញុំបានសុំលោកមេភូមិឈ្មោះ រស់លើដីទំនាស់ ដីនេះមានទំហំ ៥០ គុណនឹង៥០។ នៅពេលដែលក្រុមយុវជនចុះវាស់វែង ហើយខ្ញុំបានសុំឱ្យក្រុមយុវជនវាស់វែងជូន តែក្រុមយុវជនបានប្រាប់ថាដីនេះជាដីមានទំនាស់មិនអាចវាស់វែងបានទេ។ នៅពេលនោះ ខ្ញុំមិនបានសួរក្រុមយុវជនថា ដីនេះមានទំនាស់ជាមួយអ្នកណាទេ នៅអំឡុងឆ្នាំ២០១៧ ខាងសាលាបានហៅខ្ញុំទៅប្រជុំនៅពេលនោះមានប្រជាជនផ្សេងៗទៀតដែរ ប៉ុន្តែខ្ញុំមិនចាប់អារម្មណ៍ថាគេនិយាយពីអ្វីដែរ ខ្ញុំក៏មិនព្រមផ្តិតមេដៃឱ្យខាងសាលា។ នៅអំឡុងឆ្នាំ២០១៩ ខែកញ្ញា ខ្ញុំបានសាងសង់ផ្ទះថ្មមួយខ្នងលើដីទំនាស់នោះ ដោយហេតុថា ផ្ទះឈើរបស់ខ្ញុំពុក។ ក្នុងអំឡុងពេលដែលខ្ញុំកំពុងសាងសង់ មានខាងសាលាក្រុង ឃុំ-សង្កាត់ ខាងសាលា ទៅធ្វើការហាមឃាត់ចំនួនបីលើក លុះដល់ឆ្នាំ២០២០ ខែមករា ខ្ញុំបានរកជាងថ្មីសាងសង់ផ្ទះនោះរហូតចប់ជាស្ថាពរ។ ខ្ញុំ

បានឃើញសាលាមគេយ្យសាងសង់ដែរនៅឆ្នាំ២០១៧ ខ្ញុំមិនបានដឹងថាដីនេះជាដីរបស់សាលារៀនទេ ខ្ញុំបានដឹងនៅពេលដែលមានពាក្យបណ្តឹងប្តឹងខ្ញុំនៅតុលាការ។ ខ្ញុំមិនព្រមប្រគល់ដីនេះទៅខាងសាលាទេ ទាល់តែមានថ្នូរដោះដូរណាមួយទើបនាងខ្ញុំព្រម។

**ចំណុចវិវាទនៃរឿងក្តី:**

..........................................................................................................................................

យើងបានបញ្ចប់នីតិវិធីត្រៀមសំរាប់ការទាញហេតុផល នៅវេលាម៉ោង ដប់មួយ និងប្រាំនាទី ព្រឹក ដោយបានអានឲ្យសាមីខ្លួនថា ពិតជាត្រឹមត្រូវហើយ យល់ព្រមផ្តិតមេដៃជាមួយយើង ។

យើងកំណត់យកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង៨ និង ៣០នាទី ព្រឹក ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២។

| ដើមចោទ | ចុងចម្លើយ | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|

សាលាដំបូងខេត្តតាកែវ
លេខ.....2543.................
បាន ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០..
ម៉ោង :...10...: 30.........

## សេចក្តីថ្លែងការណ៍សម្រាប់និតិវិធីត្រៀមសម្រាប់ទាញហេតុ និង ផល

ខ្ញុំបាទ ជានាយកសាលាបឋមសិក្សាឈើទាលនិង សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធន៍ធនាគារកូរ៉េសូមរាយការណ៍ពីប្រវត្តិសាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធន៍ធនាគារកូរ៉េដូចតទៅៈ

- នៅកំឡុងឆ្នាំ១៩៨០ លោក មេភូមិប្រហ៊ូតមានគម្រោងសាងសង់សាលារៀនគាត់បានសុំដោះដូរដីលំនៅដ្ឋានពីលោកតា និង លោកយាយ ដោយឲ្យលោកតាទៅរស់នៅលើដីសមាគមន៍ភូមិវិញដើម្បីពង្រីកដីបានធំសម្រាប់សាងសង់សាលារៀន ក្រោយមកលោកមេភូមិ និង សហគមន៍បានកសាងសាលារៀន១(មួយខ្នង)ស្មើនឹង៣(បីបន្ទប់) នៅលើដីនេះដោយប្រក់ក្បឿង។សាលារៀននេះបានដំណើរការប្រហែល **៥-៦ឆ្នាំ** ចំនួនសិស្សក៏មានការកើនឡើងជាលំដាប់ដោយទីធ្លាតូចចង្អៀតពេកពេលនោះ លោកអាចារ្យនិង គណៈកម្មការគ្រប់គ្រងសាលាបានសម្រេចរុះរើឲ្យមកបង្រៀននៅវត្តឈើទាលជាបណ្តោះអាសន្ន។
- **ឆ្នាំ១៩៩០ - ១៩៩៥** ក៏មានការប្រជុំគណៈកម្មការសាងសង់ហើយបានឯកភាពគ្នាសង់សាលារៀន១(មួយខ្នង)ស្មើនឹង១១បន្ទប់។បន្ទាប់ពីសាងសង់រួចរាល់ហើយបានដាក់ឈ្មោះថា " សាលាបឋមសិក្សាឈើទាល " ដែលមានលោកគ្រូ ជានាយកសាលា និង លោកគ្រូ ជានាយករងសាលា។
- នៅថ្ងៃទី**១៧ខែមេសាឆ្នាំ១៩៩២** ដីសាលារៀនប្រហ៊ូត(ហៅសាលាដើមស្លែង)បានចេញជាប្លង់សម្គាល់ម្ចាស់អចលនវត្ថុឲ្យជាកម្មសិទ្ធរដ្ឋ(**ហៅប្លង់ស្លាបមាន់**)ដែលមានទីតាំងនៅក្នុងភូមិប្រហ៊ូត រកាក្រៅ ទីរួមខេត្ត ខេត្តតាកែវ។
- នៅឆ្នាំ**១៩៩៥ - ១៩៩៨** លោកគ្រូ ជានាយកសាលា និង លោកគ្រូ ជានាយករង។ក្រោយមកឈ្មោះ ឃើញដីសាលារៀនប្រហ៊ូត (ហៅសាលាដើមស្លែង)នៅទំនេរក៏បានមកសុំព្រះតេជគុណ ជាចៅអធិការវត្តឈើទាល (សព្វថ្ងៃព្រះអង្គនៅមានព្រះជន្មនៅឡើយនិងជាព្រះអនុគណក្រុងដូនកែវ) និង លោកនាយក នាយករងសាលា ដើម្បីស្នាក់នៅជាបណ្តោះអាសន្នទម្រាំគាត់មានលទ្ធភាពគាត់នឹងចេញទៅវិញ។ ពេលនោះព្រះតេជគុណ លោកនាយក នាយករង ក៏បានអនុញ្ញាតឲ្យស្នាក់នៅបណ្តោះអាសន្ន។
- នៅឆ្នាំ**១៩៩៨ - ២០០៥** លោកគ្រូ ជានាយកនិងលោកគ្រូ ជានាយករងសាលាបានសុំឲ្យប្រជាពលរដ្ឋដែលស្នាក់នៅ និង អាស្រយផលនៅលើដីសាលាប្រហ៊ូតមកបំពេញកិច្ចសន្យាស្នាក់ និង អាស្រ័យផលដំណាំក្នុង១ឆ្នាំម្តង ប៉ុន្តែពុំមានបុគ្គលណាមួយមកបំពេញឲ្យឡើយ។
- រហូតមកដល់ថ្ងៃទី**០១ ខែសីហា ឆ្នាំ២០១៧** គណៈកម្មការសាងសង់ដែលមានព្រះតេជគុណជាប្រធាន

លោកមេភូមិ (ចាស់)និងលោកមេភូមិ ថ្មី)លោកនាយកសាលា បានសុំអញ្ជើញប្រជាពលរដ្ឋដែលកំពុងស្នាក់នៅ និង ធ្លាប់អាស្រ័យផលមកចូលរួមប្រជុំដើម្បីសុំដកយកដីមកសាងសង់សាលាដែលជាអំណោយរបស់អង្គការកូរ៉េ(ដៃល្អ)ពួកគាត់ក៏បានយល់ព្រមប្រគល់ដីឲ្យសាលាវិញ។ពេលនោះឈ្មោះ មិនព្រមផ្តិតមេដៃប្រគល់វិញទេ។

- នៅថ្ងៃទី**១៨ ខែកញ្ញា ឆ្នាំ២០១៧** សាលាក៏បានចាប់សាងសង់អគាសិក្សាលើដីសាលារៀនប្រហ៊ូត(ហៅសាលាដើមស្លែង)និងបានបញ្ចប់ការសាងសង់ព្រមទាំងសម្ពោធដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី**១៧ខែវិច្ឆិកា ឆ្នាំ២០១៧** ក្រោមអធិបតីភាពរបស់លោក អភិបាលរងខេត្តជាតំណាងលោកឲ្យ **ឯកឧត្តម** គណៈអភិបាលខេត្តតាកែវ និង ប្រធានអង្គការកូរ៉េ។
- នៅថ្ងៃទី**០៤ ខែមករា ឆ្នាំ២០១៨** ដីសាលាប្រហ៊ូតត្រូវបានមន្ទីររៀបចំដែនដី និង នគររូបនីកម្មនិងសំណង់ខេត្តតាកែវបានចេញជាវិញ្ញាបនបត្រសម្គាល់អចលនវត្ថុជាលើកទី២(ប្លង់រឹង)។
- នៅថ្ងៃទី**០២ ខែកញ្ញា ឆ្នាំ២០១៩** ឈ្មោះ បានសង់សំណង់រឹងបន្ថែម**១ខ្នង**ទៀតមានទំហំ ៥ម x ១២ម ធ្វើអំពីឥដ្ឋប្រង់ស័ង្កសី ស្របពេលដែលខ្ញុំ(ខឹម សារិន)ជិះកាត់តាមផ្លូវមុខផ្ទះក៏បានឃើញហើយបានសាកសួរទៅសួរលោកមេភូមិនិងបានរាយការណ៍ជូនទៅអាជ្ញាធរដែនដី។
- នៅថ្ងៃទី**០៧ ខែកញ្ញា ឆ្នាំ២០១៩** អាជ្ញាធរសង្កាត់ដឹកនាំដោយលោក ចៅសង្កាត់រងទី១ លោកនាយក លោកគ្រូ តំណាងប៉ុស្តិ៍រដ្ឋបាល លោកមេភូមិ បានចុះទៅហាមឃាត់និងធ្វើកិច្ចសន្យាផ្អាកការសាងសង់ជាបណ្តោះអាសន្នដោយឲ្យម្ចាស់ផ្ទះ និង ក្រុមជាងចុះហត្ថលេខាលើកិច្ចសន្យានោះ។សំណង់បានប្រហែល៣០%។ ដោយមានការឃ្លាំមើលពីសំណាក់លោកគ្រូ អ្នកគ្រូនៅសាលាមត្តេយ្យប្រហ៊ូតនៅតែមានការសាងសង់បន្តពេលនោះនាយកសាលាក៏បានជូនដំណឹងជាលើកទី២ដល់ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង និង ថ្នាក់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត។
- នៅថ្ងៃទី**១១ ខែកញ្ញា ឆ្នាំ២០១៩**ក្រុមការងារថ្នាក់មន្ទីរអប់រំខេត្តដែលដឹកនាំដោយលោកស្រី អនុប្រធានមន្ទីរ លោកប្រធានការិយាល័យកុមារតូច លោកប្រធានការិយាល័យគណនេយ្យ លោកស្រី អនុប្រធានការិយាល័យអប់រំ យុវជន និង កីឡាក្រុង លោកនាយក អ្នកគ្រូមត្តេយ្យ លោកក្រុមប្រឹក្សាសង្កាត់ លោកមេភូមិ បានចុះមកត្រួតពិនិត្យនិងណែនាំកុំអោយសាងសង់បន្តរងចាំនៅពេលមានដំណោះស្រាយសិន។
- នៅថ្ងៃទី**២៥ ខែមីនា ឆ្នាំ២០២០** ម្ចាស់សំណង់នៅតែបន្តការសាងសង់រហូតបានសម្រេចប្រហែលជា៨០%។
- នៅថ្ងៃទី**២៧ ខែមីនា ឆ្នាំ២០២០** ឯកឧត្តមអភិបាលខេត្តបានចេញជាចំណារមួយទៅឲ្យអាជ្ញាធរក្រុងចុះទប់ស្កាត់ជាបន្ទាន់។
- នៅថ្ងៃទី**០២ខែមេសា ឆ្នាំ២០២០**គណៈគ្រប់គ្រងសាលាបានរៀបចំឯកសារជូនដំណឹងទៅសាលាដំបូង

ខេត្តតាកែវ ដោយបានឆ្លងកាត់ថ្នាក់ការិយាល័យក្រុង និង ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

- នៅថ្ងៃទី**០២ ខែមេសា ឆ្នាំ២០២០** គណៈគ្រប់គ្រងសាលាបានរៀបចំដាក់ពាក្យបណ្ដឹងទៅសាលាដំបូងខេត្តដើម្បីការពារទ្រព្យសម្បត្តិរដ្ឋ។
- លុះមកដល់**ពាក់កណ្ដាល ខែមិថុនា ឆ្នាំ២០២០** សំណង់ត្រូវបានសាងសង់រួចរាល់ជាស្ថាពរ។
- បច្ចុប្បន្នឈ្មោះ                    បានរស់នៅលើដីសាលាប្រហ៊ូតដែលមានទំហំ ៣៨ម x ៥០ម ។ សំណង់នេះសង់នៅលើក្បាលដីលេខៈ៥៧៩ នៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 21080303-0579។

**បញ្ជាក់**៖ -១ខ្នងសង់អំពីឈើប្រក់ស្លឹកទំហំ ៥.៥ម x ៧ម

-១ខ្នងទៀតសង់អំពីឥដ្ឋប្រក់ស័ង្កសីទំហំ ៥ម x ១២ម

ថ្ងៃសុក្រ 12កើត ខែកត្តិក ឆ្នាំជូត ទោស័ក ពស 25

ធ្វើនៅ ថ្ងៃទី27 ខែ វិច្ឆិកា ឆ្នាំ2020

នាយក

[signature]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តតាកែវ
សំណុំរឿងរដ្ឋប្បវេណីលេខៈ១១៧
ចុះថ្ងៃទី០៤-០៥-២០២០

## កំណត់ហេតុ
## នៃនីតិវិធីត្រៀមសំរាប់ទាញហេតុផល(លើកទីពីរ)

បានឃើញមាត្រា១១០ ដល់មាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

## សញ្ញាណរឿងក្តី

ដើមចោទប្តឹងសុំតុលាការចេញសាលក្រមៈ

-សម្រេចឱ្យចុងចម្លើយរុះរើសំណង់ និងឈប់រស់នៅលើដីសាលាមតេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ។

លោកស្រី ចៅក្រមសាលាដំបូងខេត្តតាកែវ

លោក ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

-ដើមចោទឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧២ មុខរបរនាយកសាលាមតេយ្យឈើទាល ទីលំនៅបច្ចុប្បន្ន ភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

-ចុងចម្លើយឈ្មោះ ភេទស្រី អាយុ៦១ឆ្នាំ ថ្ងៃខែឆ្នាំកំណើត១៩៥៨ ជនជាតិខ្មែរ មុខរបរបុគ្គលិកមេផ្ទះ ទីលំនៅបច្ចុប្បន្ននៅភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

ឆ្នាំពីរពាន់ម្ភៃ ខែធ្នូ ថ្ងៃទីដប់ប្រាំ វេលាម៉ោងប្រាំបួន និងដប់ប្រាំនាទី ព្រឹក នៅសាលាដំបូងខេត្តតាកែវ បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់**រវាងដើមចោទ និងចុងចម្លើយដូចតទៅៈ**

-ភាគីដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្ញុំបាទនៅតែរក្សានៅការទាមទារដូចមានក្នុងសេចក្តីថ្លែងការណ៍នៅក្នុងដំណាក់កាលត្រៀមលើកទីមួយ។ ប៉ុន្តែខ្ញុំបាទសុំកែតម្រូវទំហំដី ព្រោះក្រោយពីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីមួយរួចហើយ ខ្ញុំនឹងលោកគ្រូឈ្មោះ បានសុំចុងចម្លើយចូលវាស់វែងដីដែលគាត់កំពុងចូលកាន់កាប់ដោយជាក់ស្តែង ឃើញថា ដីនោះ មានទំហំ ទទឹងប្រវែង ៥០ម៉ែត្រ និងបណ្តោយ ៣៨ម៉ែត្រ។

-ចុងចម្លើយឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្ញុំនៅតែរក្សានូវសេចក្តីសេចក្តីថ្លែងការណ៍ដូចដែលមាននៅក្នុងដំណាក់កាលនីតិវិធីត្រៀមលើកទីមួយនោះដដែល ហើយ នាងខ្ញុំក៏នៅតែអះអាងផងដែរថា នាងខ្ញុំនឹងមិនចាកចេញទៅណាទាំងអស់។

## ចំណុចវិវាទនៃរឿងក្តី:

តើដីទំហំ៥០ គុណនឹងបណ្តោយ៣៨ម៉ែត្រ ដែលចុងចម្លើយឈ្មោះ          កំពុងកាន់កាប់ជាដីឯកជន ឬជាដីកម្មសិទ្ធិរបស់សាលាមតេយ្យសិក្សាប្រហ៊ូតសហព័ន្ធជានាគារកូរ៉េ?

យើងបានបញ្ចប់នីតិវិធីត្រៀមសំរាប់ការទាញហេតុផល នៅវេលាម៉ោង ដប់មួយ និងដប់មួយ   នាទីព្រឹក ដោយបានអានឲ្យសាមីខ្លួនថា ពិតជាត្រឹមត្រូវហើយ យល់ព្រមផ្តិតមេដៃជាមួយយើង ។

| ដើមចោទ | ចុងចម្លើយ | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|

# ឧបសម្ព័ន្ធទី១៤

## ពាក្យសុំបញ្ចូលឥស្សុតាង

លេខាធិការដ្ឋានរដ្ឋបាល
សាលាដំបូងខេត្តតាកែវ
លេខ......135......
ចូល ថ្ងៃទី..14..ខែ..07..ឆ្នាំ..20..
ម៉ោង:....9:50....

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំបញ្ចូលភស្តុតាង

នាងខ្ញុំបាទឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ កើតថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៨ ជនជាតិខ្មែរ មានមុខរបរមេផ្ទះ មានទីលំនៅបច្ចុប្បន្នភូមិប្រហ៊ូត សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

### សូមគោរពជូន
### លោកស្រី ចៅក្រមសាលាដំបូងខេត្តតាកែវ

**កម្មវត្ថុៈ** សុំបញ្ចូលភស្តុតាងជាឯកសារ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១១៧ ចុះថ្ងៃទី៤០ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ។

**១.ភស្តុតាងជាឯកសារៈ**

១.ឯកសារលិខិតធានាអះអាង ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១

២.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:១០០០៣០០៦៨

៣.បង្កាន់ដៃលេខ: ០៤៨៨៥៩២ របស់អគ្គិសនីតាកែវ

៤.វិក័យបត្របង់ប្រាក់របស់អគ្គិសនីតាកែវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣

៥.បញ្ជីប៉ាន់តំលៃប្រាក់កក់ និងថ្លៃបន្តចរន្ត លេខ០៦២០/១៣ អ.ជ.អតក

៦. ពាក្យសុំបន្តចរន្តអគ្គិសនី ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣

៧.សៀវភៅគ្រួសាររបស់ឈ្មោះ ២០១.ដ.ក.៣៨៩៩

៨.កិច្ចព្រមព្រៀមផ្គត់ផ្គង់អគ្គិសនីសំរាប់អតិថិជនធុនតូចនៅ អគ្គិសនីតាកែវ លេខ ៨៤៥២/១៣អ.ជ.អតក

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន លោកស្រីចៅក្រម មេត្តាជ្រាបថាៈ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ឈ្មោះ បានដាក់ពាក្យបណ្តឹងទៅតុលាការឱ្យបង្គាប់ឱ្យនាងខ្ញុំរុះរើសំណង់ និងឈប់រស់នៅលើដីសាលាមេតយ្យសិក្សាប្រហូតសហព័ន្ធធនាគារកូរ៉េ។ ក្រោយមកកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ តុលាការបានកោះហៅនាងខ្ញុំឱ្យចូលរួមនីតិវិធីត្រៀម។ បន្ទាប់ពីបានចូលរួមក្នុងនីតិវិធីតុលាការ នាងខ្ញុំបានស្នើសុំឱ្យតុលាការចុះទៅពិនិត្យនៅទីតាំងដីទំនាស់កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១។ នៅពេលនោះតុលាការបានបង្គាប់ឱ្យនាងខ្ញុំដាក់បញ្ចូលភស្តុតាងចូលមកតុលាការ។ ដូច្នេះ នាងខ្ញុំសុំបញ្ចូលភស្តុតាងដែលមានខាងលើ។

សេចក្តីដូចបានជម្រាបខាងលើ សូមលោកស្រីចៅក្រម សាលាដំបូងខេត្តតាកែវ មេត្តាអនុញ្ញាត តាមការសុំ ដូចខាងលើដោយក្តីអនុគ្រោះ។

សូមលោកស្រីចៅក្រម សាលាដំបូងខេត្តតាកែវ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

ក្រែងពុំពិតប្រាកដខ្ញុំសុំផ្តិតម្រាមដៃទុកចំណាំ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០

ស្នាមផ្តិតម្រាមដៃស្តាំ



# ឧបសម្ព័ន្ធទី១៥

## លិខិតសុំបញ្ចូលសាក្សី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខាធិការដ្ឋានរដ្ឋបាល
សាលាដំបូងខេត្តតាកែវ
លេខ 110
ចូល ថ្ងៃទី 13 ខែ 01 ឆ្នាំ 21
ម៉ោង: 9-30

**សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ**

## លិខិតសុំបញ្ចូលសាក្សី

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំជាដើមចោទលើដីទំនាស់សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ ស្ថិតនៅក្នុងភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តតាកែវ**

សូមជ្រាប!

**<u>កម្មវត្ថុ:</u>** សំណើសុំបញ្ចូលឈ្មោះសាក្សីដូចខាងក្រោមៈ

១.ព្រះតេជគុណ ព្រះជន្ម ៥៩ព្រះវស្សា(គណៈកម្មការសាងសង់)ទីលំនៅបច្ចុប្បន្ននៅវត្តឈើទាលទងត្រា សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

២.លោក អាយុ ៧៩ឆ្នាំ(អតីតមេភូមិ) ទីលំនៅបច្ចុប្បន្នភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

៣.លោកស្រី អាយុ ៦៤ឆ្នាំ (អតីតគ្រូបង្រៀន)ទីលំនៅបច្ចុប្បន្នភូមិតាឌូ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

៤.លោក អាយុ ៥៦ឆ្នាំ (មេភូមិថ្មី)ទីលំនៅបច្ចុប្បន្នភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

៥.លោក អាយុ ៦១ឆ្នាំ (ប្រជាពលរដ្ឋ)លំនៅបច្ចុប្បន្នភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

**<u>មូលហេតុ:</u>** ដើម្បីជួយបំភ្លឺរឿងវិវាទទំនាស់ដីធ្លីរបស់សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ ដែលមានសំណុំរឿងលេខៈ១១៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

អាស្រ័យហេតុដូចបានជម្រាបជូនក្នុងមូលហេតុខាងលើសូមលោកប្រធានសាលាដំបូងខេត្តតាកែវ មេត្តាជួយដោះស្រាយដោយក្តីអនុគ្រោះផងចុះ។

ថ្ងៃព្រហស្បតិ៍០១កើត ខែមាឃ ឆ្នាំជូតទោស័ក ព.ស ២៥៦៤

ប្រហ៊ូត ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១

**ដើមចោទ**

# ឧបសម្ព័ន្ធទី១៦

## ពាក្យសុំបញ្ចូលឥស្សុតាខ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខាធិការដ្ឋានរដ្ឋបាល
សាលាដំបូងខេត្តតាកែវ
លេខ 169
ចូល ថ្ងៃទី 18 ខែ 01 ឆ្នាំ 2021
ម៉ោង: 9:15

**សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ**

## <u>សុំបញ្ចូលភស្តុតាង</u>

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំជាដើមចោទលើដីទំនាស់សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ ស្ថិតនៅក្នុងភូមិប្រហ៊ូត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

**<u>សូមគោរពជូន</u>**

**លោកប្រធានសាលាដំបូងខេត្តតាកែវ**

សូមជ្រាប!

**<u>កម្មវត្ថុ</u>:** សុំបញ្ចូលភស្តុតាងដូចខាងក្រោម៖

១.កំណត់ហេតុ និង រូបភាពសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានចុះហាមឃាត់លើកទី១ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៩ មានចំនួន ០៥សន្លឹក។

២.បញ្ជីវត្តមាន និង រូបភាពសកម្មភាពរបស់ថ្នាក់សាលា ថ្នាក់ការិយាល័យអប់រំក្រុង និង មន្ទីរអប់រំយុវជននិងកីឡាខេត្តចុះហាមឃាត់លើកទី២នៅថ្ងៃទី១១ខែកញ្ញាឆ្នាំ២០១៩ មានចំនួន ០៤សន្លឹក។

៣.រូបភាពដំណាំកសិកម្មលើដីទំនាស់មានចំនួន០៨សន្លឹក។

**<u>មូលហេតុ</u>:** ដើម្បីជាភស្តុតាងរឿងវិវាទទំនាស់ដីធ្លីរបស់សាលាមត្តេយ្យសិក្សាប្រហ៊ូតសហព័ន្ធធនាគារកូរ៉េ ដែលមានសំណុំរឿងលេខ:១១៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

អាស្រ័យហេតុដូចបានជម្រាបជូនក្នុងមូលហេតុខាងលើសូមលោកប្រធានសាលាដំបូងខេត្តតាកែវ មេត្តាជួយដោះស្រាយដោយក្តីអនុគ្រោះផងចុះ។

ថ្ងៃចន្ទ០៥កើត ខែមាឃ ឆ្នាំជូតទោស័ក ព.ស ២៥៦៤

ប្រហ៊ូត ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១

**ដើមចោទ**

(signature)

# ឧបសម្ព័ន្ធទី១៧

## ដីកាកោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
**សំណុំរឿងរដ្ឋប្បវេណី**

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកឈ្មោះ | ជាដើមចោទ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ។ |
| សញ្ញាណនៃរឿងក្តី (លេខនិងភាគី) | សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៧ ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២០ ដើមចោទឈ្មោះ , ចុងចម្លើយឈ្មោះ ហៅ_ និងឈ្មោះ- ។ |
| កាលបរិច្ឆេទនិងកន្លែងដែលត្រូវបង្ហាញខ្លួន | **ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០** វេលាម៉ោង៩ព្រឹក មន្ទីរស៊ើបសួរលេខ២ (បន្ទប់លេខ២) |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស ☐លើលេខនៃនីតិដែលចាំបាច់) | ១-ផ្សះផ្សា☑ ២-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល☐ ៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់☑ |
| ប្រភេទនៃឯកសារដែលភ្ជាប់មកជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារ បើចាំបាច់ឱ្យមកកាន់) | ១-ពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ចំនួន០២ច្បាប់ ........................................................................................................ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួននោះ តុលាការអាចទទួលស្គាល់ថាសេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៤០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវតុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី១,០០០,០០០៛ (មួយលានរៀល) តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនតាមពេលវេលានិងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ ។

ថ្ងៃច័ន្ទ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
តាកែវ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០
**ចៅក្រម**

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ ។

-ពេលបង្ហាញខ្លួនសូមយកដីកានេះជូនក្រឡាបញ្ជីទទួលបន្ទុក ។

-ករណីមិនព្រមចូលខ្លួនមកឆ្លើយបំភ្លឺតាមកាលកំណត់យើងនឹងបង្គាប់ឱ្យនាំខ្លួនតាមបញ្ញត្តិមាត្រា១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

**សំណុំរឿងរដ្ឋប្បវេណី**

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកឈ្មោះ ហៅ និងឈ្មោះ ជាចុងចម្លើយ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ។ | |
| សញ្ញាណនៃរឿងក្តី (លេខនិងភាគី) | សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៧ ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២០ ដើមចោទឈ្មោះ ចុងចម្លើយឈ្មោះ ហៅ និងឈ្មោះ - ។ |
| កាលបរិច្ឆេទនិងកន្លែងដែលត្រូវបង្ហាញខ្លួន | **ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០** វេលាម៉ោង២ រសៀល មន្ទីរស៊ើបសួរលេខ២ (បន្ទប់លេខ២) |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស ☐លើលេខនៃនីតិដែលចាំបាច់) | ១-ផ្សះផ្សា☑ ២-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល☐<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់☑ |
| ប្រភេទនៃឯកសារដែលត្រូវភ្ជាប់មកជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារ បើចាំបាច់ឱ្យមកកាន់) | ១-ពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ចំនួន០២ច្បាប់<br>........................................................................................................ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួននោះ តុលាការអាចទទួលស្គាល់ថាសេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៤០ កថាខណ្ឌ២ និងមាត្រា ២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវតុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី១,០០០,០០០៛ (មួយលានរៀល) តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |
| សូមបង្ហាញខ្លួនតាមពេលវេលានិងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ ។<br>ថ្ងៃច័ន្ទ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣<br>តាកែវ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម** | |

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ ។

-ពេលបង្ហាញខ្លួនសូមយកដីកានេះជូនក្រឡាបញ្ជីទទួលបន្ទុក ។

-ករណីមិនព្រមចូលខ្លួនមកឆ្លើយបំភ្លឺតាមកាលកំណត់យើងនឹងបង្គាប់ឱ្យនាំខ្លួនតាមបញ្ញត្តិមាត្រា១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

# ឧបសម្ព័ន្ធទី១៨

## របាយការណ៍ស្តីពីការបញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

# របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញៈ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០<br>ឈ្មោះឯកសារដែលត្រូវបានបញ្ជូនៈ ដីកាកោះហៅចូលនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់<br>ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូនៈ ស៊ុ សារឿន<br>អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូនៈ សាលាដំបូងខេត្តតាកែវ<br>ឈ្មោះជនដែលត្រូវទទួលការបញ្ជូនៈ លោកស្រី (ដើមចោទ) |

**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែងៈ**

..........................................................................................................

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសនីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | | |
|---|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូនៈ សាលាដំបូងខេត្តតាកែវ | | |
| កាលបរិច្ឆេទនៃការបញ្ជូនៈថ្ងៃទី............ខែ....................ឆ្នាំ២០២០ ម៉ោង.................... | | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | | |
| ☐ | ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | | ☐ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះជននោះមិនចេះអក្សរ ។ |
| ☐ | ២ | បានប្រគល់ឯកសារ ទៅអ្នកមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទួលការបញ្ជូននោះទេ ។ |
| | | ☐អ្នកបម្រើ ☐អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐អ្នកនៅជាមួយ<br>ឈ្មោះ.................................................................... |
| ☐ | ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | | ☐ជនដែលត្រូវទទួលការបញ្ជូន ☐អ្នកបម្រើ ☐អ្នកនៅជាមួយ ☐អ្នកផ្សេងដែលធ្វើការនៅទីនោះ<br>ឈ្មោះ.................................................................... |
| ☐ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | | |
| ☐ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។ | | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ៈ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ | | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ៈ.................................................... | | |

កំណត់សម្គាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន:

១-ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលបញ្ជូន ឬបុគ្គលផ្សេងទៀត) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង " **ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង** "។

២-" ទីកន្លែងដែលបានធ្វើការបញ្ជូន " ត្រូវតែសរសេរឲ្យបានច្បាស់ៗ និងត្រឹមត្រូវ ។

៣-ប្រសិនបើការបញ្ជូនធ្វើឡើតតាមចំណុចលេខ១ អ្នកត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេប ត្រូវគូស☑ នៅក្នុងប្រអប់ដែរ ។

ប្រសិនបើការបញ្ជូនត្រូវធ្វើឡើតតាមចំណុចលេខ២ ត្រូវគូស ☑ នៅក្នុងប្រអប់លេខ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួល ដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និងសរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង ។

ប្រសិនបើការទទួលត្រូវបានធ្វើឡើងតាមចំណុចលេខ៣ អ្នកបញ្ជូនត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនេះដោយការគូស ☑ នៅក្នុងប្រអប់កំណត់ដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គលដែលមិនព្រមទទួលការបញ្ជូននោះចូលផង ។

៤-ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចបញ្ជូនឯកសារបានស្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☑ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា " ខ្ញុំមិនអាចបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះទេ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តតាកែវ

# របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន: ដីកាកោះ |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តតាកែវ |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: លោកស្រី |

**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្ដែង:**

[illegible]..........................................................................

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសនីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | | |
|---|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន: សាលាដំបូងខេត្តតាកែវ | | |
| កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី 23 ខែ កក្កដា ឆ្នាំ២០១៨ ម៉ោង.......... | | |
| **វិធីជាក់ស្ដែងក្នុងការបញ្ជូន** | | |
| ☐ | ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | | ☐ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះជននោះមិនចេះអក្សរ ។ |
| ☐ | ២ | បានប្រគល់ឯកសារ ទៅអ្នកមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូននោះទេ ។ |
| | | ☐អ្នកបម្រើ ☐អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐អ្នកនៅជាមួយ<br>ឈ្មោះ.......... |
| ☐ | ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | | ☐ជនដែលត្រូវទទួលការបញ្ជូន ☐អ្នកបម្រើ ☐អ្នកនៅជាមួយ ☐អ្នកផ្សេងដែលធ្វើការនៅទីនោះ<br>ឈ្មោះ.......... |
| ☐ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | | |
| ☐ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។ | | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ | | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍:.......... | | |

កំណត់សម្គាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូនៈ

១-ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលបញ្ជូន ឬបុគ្គលផ្សេងទៀត) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង " **ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង** "។

២-" ទីកន្លែងដែលបានធ្វើការបញ្ជូន " ត្រូវតែសរសេរឲ្យបានច្បាស់ៗ និងត្រឹមត្រូវ ។

៣-ប្រសិនបើការបញ្ជូនធ្វើឡើតតាមចំណុចលេខ១ អ្នកត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេប ត្រូវគូស☑ នៅក្នុងប្រអប់ដែរ ។

ប្រសិនបើការបញ្ជូនត្រូវធ្វើឡើតតាមចំណុចលេខ២ ត្រូវគូស ☑ នៅក្នុងប្រអប់លេខ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួល ដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និងសរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង ។

ប្រសិនបើការទទួលត្រូវបានធ្វើឡើងតាមចំណុចលេខ៣ អ្នកបញ្ជូនត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនេះដោយការគូស ☑ នៅក្នុងប្រអប់កំណត់ដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គលដែលមិនព្រមទទួលការបញ្ជូននោះចូលផង ។

៤-ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចបញ្ជូនឯកសារបានស្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☑ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា " ខ្ញុំមិនអាចបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះទេ ។

# ឧបសម្ព័ន្ធទី១៩

## ដីកាបញ្ជូន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

មន្ទីរស៊ើបសួរទី២

សំណុំរឿងលេខ: ៤៧

ចុះថ្ងៃទី: ០៣-០២-២០២០

លេខ: ./២០

# ដីកាបញ្ជូន

## ផ្ញើជូន

## លោកមេឃុំព្រះបាទជាន់ជុំ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| | ដីកាកោះ | | ដើម្បីចាត់បញ្ជូនដល់សាមីខ្លួនរួច បង្វិលដើមដីកាឬលិខិតចុងដីកាមកសាលាដំបូងខេត្តតាកែវ ក្រោយពីសាមីខ្លួនបានផ្តិតមេដៃទទួលរួចហើយ។ |
| ០១ | -ឈ្មោះ ហៅ<br>និងឈ្មោះ<br>(ចុងចម្លើយ) | ០២សន្លឹក | |
| សរុប | | ០២សន្លឹក | |

ថ្ងៃច័ន្ទ ១៤កើត ខែចេត្រ ឆ្នាំកុរ សំរឹទ្ធិស័ក ព.ស.២៥៦៣

តាកែវ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០

**ចៅក្រម**

# ឧបសម្ព័ន្ធទី២០

## លិខិតអញ្ជើញមេធាវី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

# លិខិតអញ្ជើញ

យើង ចៅក្រមនៃសាលាដំបូងខេត្តតាកែវ ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខៈ ៣២២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ។

បានឃើញលិខិតតំណាងដោយអាណត្តិចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ។

អញ្ជើញលោកមេធាវី មានអត្តលេខៈ ៥១៣ និងលោកមេធាវី មានអត្តលេខៈ ២២២៧T ជាសមាជិកមេធាវីនៃក្រុមហ៊ុនមេធាវីខ្មែរអប្សរា ដែលមានការិយាល័យផ្ទះលេខៈ ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ។

ចូលមកសាលាដំបូងខេត្តតាកែវ ( បន្ទប់ចៅក្រមទី០៨ ) នៅថ្ងៃទី....02.. ខែ..មីនា.. ឆ្នាំ២០២១ ម៉ោង.......១ រសៀល......... ដើម្បីចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។

សូមលោកអញ្ជើញមកអោយទាន់ពេលវេលាកំណត់។

ថ្ងៃចន្ទ ១១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១

**ចៅក្រម**

បានទទួល

ថ្ងៃទី..09......ខែ...កុម្ភៈ......ឆ្នាំ..2021..

ហត្ថលេខា

# ឧបសម្ព័ន្ធទី២១

## កំណត់ហេតុស្តីពីការសះជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

# កំណត់ហេតុស្តីពីការសះជា

សញ្ញាណនៃរឿងក្តី ៖ រឿងរដ្ឋប្បវេណីលេខៈ ៣២២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០

កាលបរិច្ឆេទ ៖ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១១ និង០០នាទីព្រឹក

ទីកន្លែង ៖ សាលាដំបូងខេត្តតាកែវ

ចៅក្រម ៖ លោក ចៅក្រមសាលាដំបូងខេត្ត

ក្រឡាបញ្ជី ៖ លោក ក្រឡាបញ្ជីសាលាដំបូងខេត្ត

ភាគីដែលបង្ហាញខ្លួន ៖

ដើមចោទៈឈ្មោះ ភេទប្រុស អាយុ៦៥ ជនជាតិខ្មែរ មានអាសយដ្ឋាននៅភូមិតាំងឬស្សី ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ដោយមានលោក ជាមេធាវីតំណាងដោយអាណត្តិ។

ចុងចម្លើយៈ ឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិពន់ចាន ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល តំណាងដោយលោក និងមានលោក កញ្ញា ជាមេធាវី តំណាងដោយអាណត្តិ។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញៈ

សុំឲ្យតុលាការចេញសាលសក្រមសម្រេចដូចខាងក្រោមៈ

១.បង្គាប់ឲ្យចុងចម្លើយឈ្មោះ សងប្រាក់ចំនួន ៦,៦៣៧$ (ប្រាំមួយពាន់ប្រាំមួយរយសាមសិបប្រាំពីរដុល្លាអាមេរិក) ឱ្យទៅដើមចោទឈ្មោះ ។

២.បង្គាប់ឱ្យចុងចម្លើយសងសំណាងនៃការយឺតយ៉ាវ ការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្តសរុបចំនួន ៣០,០០០,០០០៛ (សាមសិបលានរៀល)។

៣.សុំអនុវត្តបណ្តោះអាសន្នលើប្រាក់ដើមចំនួន ៦,៦៣៧$ (ប្រាំមួយពាន់ប្រាំមួយរយសាមសិបប្រាំពីរដុល្លាអាមេរិក)។

នាពេលនេះភាគីដើមចោទ និងចុងចម្លើយបានយល់ព្រមគ្នាចំពោះមុខយើងដូចខាងក្រោមៈ

១.ចុងចម្លើយឈ្មោះ ទទួលស្គាល់ និងយល់ព្រមសងប្រាក់ចំនួន ៦៦៣៧$ នៃការទិញលក់ដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ២១០២១០០៧-០៣៨៤ មានទំហំ ១២៦៥៥ ម៉ែត្រការ៉េ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០២ មានទីតាំងស្ថិតនៅភូមិតាំងឬស្សី ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ឱ្យទៅដើមចោទឈ្មោះ វិញគ្រប់ចំនួន នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ ហើយដើមចោទឈ្មោះ ក៏បានយល់ព្រមដោយឱ្យចុងចម្លើយសងប្រាក់មកឱ្យខ្លួនវិញតាមការសន្យាខាងលើនោះដែរ។

២.ករណីដែលចុងចម្លើយឈ្មោះ ពុំបានអនុវត្តតាមខ្លឹមសារនៃចំណុចទី១ ក្នុងកំណត់ហេតុស្តីពីការសះជានេះទេ នោះដើមចោទមានសិទ្ធិដាក់ពាក្យសុំអនុវត្តដោយបង្ខំលើប្រាក់ដើមចំនួន ៦៦៣៧$ និងសំណងការខូចខាតផ្សេងៗតាមច្បាប់។

៣.ដើមចោទឈ្មោះ យល់ព្រមពុំទាមទារសងសំណងនៃការយឺតយ៉ាវ ការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្តសរុបចំនួន ៣០,០០០,០០០៛ (សាមសិបលានរៀល) ពីចុងចម្លើយឈ្មោះ នោះទេ។

៤.ដើមចោទឈ្មោះ បានយល់ព្រមសុំឱ្យតុលាការឈប់អនុវត្តបណ្តោះអាសន្នលើប្រាក់ដើមចំនួន ៦,៦៣៧$ (ប្រាំមួយពាន់ប្រាំមួយរយសាមសិបប្រាំពីរដុល្លាអាមេរិក) ពីចុងចម្លើយឈ្មោះ វិញ។

ចៅក្រមៈ ប្រកាសបទិបញ្ចប់កំណត់ហេតុស្តីពីការសះជានាពេលនេះ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោងដប់មួយ និងសែសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

បានអាននូវខ្លឹមសារទាំងស្រុងរបស់កំណត់ហេតុឲ្យភាគីស្តាប់ឆ្លើយថាត្រឹមត្រូវ និងព្រមផ្តិតមេដៃទុកជាចំណាំចំពោះមុខយើង។

**ក្រឡាបញ្ជី** **ចៅក្រម**

**មេធាវីដើមចោទ** **មេធាវីចុងចម្លើយ**





**ដើមចោទ** **ចុងចម្លើយ**









# ឧបសម្ព័ន្ធទី២២

## សេចក្តីថ្លែងការណ៍អំពី

## លទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខាធិការដ្ឋានរដ្ឋបាល
សាលាដំបូងខេត្តតាកែវ
លេខ 282
ចូល ថ្ងៃទី 26 ខែ 01 ឆ្នាំ 2021
ម៉ោង: 3,20

## សេចក្តីថ្លែងការណ៍អំពីលទ្ធផល
## នៃនីតិវិធីសម្រាប់ការទាញហេតុផល

ខ្ញុំមេធាវី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ជាភាគីដើមចោទក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៣០១ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តតាកែវ**

**កម្មវត្ថុ** : សុំធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដាក់បញ្ចូលក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៣០១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ

**យោង** :-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

-ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣០១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ

-លិខិតអញ្ជើញ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ

-កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ជាភាគីដើមចោទក្នុងសំណុំរឿងរដ្ឋប្បវេណីខាងលើ ខ្ញុំសូមធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជូន **ឯកឧត្តមប្រធាន** មានខ្លឹមសារដូចតទៅៈ

នៅតែទាមទារអោយតុលាការចេញសាលក្រមសម្រេចដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ភាគីដើមចោទទុកដដែល ។

ដោយហេតុថាដើមចោទ ឈ្មោះ អស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នាទៅថ្ងៃអនាគតបានទៀតនោះទេ ការរស់នៅមានភាពរកាំរកូស និងមិនចុះសម្រុងនឹងគ្នា ម្យ៉ាងភាគីចុង

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១(មួយ)ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

.....................................

ផ្អែកតាមមាត្រា២២ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិថា "សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំជាអាទិ៍ ៖

១-ប្រសិនបើតុលាការចេញសាលក្រម ឬសាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្តឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬលែងលះគ្នា តុលាការត្រូវធ្វើការសម្រេចអំពីការកំណត់អ្នកមានអំណាចមេបាដោយធន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគីត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ។

២-.................................

ដូច្នេះក្នុងនាមខ្ញុំជាមេធាវីតំណាងដោយភាគីដើមចោទសូមសំណូមពរ **ឯកឧត្តមប្រធាន** ចេញសាលក្រមសម្រេចតាមពាក្យបណ្តឹងចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ដើមចោទដោយ ៖

១-សម្រេចឱ្យដើមចោទឈ្មោះ លែងលះពីចុងចម្លើយ ឈ្មោះ

២-កំណត់ឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ៣០ វិច្ឆិកា ២០០៤

-កំណត់ឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ១៣ វិច្ឆិកា ២០០៩ ។

៣-ភាគីដែលពុំមានអំណាចមេបាមានសិទ្ធិ ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** សម្រេចតាមសំណូមពរខាងលើតាមនីតិវិធីច្បាប់។

សូម **ឯកឧត្តមប្រធាន** ទទួលការគោរពរាប់អានអំពីខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

**មេធាវីតំណាងដោយអាណត្តិ**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

*មេធាវី*

# ឧបសម្ព័ន្ធទី២៣

## កំណត់ហេតុ

## ស្ដីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

**សំណុំរឿងរដ្ឋប្បវេណីលេខ:៤៧**

**ចុះថ្ងៃទី:០៣-០២-២០២០**

# កំណត់ហេតុស្ដីពី
# នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

បានឃើញមាត្រា១១០ ដល់មាត្រា ១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧០៦/០២១ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

វេលាម៉ោងពីររសៀល ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទីម្ភៃបី នៅសាលាដំបូងខេត្តតាកែវ

លោកស្រី ចៅក្រមសាលាដំបូងខេត្តតាកែវ

អមដោយលោក ជាក្រឡាបញ្ជី

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណី លេខ:៤៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ រវាង:

**ដើមចោទ ៖** ឈ្មោះ ភេទស្រី អាយុ៤៨ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ ។

**និង**

**សហចុងចម្លើយ ៖** ឈ្មោះ ហៅ ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្រូបង្រៀន និងប្ដីឈ្មោះ អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ ។

## សញ្ញាណរឿងក្ដី

**កម្មវត្ថុបណ្ដឹង:** ដើមចោទប្ដឹងសុំតុលាការចេញសាលក្រមដូចខាងក្រោម៖

១.ឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ៤០,០០០,០០០៛ (សែសិបលាន) រៀល ឱ្យដើមចោទ ។

២.ឱ្យសហចុងចម្លើយសងការប្រាក់ចំនួន១៨% (ដប់ប្រាំបីភាគរយ) ក្នុង១ឆ្នាំ លើប្រាក់ដើមចំនួន ៤០,០០០,០០០៛ (សែសិបលាន) រៀល គិតពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួនឱ្យទៅដើមចោទ ។

៣.ទាមទារការខូចខាតពេលវេលា និងសោហ៊ុយចំណាយផ្សេងៗចំនួន ១០,០០០,០០០៛ (ដប់លាន) រៀល ។

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

៥.សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ។

# សេចក្តីថ្លែងការណ៍របស់គូភាគី

**-ដើមចោទ៖** ខ្ញុំនៅតែរក្សាសេចក្តីថ្លែងការណ៍ដូចនៅក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល បានធ្វើនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ។ តាំងពីនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ មកដល់ពេលនេះសហចុងចម្លើយឈ្មោះ ហៅ និងប្តីឈ្មោះ ពុំបានយកប្រាក់មកសងនាងខ្ញុំនោះទេ ។ ឈ្មោះ បានខ្ចីប្រាក់ខ្លួនចំនួនពីរលើក លើកទី២ ចំនួន២០.០០០.០០០ (ម្ភៃលាន)រៀល តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ និងលើកទី១ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ ។ នៅពេលខ្ចី ខ្លួនមិនបានកំណត់ពីការប្រាក់ទេ ដោយគិតថាខ្ចីត្រឹម១អាទិត្យប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំទទួលបានការប្រាក់ចំនួន២០០.០០០ (ពីរសែន)រៀល ក្នុងអំឡុងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨ ។

**-សហចុងចម្លើយ៖ ឈ្មោះ** ហៅ និងប្តីឈ្មោះ បានទទួលដីកាបញ្ជូនព្រមទាំងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងដីកាកោះហៅចូលរួមការទាញហេតុផល ប៉ុន្តែអវត្តនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុត្រឹមត្រូវ ។

## ចំណុចវិវាទនៃរឿងក្តី:

-ក្នុងកម្មវត្ថុនៃបណ្តឹង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ។

យើងបានប្រកាសបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅវេលាម៉ោងពីររសៀល ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ។

តុលាការបានបញ្ជូនកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់ ធ្វើនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោងពីររសៀល ទៅឱ្យសហចុងចំម្លើយ ។

តុលាការកំណត់កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ម៉ោង២រសៀល ។

យើងបានអានកំណត់ហេតុនេះឱ្យភាគីស្តាប់ ហើយភាគីបានឯកភាព និងយល់ព្រមផ្តិតមេដៃនៅចំពោះមុខយើង ។

**ដើមចោទ** **សហចុងចម្លើយ** **ក្រឡាបញ្ជី** **ចៅក្រម**



# ឧបសម្ព័ន្ធទី២៤

## សាលក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
-សំណុំរឿងរដ្ឋប្បវេណីលេខ: ២៤២
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០
-សាលក្រមលេខ: ០១ "ជ"
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ: ២៤២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាពដូចតទៅ:

### ចៅក្រមជំនុំជម្រះ

លោក ជាចៅក្រមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោក ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**-ដើមចោទឈ្មោះ** ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត ដោយមានលោក និងលោក ជាមេធាវីតំណាងដោយអាណត្តិ។

**-ចុងចម្លើយឈ្មោះ** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ និងប្រពន្ធឈ្មោះ អាយុ៣៤ឆ្នាំ មានទីលំនៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ។

### អង្គហេតុ និងចំណុចវិវាទ

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១.បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ទៅឱ្យដើមចោទនូវទឹកប្រាក់ចំនួន ៧,៨៤៦$ (ប្រាំពីរពាន់ ប្រាំបីរយសែសិបប្រាំមួយដុល្លាអាមេរិក) និងជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ២០ម្តែលានរៀល។

២.សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានភ្លាមៗទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។

៣.បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី។

**ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ លោក និងលោក ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ បានដាក់ពាក្យបណ្តឹងចូលមកសាលាដំបូងខេត្តតាកែវ ដោយប្តឹងទាមទារឱ្យសហចុងចម្លើយឈ្មោះ សងប្រាក់មកឱ្យដើមចោទឈ្មោះ ចំនួន

៧,៨៤៦$ ដោយបានអះអាងថាៈ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ បានធ្វើកិច្ចសន្យាសងប្រាក់មកឱ្យដើមចោទ ដែលសហចុងចម្លើយបានជំពាក់ដើមចោទចំនួន ៧,៨៤៦$ ហើយសហចុងចម្លើយក៏បានសន្យាថានឹងសងប្រាក់មកឱ្យដើមចោទវិញក្នុងមួយខែចំនួន ១០០$ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ រហូតដល់គ្រប់ចំនួន ៧,៨៤៦$ នៃលុយដែលជំពាក់។ លុះដល់ថ្ងៃកំណត់ដែលត្រូវសងជាប្រចាំខែសហចុងចម្លើយគេចវេសមិនបានសងប្រាក់មកឱ្យដើមចោទដូចការសន្យានោះទេ។ រឿងហេតុទាំងអស់នេះហើយបានជា ដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងចូលមកសាលាដំបូងខេត្តតាកែវដើម្បីតែម្តង។

**គ. ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**គ.១. ចំណុចវិវាទ :**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការកំណត់បានចំណុចវិវាទនៃរឿងក្តីមានដូចតទៅៈ

១.សហចុងចម្លើយអះអាងថាខ្លួនពុំមានលទ្ធភាពក្នុងការសងជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ២០លានរៀលទៅឱ្យដើមចោទនោះទេ។

២.សហចុងចម្លើយសុំឱ្យតុលាការកុំអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ន។

៣.ដើមចោទសុំឱ្យសហចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺសហចុងចម្លើយពុំឯកភាពនោះទេ។

**គ.២. ចំណុចគ្មានវិវាទៈ**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការកំណត់បានចំណុចគ្មានវិវាទនៃរឿងក្តីមានដូចតទៅៈ

-ភាគីសហចុងចម្លើយទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់របស់ដើមចោទចំនួន ៧,៨៤៦$ ពិតមែន។

**ឃ. សេចក្តីថ្លែងការណ៍របស់គូភាគី**

**ឃ.១. សេចក្តីថ្លែងការណ៍របស់ដើមចោទ**

ដើមចោទឈ្មោះ ដោយមានលោក ជាមេធាវីតំណាងដោយអាណត្តិបានធ្វើសេចក្តីថ្លែងកាណ៍ថាៈ ខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទនៅតែរក្សាការទាមទារដូចមានក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទុកដដែល ដោយបង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ទៅឱ្យដើមចោទនូវទឹកប្រាក់ចំនួន ៧,៨៤៦$ និងជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ២០ម្ភៃលានរៀល, សុំអនុវត្តសាលក្រមនេះជាបណ្តោះអាសន្នបានភ្លាមៗទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ និងសុំបង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី។ ខ្លួនសូមជម្រាបជូនលោកចៅក្រមថាៈ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ បានធ្វើកិច្ចសន្យាសងប្រាក់មកឱ្យកូនក្តីខ្លួនដែលពួកគេបានជំពាក់កូនក្តីខ្លួនចំនួន ៧៨៤៦$ ដោយសន្យាថានឹងសងប្រាក់ទាំងនោះមកឱ្យកូនក្តីខ្លួនក្នុងមួយខែចំនួន ១០០$ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ រហូតដល់គ្រប់ចំនួនប្រាក់ដែលជំពាក់។ ប៉ុន្តែតាមកិច្ចសន្យានោះចុងចម្លើយបានអនុវត្តដោយបានសងប្រាក់មកឱ្យកូនក្តីខ្លួនបានតែចំនួន ២ខែ ប៉ុណ្ណោះ គឺស្មើនឹង២០០$ ចំពោះការសងផ្សេងៗទៀតគឺខ្លួនពុំបានដឹងនោះទេ

ដោយកូនក្តីខ្លួនបានប្រាប់មកតែប៉ុនេះ ហើយចំពោះប្រាក់ដែលនៅសេសសល់ក្រៅពីនោះគឺសហចុងចម្លើយបានអាក់ខានក្នុងការសងរហូតដល់សព្វថ្ងៃនេះ។ ចំពោះទាក់ទងនឹងការទាមទារជំងឺចិត្ត និងការខាតបង់ពេលវេលានោះ គឺដោយសារតែកូនក្តីខ្លួនបានខាតបង់ពេលវេលាក្នុងការរកស៊ីរបស់គេ និងការចំណាយសេវាមេធាវី ព្រមទាំងដើម្បីដំណើរការរឿងក្តី ដូច្នះហើយទើបបានជាខាងកូនក្តីខ្លួនសុំទាមទារជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ២០លានរៀលនោះ។ ចំពោះការទាមទារទី២ ដោយសុំអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ននោះ ដោយហេតុថា: សហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចដូចមានក្នុងកិច្ចសន្យាសងប្រាក់ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ដែលជាហេតុធ្វើឱ្យប៉ះពាល់ និងមានការយឺតយ៉ាវក្នុងការសងប្រាក់មកឱ្យកូនក្តីខ្លួន។ ចំពោះចំណុចទី៣ ទាក់ទងនឹងប្រាក់ប្រដាប់ក្តីវិញ ខ្លួនសុំឲ្យសហចុងចម្លើយទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តី ដោយសារតែខាងខ្លួនបានបង់ពន្ធដាក់ពាក្យបណ្តឹង និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធផ្សេងទៀតដើម្បីដំណើរការរឿងក្តី ដូច្នេះហើយទើបខ្លួនសុំឲ្យភាគីសហចុងចម្លើយជាអ្នកទទួលបន្ទុក។ ខ្លួនសូមបញ្ជាក់ផងដែរថា: សព្វថ្ងៃនេះសហចុងចម្លើយនៅមានទ្រព្យសម្បត្តិរបស់គាត់ដែលបានដាក់បញ្ចាំមកឱ្យកូនក្តីខ្លួនមានដូចជា:វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០១១០៣-១៣០១ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០១១០៣-១២៦៥ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ ព្រមទាំងទ្រព្យសម្បត្តិមួយចំនួនទៀតផងដែរ។ ហេតុដូច្នេះទើបខ្លួនសូមឱ្យតុលាការសម្រេចចេញសាលក្រមអនុវត្តជាបណ្តោះអាសន្នទៅលើប្រាក់ដែលសហចុងចម្លើយបានជំពាក់កូនក្តីខ្លួន។

ឃ.២. សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ បានធ្វើសេចក្តីថ្លែងកាណ៍ថា: ទាក់ទងនឹងការបង្គាប់ឱ្យខ្លួនសងប្រាក់ទៅឱ្យដើមចោទនូវទឹកប្រាក់ចំនួន ៧,៨៤៦$ គឺខ្លួនសូមទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់ដូចការអះអាងរបស់ដើមចោទមែន។ ដោយខ្លួនសូមទទួលសងប្រាក់នោះទៅឱ្យដើមចោទវិញក្នុងមួយខែយ៉ាងទាបបំផុតចំនួន១០០$ គិតចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ តទៅ ហើយនៅពេលណាដែលខ្លួនរកចំណូលបានច្រើន ខ្លួនសូមសងទៅតាមចំណូលដែលរកបាននោះប្រសិនបើខ្លួនមានលទ្ធភាពខ្លួននឹងខ្ចីលុយធនាគារឯកជនដើម្បីយកមកសងផ្តាច់ឱ្យដើមចោទឈ្មោះ នៅដំណាច់ឆ្នាំ២០២១ ឱ្យបានគ្រប់ចំនួនវិញជាកំណត់។ ខ្លួនសូមទទួលស្គាល់ថា: ខ្ញុំបាទ និងប្រពន្ធឈ្មោះ ពិតជាបានធ្វើកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ជាមួយដើមចោទមែន។ ខ្លួនពិតជាបានសងប្រាក់ឱ្យទៅដើមចោទឈ្មោះ បានតែចំនួន ០៣ខែមែន ដែលការសងនោះសរុបជាទឹកប្រាក់ចំនួន ៣០០$ រួចហើយ ហើយទឹកប្រាក់ដែលខ្លួននៅជំពាក់ដើមចោទសរុបនៅពេលនេះគឺមានចំនួន ៧,៥៤៦$។ ចំពោះការខកខានសងប្រាក់កន្លងមកនោះគឺដោយសារចាប់តាំងពីពេលខ្ចីប្រាក់នោះមកគឺមានជំងឺកូវីដទើបខ្លួនរកចំណូលពុំសូវបាន ចំពោះការទាមទាររបស់ដើមចោទត្រង់ជំងឺចិត្ត និងការខាតបង់ពេលវេលានោះ គឺខ្លួនពុំមានលទ្ធភាពនោះទេ ដោយហេតុថាការរកចំណូលរបស់ខ្លួនសព្វថ្ងៃបានតែបន្តិចបន្តួច ហើយសព្វថ្ងៃនេះគឺខ្លួននៅជំពាក់ខាងធនាគារឯកជនផ្សេងៗច្រើនផងដែរ។ ហេតុនោះហើយទើបជាខ្លួនសុំសងតែប្រាក់ដើមដែលបានជំពាក់ចំនួន ៧,៨៤៦$ នោះ។ ចំពោះចំណុចទី២ ត្រង់ការទាមទារអនុវត្តសាលក្រមជាបណ្តោះ

អាសន្ននោះ ខ្លួនសុំឲ្យតុលាការកុំសម្រេចឲ្យអនុវត្តជាបណ្ដោះអាសន្នអីដោយសារខ្លួនត្រូវការពេលវេលាដើម្បីរកប្រាក់មកសងឱ្យដើមចោទវិញ ហើយខ្លួនសូមធ្វើកិច្ចសន្យាសងប្រាក់ជាមួយដើមចោទឈ្មោះ ជាថ្មីម្ដងទៀត ប្រសិនបើការធ្វើកិច្ចសន្យាលើកចុងក្រោយនេះខ្លួនពុំអនុវត្តតាមនោះទេ គឺខ្លួនសុខចិត្តទទួលខុសត្រូវជាមួយដើមចោទ និងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ ចំពោះចំណុចទី៣ ទាក់ទងនឹងប្រាក់ប្រដាប់ក្ដី គឺខ្លួនពុំឯកភាពតាមនោះទេ ព្រោះថាខ្លួនពុំមានលទ្ធភាពនោះទេ។ ជាចុងក្រោយខ្លួនសំណូមពរទៅដើមចោទឈ្មោះ មេត្តាអធ្យាស្រ័យមកលើខ្លួនចំពោះការខកខានក្នុងការសងប្រាក់ទៅគាត់ដោយសារតែជួបនឹងវិបត្តិបញ្ហាជំងឺកូវីដ ហើយខ្លួនសូមសន្យាថានឹងសងប្រាក់នោះទៅឱ្យដើមចោទវិញគ្រប់ចំនួនឱ្យដើមចោទតាមការសន្យារបស់ខ្លួន។

## **សំអាងហេតុ**

១.តាមពាក្យបណ្ដឹងចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ឃើញថាធ្វើឡើងត្រឹមត្រូវស្របតាមទម្រង់ដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម៉្យាងទៀតឃើញថាលំនៅឋានរបស់សហចុងចម្លើយមានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ នាំឲ្យសាលាដំបូងខេត្តតាកែវអាចយករឿងនោះមកដោះស្រាយបានស្របតាមបញ្ញត្តិមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.ដើមចោទឈ្មោះ បានដាក់ពាក្យបណ្ដឹងដោយបង្គាប់ឱ្យសហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ សងប្រាក់មកឱ្យខ្លួនវិញចំនួន ៧,៨៤៦$ និងជំងឺចិត្ត ការខាតបង់ពេលវេលាចំនួន ២០ម៉ឺលានរៀល ដោយសំអាងថា: សហចុងចម្លើយបានបង្កើតកិច្ចសន្យាលក់ទិញជាមួយខ្លួននូវសម្ភារៈ និងគ្រឿងត្រាក់ទ័រផ្សេងៗ។ ហើយនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ សហចុងចម្លើយក៏បានធ្វើកិច្ចសន្យាសងប្រាក់មកឱ្យខ្លួនក្នុងមួយខែចំនួន ១០០$ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ រហូតដល់គ្រប់ចំនួននៃលុយដែលជំពាក់។ រហូតដល់ថ្ងៃកំណត់ដែលត្រូវសងសហចុងចម្លើយគេចវេសមិនបានសងប្រាក់មកឱ្យខ្លួនដូចការសន្យានោះទេ។

៣.ផ្អែកតាមវិក័យប័ត្រលក់រាយចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ និងវិក័យប័ត្រលក់ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ឃើញថា: ដើមចោទ និងសហចុងចម្លើយពិតជាបានបង្កើតកិច្ចសន្យាលក់ទិញជាមួយគ្នានូវសម្ភារៈ និងគ្រឿងត្រាក់ទ័រផ្សេងៗជាមួយគ្នាពិតមែន។ ហើយនៅក្នុងការបង្កើតកិច្ចសន្យានោះទៀតសោត គឺដើមចោទ និងចុងចម្លើយបានបង្កើតជាកិច្ចសន្យារួមគ្នាស្របតាមបញ្ញត្តិមាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីផងដែរ។

៤.ផ្អែកតាមកិច្ចសន្យាសងប្រាក់ និងធានាអះអាងចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨, កិច្ចសន្យាសងប្រាក់ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២១០៩ និងកិច្ចសន្យាសងប្រាក់ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ឃើញថា: សហចុងចម្លើយទទួលស្គាល់នូវការខ្ចីប្រាក់ពីដើមចោទចំនួន ៧,៨៤៦$ និងតាមសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយថា: ខ្លួនបានសងប្រាក់ទៅឱ្យដើមចោទបានចំនួន ៣ខែ ដោយសរុបជាទឹកប្រាក់ចំនួន ៣០០$ រួចមកហើយ ហើយការសងប្រាក់ទៅឱ្យដើមចោទលើកចុងក្រោយគឺខ្លួនបានវេរតាមវីងវេរលុយ ចំពោះទឹកប្រាក់ដែលខ្លួននៅជំពាក់ដើមចោទសរុបនាពេលនេះមានចំនួន ៧,៥៤៦$ និងតាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងថា: ចុងចម្លើយបានសង

ប្រាក់មកឱ្យកូនក្តីខ្លួនពិតមែន ប៉ុន្តែបានតែចំនួន ២ខែប៉ុណ្ណោះ ស្មើនឹង២០០$ ចំពោះការសងផ្សេងៗទៀតគឺខ្លួនពុំបានដឹងនោះទេ ដោយកូនក្តីខ្លួនបានប្រាប់មកតែប៉ុន្នេះ។

៥.ផ្អែកតាមការពិនិត្យបង្កាន់ដៃវេរលុយ Wing ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ឃើញថា: ចុងចម្លើយឈ្មោះ ពិតជាបានវេរលុយតាមភ្នាក់ងារ Wing ឱ្យទៅដើមចោទឈ្មោះ តាមរយៈលេខទូរស័ព្ទរបស់ដើមចោទគឺមានលេខ: ០៩៧ ៣៣៣៣ ៩៩ ៤៤ ពិតមែន។ តុលាការយល់ឃើញថា: ចុងចម្លើយឈ្មោះ ពិតជាបានបង់ប្រាក់ឱ្យទៅដើមចោទឈ្មោះ បានចំនួន ០៣លើក ដោយសរុបជាទឹកប្រាក់ចំនួន ៣០០$ ពិតប្រាកដមែន។

៦.ឃើញថា: សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាមួយនឹងដើមចោទឈ្មោះ ឱ្យបានពេញលេញស្របតាមខ្លឹមសារនៃមាត្រា ៣៨៤ នៃក្រមរដ្ឋប្បវេណីនោះទេ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ទៅឱ្យដើមចោទតាមការប្តឹងទាមទារតាមបញ្ញត្តិមាត្រា ៣៨៥ នៃក្រមរដ្ឋប្បវេណី។

៧.តាមសេចក្តីថ្លែងការណ៍របស់លោក ដែលជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ដោយសុំអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ន ដោយហេតុថា: សហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចដូចមានក្នុងកិច្ចសន្យាសងប្រាក់ជាមួយនឹងកូនក្តីខ្លួន ហើយបានធ្វើឱ្យប៉ះពាល់ និងខូចប្រយោជន៍របស់កូនក្តីខ្លួនទៀតផង។ ឃើញថា: ចំពោះការសុំអនុវត្តសាលក្រមនេះជាបណ្តោះនេះ គប្បីសម្រេចប្រកាសឱ្យអនុវត្តតែចំពោះប្រាក់ដើមតែប៉ុណ្ណោះ ដោយឡែកចំពោះការទាមទារសំណងជំងឺចិត្ត និងការទាមទារផ្សេងៗគប្បីពុំសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ននោះទេ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចប្រកាសឱ្យអនុវត្តសាក្រមនេះជាបណ្តោះ អាសន្នត្រង់ចំណុចនៃប្រាក់ដើម តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៨.ឃើញថា: ដើមចោទឈ្មោះ បានទាមទារសំណងជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ២០លានរៀល ពីសហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ ប៉ុន្តែដើមបណ្តឹងពុំបានដាក់បញ្ចូលនូវភស្តុតាងណាមួយជូនមកតុលាការដើម្បីពិនិត្យឱ្យឃើញពីទំហំនៃការខាតបង់ និងការខូចខាតរបស់ខ្លួននោះទេ។ ហេតុដូច្នេះគប្បីតុលាការសម្រេចអំពីសំណងទៅតាមទំហំ និងព្យសនកម្មដែលបានកើតឡើងជាក់ស្តែង។

៩.យល់ឃើញថាប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តី តាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ហេតុដូច្នេះសម្រេច

១.ទទួលស្គាល់ពាក្យបណ្តឹងរបស់ឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ដោយ:

១.១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ សងប្រាក់ឱ្យទៅដើមចោទឈ្មោះ ចំនួន ៧,៥៤៦$(ប្រាំពីរពាន់ប្រាំរយសែសិបប្រាំមួយដុល្លាអាមេរិក)។

១.២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ សំណងជំងឺចិត្ត និងការខាតបង់ពេលវេលាឱ្យទៅដើមចោទឈ្មោះ ចំនួន ១,000,000៛(មួយលានរៀល) ។

២.សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី ១.១ នៃសេចក្ដីសម្រេចនេះ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

-សាលក្រមនេះបានទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសនាថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងចំពោះចុងចម្លើយ។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ,ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា:

---

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ,ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

បានឃើញ

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ចៅក្រម**

# ឧបសម្ព័ន្ធទី២៥

## កំណត់ហេតុប្រកាសសាលក្រម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តតាកែវ

## កំណត់ហេតុប្រកាសសាលក្រម

**សញ្ញាណនៃរឿងក្តី** ៖ រឿងរដ្ឋប្បវេណីលេខៈ ១៧១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

**កាលបរិច្ឆេទ** ៖ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០៣ និង ០០នាទីរសៀល

**ទីកន្លែង** ៖ សាលាដំបូងខេត្តតាកែវ

**ចៅក្រម** ៖ លោក ចៅក្រមសាលាដំបូងខេត្ត

**ក្រឡាបញ្ជី** ៖ លោក ក្រឡាបញ្ជីសាលាដំបូងខេត្ត

ភាគីដែលបង្ហាញខ្លួន ៖

**១.ដើមចោទឈ្មោះ** ភេទស្រី អាយុ២៥ឆ្នាំ មុខរបរធ្វើការរោងចក្រ មានទីលំនៅបច្ចុប្បន្ននៅភូមិភ្នំថ្នក់ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកកែវ។

**២.ចុងចម្លើយឈ្មោះ** ភេទប្រុស អាយុ២៨ឆ្នាំ មុខរបរកសិករ មានទីលំនៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ។

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**៖សុំឲ្យតុលាការចេញសាលក្រមសម្រេចៈ

១.លែងលះពីប្តីឈ្មោះ ភេទប្រុស អាយុ២៨ឆ្នាំ។

២.ប្រគល់កូនឈ្មោះ ភេទប្រុស កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦ ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង និងមានអំណាចមេបា។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**-ចៅក្រម៖** បានប្រកាសសាលក្រមនៅក្នុងសាលសវនាការ ដោយបានសម្រេចសេចក្តីដូចខាងក្រោមៈ

១.ទទួលស្គាល់ពាក្យបណ្តឹងរបស់ឈ្មោះ ភេទស្រី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ដោយៈ

១.១.លែងលះឈ្មោះ ភេទស្រី អាយុ២៥ឆ្នាំ ពីប្តីឈ្មោះ ភេទប្រុស អាយុ២៨ឆ្នាំ។

១.២.កំណត់យកចុងចម្លើយឈ្មោះ ភេទប្រុស អាយុ២៨ឆ្នាំ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។



សាលក្រមនេះបានទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ និងប្រកាសនាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងចុងចម្លើយ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោងបី និងហាសិបនាទីរសៀលនាថ្ងៃខែឆ្នាំដដែល។

បានអាននូវខ្លឹមសារទាំងស្រុងរបស់កំណត់ហេតុឲ្យភាគីស្តាប់ឆ្លើយថាត្រឹមត្រូវ និងព្រមផ្តិតមេដៃទុកជាចំណាំចំពោះមុខយើង។

**ដើមចោទ** **ក្រឡាបញ្ជី** **ចៅក្រម**

# ឧបសម្ព័ន្ធទី២៦

## លិខិតបញ្ជាក់ស្តីពីការចូលជាស្ថាពរនៃសាលក្រម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

លេខៈ ១៥៨ /២០២០

# លិខិតបញ្ជាក់

# ការចូលជាស្ថាពរនៃសាលក្រម

យើង ក្រឡាបញ្ជីនៃសាលាដំបូងសាលាដំបូងខេត្តតាកែវ។

-បានឃើញ មាត្រា ២៦៤ និងមាត្រា ៣៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៧១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ។

-បានឃើញ សាលក្រមលេខៈ ០៤ (ជ) ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ។

-បានឃើញ ពាក្យសុំបញ្ជាក់ស្ថាពរនៃសាលក្រមចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ របស់ឈ្មោះ

ភេទស្រី អាយុ២៥ឆ្នាំ ដែលមានខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខៈ ០៤ (ជ) ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ។

**បញ្ជាក់ថា**

១.សាលក្រមលេខៈ ០៤ (ជ) ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ បានចូលជាស្ថាពរចាប់ពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ ហើយ។

២.យើងចេញលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមនេះឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃចន្ទ ៧រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ,ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**